**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

UNIVERSITÉ ROYALE DE DROIT ET DES SCIENCES ECONOMIQUES

ROYAL UNIVERSITY OF LAW AND ECONOMICS


# សារណាបញ្ចប់ការសិក្សា

# សិទ្ធិ និងភាតព្វកិច្ចរបស់នីតិសទ្វាសជនក្រោយការលែងលះ និងមរណភាព

ស្រាវជ្រាវចាប់ពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **បេ ហាក់យូ**

**ក. ឡី សុភា**

សាស្ត្រាចារ្យណែនាំ

**បណ្ឌិត ព្រុំ រិទ្ធី**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៧ (អាហារូបករណ៍)

ឆ្នាំចូលសិក្សា ២០១៨

ឆ្នាំសរសេរសារណា ២០២២

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **មេ ហាក់យូ** និង **ឡី សុភា** ជានិស្សិតឆ្នាំទី៤ ថ្នាក់ L4B1 នៃថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រអាហារូបករណ៍ជំនាន់ទី ២៧ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំសិក្សា ២០១៨-២០២២។

## សូមគោរព និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ

**លោកអ្នកមានគុណទាំងទ្វេ** ដែលផ្តល់នូវការស្រឡាញ់ បីបាច់ចិញ្ចឹមកូនដោយព្រហ្មវិហារធម៌ ដោយមិនមានការរអ៊ូ និងហត់នឿយឡើយ ក្នុងការមើលថែទាំរូបកូនម្នាក់នេះ។ ទំហំនៃសេចក្តីស្រឡាញ់មួយនេះជាកម្លាំងចិត្តដ៏មហិមាដល់កូនក្នុងការជម្នះរាល់ឧបសគ្គដែលកូនបានជួបប្រទះក្នុងការសិក្សាកន្លងមក។ ពាក្យទូន្មាន ប្រៀនប្រដៅរបស់លោកឪពុក និងអ្នកម្តាយបានច្នៃរូបកូនឱ្យក្លាយជាកូនល្អ សិស្សល្អ និងពលរដ្ឋល្អមកដល់សព្វថ្ងៃនេះ។ សូមថ្លែងអំណរគុណចំពោះការទុកចិត្ត និងការផ្តល់កម្លាំងចិត្តកន្លងមក។

## យើងខ្ញុំសូមថ្លែងអំណរគុណជាពិសេសចំពោះ

ថ្នាក់ដឹកនាំ និងសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានអនុញ្ញាតនិងផ្តល់ឱកាសឱ្យក្រុមយើងខ្ញុំបានធ្វើការស្រាវជ្រាវលើប្រធានបទខាងលើនេះ និងទទួលបានការយល់ដឹងស៊ីជ្រៅលើនីតិគ្រួសារ ទាក់ទងជាមួយអានុភាពនៃការលែងលះ និងមរណភាព។

**បណ្ឌិត ព្រុំ រិទ្ធី** ដែលជាសាស្ត្រាចារ្យណែនាំក្នុងការសរសេរសារណាបញ្ចប់ការសិក្សារបស់ពួកខ្ញុំ ហើយលោកគ្រូបានចំណាយពេលវេលាយ៉ាងមានតម្លៃក្នុងការកែលម្អ និងផ្តល់យោបល់ មិនថាពួកខ្ញុំជួបឧបសគ្គអ្វីឡើយទាំងការសរសេរ និងស្វែងយល់ពីចំណុចសំខាន់របស់ប្រធានបទខាងលើ គឺលោកគ្រូតែងតែជួយ និងយកចិត្តទុកដាក់លើកិច្ចការរបស់ពួកខ្ញុំដោយមិនមានការយឺតយ៉ាវឡើយ។ ពួកខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយដែលមានលោកគ្រូជាសាស្ត្រាចារ្យណែនាំសារណារបស់ក្រុមយើងខ្ញុំ។

ជាអវសានកថា ក្រុមយើងខ្ញុំមានតែលើកដៃសូមប្រសិទ្ធិពរជ័យ សិរីមង្គល និងពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ជូនចំពោះលោកអ្នកមានគុណ ថ្នាក់ដឹកនាំ សាស្ត្រាចារ្យណែនាំ លោកគ្រូ អ្នកគ្រូ និងមិត្តភក្តិទាំងអស់ដែលបានផ្តល់កម្លាំងចិត្ត រួមទាំងសមាជិកក្រុមក្នុងការសម្រេចកិច្ចការមួយនេះ។

## **អារម្ភកថា**

អាពាហ៍ពិពាហ៍ជាលក្ខខណ្ឌមួយក្នុងការបង្កើតគ្រួសារមួយ តែភាពឋិតថេររបស់គ្រួសារវាអាស្រ័យលើសហព័ទ្ធទាំងពីរ។ ទម្រាំបង្កើតអាពាហ៍ពិពាហ៍មួយ ត្រូវឆ្លងកាត់តាមប្រពៃណីជាច្រើនរហូតដល់ថ្ងៃចុះសំបុត្រអាពាហ៍ពិពាហ៍ ហើយអាពាហ៍ពិពាហ៍នេះបង្កើតនូវសិទ្ធិ និងកាតព្វកិច្ចដល់នីតិសង្វាសជនទាំងពីរ។ នៅពេលដែលគ្រួសារមួយបានបែកបាក់ក៏បានឆ្លុះបង្ហាញពីសិទ្ធិ និងកាតព្វកិច្ចមួយចំនួនដែលត្រូវបន្ត និងមួយចំនួនទៀតដែលត្រូវបាត់បង់។ នត្ថិភាពនៃចំណងអាពាហ៍ពិពាហ៍បានបន្តបង្កើតនូវសិទ្ធិ និងកាតព្វកិច្ចដូចជា អាហារកិច្ច ការបែងចែកអំណាចមេបា ការទទួលខុសត្រូវលើកូនជាដើម។ ដោយឡែក ចំពោះសិទ្ធិ និងកាតព្វកិច្ចនៅពេលដែលសហព័ទ្ធទទួលមរណភាពវិញគឺ មានភាពខុសគ្នាមួយចំនួនពីសិទ្ធិ និងកាតព្វកិច្ចក្រោយការលែងលះ។

ដើម្បីរួមចំណែកក្នុងការយល់ដឹងឱ្យបានស៊ីជម្រៅទាក់ទងទៅនឹងសិទ្ធិ និងកាតព្វកិច្ចដែលលេចចេញក្នុងសម័យសតវត្សទី២១របស់សហព័ទ្ធក្រោយពេលលែងលះ និងមរណភាព យើងខ្ញុំដែលជានិស្សិតនីតិសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានរៀបចំសរសេរជាសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រដោយជ្រើសរើសយកនូវប្រធានបទ “**សិទ្ធិ និងកាតព្វកិច្ចរបស់នីតិសង្វាសជនក្រោយការលែងលះ និងមរណភាព**” ដើម្បីផ្តល់នូវការយល់ដឹងបន្ថែមពីសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួនជាប្តី ឬប្រពន្ធបន្ទាប់ពីមានការលែងលះ ឬមានសហព័ទ្ធម្ខាងទទួលមរណភាព ដោយផ្សារភ្ជាប់នឹងបញ្ហាមួយចំនួនដែលទាក់ទងនឹងច្បាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក នៅពេលដែលកូនបានបង្កើតកិច្ចសន្យាទិញតាមអនឡាញ ព្រមទាំងសិទ្ធិលើកម្មសិទ្ធិបញ្ញារបស់សហព័ទ្ធម្ខាងដែលទទួលមរណភាពជាដើម។

ដោយហេតុថាការស្រាវជ្រាវនេះពឹងផ្អែកលើការបកស្រាយច្បាប់ប្រទេសផ្សេងៗ ដើម្បីបំពេញបន្ថែមលើចំណុចខ្វះខាតរបស់ច្បាប់កម្ពុជា ដែលអាចនាំឱ្យមានកំហុស ឬផ្លាស់ប្តូរខ្លឹមសារនៃស្មារតីច្បាប់ខ្មែរក្នុងប្រការណាមួយដោយអចេតនា។ ហេតុនេះក្រុមយើងខ្ញុំសូមខន្តីអភ័យទោសផងដែរ និងសង្ឃឹមយ៉ាងមុតមាំថាការស្រាវជ្រាវនេះនឹងជួយបង្ហាញបន្ថែមទៅលើសិទ្ធិ និងកាតព្វកិច្ចរបស់សហព័ទ្ធ។ ការសិក្សានីតិគ្រួសារមួយមុខមិនគ្រប់គ្រាន់ក្នុងការបកស្រាយប្រធានបទនេះឱ្យបានស៊ីជម្រៅទៅតាមតថភាពជាក់ស្តែងស្របពេលដែលការវិវត្តច្បាប់កាន់តែមានពហុភាព និងប្រសិទ្ធិភាព។ ហេតុនេះក្រុមយើងខ្ញុំបានព្យាយាមរំលេចនូវនីតិផ្សេងៗជាគតិថ្មីៗក្នុងប្រធានបទមួយនេះ។ ជាចុងក្រោយយើងខ្ញុំមានតែសូមថ្លែងអំណរគុណដល់លោកអ្នកទាំងអស់គ្នាដែលបានចំណាយពេលដ៏មានតម្លៃក្នុងការអាន និងស្វែងយល់ពីគោលគំនិតរបស់យើងខ្ញុំ។ យើងខ្ញុំសូមគោរពជូនពរ និងសូមប្រសិទ្ធិពរជ័យដល់លោកអ្នករាល់គ្នាឱ្យជួបតែសំណាងល្អ។

ធ្វើនៅថ្ងៃច័ន្ទ ១១កើត ខែស្រាពណ៍ ព.ស ២៥៦៦ ឆ្នាំខាល

ត្រូវនឹងថ្ងៃទី ០៨ ខែសីហា ឆ្នាំ២០២២

# មាតិកា

ទំព័រ

## សេចក្តីផ្តើម


១. លំនាំបញ្ហា................................................1
២. ចំណោទបញ្ហា................................................1
៣. គោលបំណង និងសារៈសំខាន់នៃការស្រាវជ្រាវ................................................1
៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ................................................1
៥. វិធីសាស្ត្រស្រាវជ្រាវ................................................2
៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ................................................2


## ជំពូកទី១
## សិទ្ធិ និងកាតព្វកិច្ចរបស់សហព័ទ្ធក្នុងករណីលែងលះ


**ផ្នែកទី១៖ ទំនាក់ទំនងសហព័ទ្ធ**................................................ 3
**កថាខណ្ឌទី១៖ អានុភាពនៃការលែងលះចំពោះទ្រព្យសម្បត្តិសហព័ទ្ធ**................................................3
១. ការបែងចែកទ្រព្យតាមការព្រមព្រៀង................................................ 4
២. ការបែងចែកតាមកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ................................................ 4
៣. ការបែងចែកទ្រព្យតាមតុលាការ................................................ 5
**កថាខណ្ឌទី២៖ អានុភាពនៃការលែងលះចំពោះសិទ្ធិសហព័ទ្ធ**................................................6
១. ឈ្មោះសហព័ទ្ធ................................................ 7
២. អាពាហ៍ពិពាហ៍ថ្មី................................................ 7
៣. អាហារកាតព្វកិច្ចចំពោះសហព័ទ្ធ................................................ 7
៤. សញ្ជាតិ និងអត្តាធីនភាព................................................ 9
**ផ្នែកទី២៖ ទំនាក់ទំនងឪពុកម្តាយជាមួយកូន**................................................ 10
**កថាខណ្ឌទី១៖ អំណាចមេបា**................................................10
១. ការកំណត់អំណាចមេបា................................................ 10
១.១. ដោយការព្រមព្រៀង................................................ 11
១.២. ដោយសេចក្តីសម្រេចរបស់តុលាការ................................................ 11
២. សិទ្ធិក្នុងការចិញ្ចឹម និងអាស្រ័យទំនាក់ទំនងកូន................................................ 14
**កថាខណ្ឌទី២៖ ការទទួលខុសត្រូវចំពោះទង្វើកូន**................................................ 17

១. ការទទួលខុសត្រូវក្នុងកិច្ចសន្យា ........ 17
ក. ករណីអនីតិជនចុះកិច្ចសន្យាអេឡិចត្រូនិច ........ 17
ខ. ករណីអនីតិជនចុះកិច្ចសន្យាទិញបរិភោគហួសប្រមាណ ........ 19
២. ការទទួលខុសត្រូវអំពើអនីត្យានុកូលចំពោះទង្វើអនីតិជន ........ 19
ក. ការបែងចែកអាយុអនីតិជន ........ 20
ខ. សំណងនៃការទទួលខុសត្រូវ ........ 21

## ជំពូកទី២

## សិទ្ធិ និងភាតព្វកិច្ចសហព័ទ្ធ ក្នុងករណីសហព័ទ្ធម្ខាងទទួលមរណភាព

**ផ្នែកទី១៖ លក្ខណៈសម្បត្តិរបស់សហព័ទ្ធនៅរស់** ........ 22
**កថាខណ្ឌទី១៖ ការវិវត្តសិទ្ធិរបស់សហព័ទ្ធនៅរស់** ........ 22
**កថាខណ្ឌទី២៖ សិទ្ធិលើភាគបម្រុង** ........ 24
១.សញ្ញាណនៃភាគបម្រុង ........ 24
២. ភាគបម្រុងចំពោះសហព័ទ្ធ ........ 25
**ផ្នែកទី២៖ ការទទួល និងបដិសេធសន្តតិកម្ម** ........ 26
**កថាខណ្ឌទី១៖ សិទ្ធិបេតិកភណ្ឌ** ........ 26
១.លក្ខខណ្ឌក្នុងការទទួលសន្តតិកម្ម ........ 26
ក. ការយល់ព្រមទាំងស្រុង ........ 26
ខ. ការយល់ព្រមទាំងស្រុងតាមច្បាប់ ........ 27
គ. ការយល់ព្រមដោយមានកម្រិត ........ 27
២. លក្ខខណ្ឌក្នុងការបដិសេធសន្តតិកម្ម ........ 28
**កថាខណ្ឌទី២៖ សិទ្ធិក្រៅបេតិកភណ្ឌ** ........ 29
១. កម្មសិទ្ធិបញ្ញា ........ 29
២. ទំនាក់ទំនងញាតិពន្ធ ........ 30
**សេចក្តីសន្និដ្ឋាន** ........ 32
**អនុសាសន៍** ........ 33
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

ការបង្កើតគ្រួសារមួយមិនមែនជារឿងងាយស្រួលតាមតែការចង់បាននោះទេ។ វាឆ្លងកាត់នូវការអត់ធ្មត់ អត់ឱនឱ្យគ្នា និងការលះបង់ដើម្បីរក្សានូវចំណងគ្រួសារ។ ពាក្យថា "គ្រួសារ" មានអត្ថន័យស៊ីជម្រៅភ្ជាប់មកនូវកាតព្វកិច្ច សីលធម៌ សង្គម និងច្បាប់។ នៅពេលដែលមាននត្ថិភាពចំណងអាពាហ៍ពិពាហ៍ ក៏ភ្ជាប់មកនូវសិទ្ធិ និងកាតព្វកិច្ចផងដែរ។ នៅក្នុងសម័យសតវត្សទី២១នេះ មានចំណោទគតិយុត្តជាច្រើនដែលពាក់ព័ន្ធទៅនឹងបញ្ហាគ្រួសារ។ ជាក់ស្តែងក្នុងព្រះរាជាណាចក្រកម្ពុជាចាប់ផ្តើមមានភាពរីកចម្រើនលើវិស័យច្បាប់ដោយមានការជជែក វែកញែកពីបញ្ហាគតិយុត្តដូចជាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក កម្មសិទ្ធិបញ្ញា ការទទួលខុសត្រូវព្រហ្មទណ្ឌក្នុងរឿងនីតិគ្រួសារជាដើម។ ដោយហេតុថាដើម្បីដោះស្រាយបញ្ហានាសម័យបច្ចុប្បន្នគឺ តម្រូវឱ្យមានការបកស្រាយបន្ថែមយោងតាមករណីសិក្សារបស់ប្រទេសជឿនលឿននៃច្បាប់។ ហេតុនេះប្រធានបទ **សិទ្ធិ និងកាតព្វកិច្ចរបស់នីតិសន្ទាសជនក្រោយការលែងលះ និងមរណភាព** នឹងពិភាក្សាពីទំនាក់ទំនងរវាងសហព័ទ្ធ និងទំនាក់ទំនងឪពុកម្តាយនិងកូន ។

## ២. ចំណោទបញ្ហា

បញ្ហាចោទដែលបានកើតឡើងទាក់ទងនឹងប្រធានបទមានដូចខាងក្រោម៖

- តើនៅពេលដែលមានការលែងលះឬមរណភាពមានបញ្ហាគតិយុត្តអ្វីខ្លះ ដែលនឹងកើតមានឡើងក្នុងទំនាក់ទំនងចំពោះសហព័ទ្ធ និងរវាងកូន?
- តើការលែងលះ និងសហព័ទ្ធម្ខាងទទួលមរណភាពបានធ្វើឱ្យមានការប្រែប្រួលបញ្ហាគតិយុត្តអ្វីខ្លះ?
- ដោយឡែក ចំពោះសហព័ទ្ធដែលបន្សល់ទុកនូវស្នាដៃ តើសិទ្ធិលើស្នាដៃនៃកម្មសិទ្ធិបញ្ញាទាំងនេះនឹងត្រូវបានចាត់ចែងយ៉ាងដូចម្តេច?

## ៣. គោលបំណង និងសារៈសំខាន់នៃការស្រាវជ្រាវ

គោលបំណងសំខាន់នៃការស្រាវជ្រាវ គឺដើម្បីបង្ហាញពីបញ្ហាចោទដែលកើតមានឡើងក្នុងទំនាក់ទំនងរវាងសហព័ទ្ធនិងកូន សហព័ទ្ធនិងសហព័ទ្ធ រួមទាំងសិទ្ធិ និងកាតព្វកិច្ចក្នុងនីតិគ្រួសារដែលទាក់ទងនឹងនីតិដទៃផ្សេងទៀត។

ម៉្យាងទៀត ការស្រាវជ្រាវប្រធានបទខាងលើក៏បានក្លាយជាឯកសារយ៉ាងសំខាន់មួយសម្រាប់អ្នកសិក្សាបានស្វែងយល់បន្ថែមពីទំនាក់ទំនងរបស់គ្រួសារក្រោយពេលលែងលះ និងមរណភាពរបស់សហព័ទ្ធ។ សិទ្ធិ និងកាតព្វកិច្ចមួយចំនួនមានភាពប្រទាក់ក្រឡាជាមួយនឹងនីតិដទៃទៀតដែលនឹងបកស្រាយនៅផ្នែកខាងក្រោម។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ប្រធានបទមួយនេះនឹងលើកឡើងតែក្រោយពេលលែងលះ និងពេលមរណភាពរបស់សហព័ទ្ធ ចំពោះសិទ្ធិ និងកាតព្វកិច្ចមួយចំនួនដែលក្រុមយើងខ្ញុំគិតថាចាំបាច់ក្នុងការបកស្រាយ ដោយមិនរៀបរាប់ពីនីតិវិធីក្នុង

ខ្លឹមសារនៃអត្ថបទស្រាវជ្រាវនេះទេ។ ក្នុងប្រធានបទនេះទៀតសោតផ្តោតតែរឿងនីតិសង្វាសជន ដែលខ្លឹមសារផ្តោតទៅលើសិទ្ធិ និងកាតព្វកិច្ច។ ម្យ៉ាងទៀត ពាក្យថា "សហព័ទ្ធ" ដែលលើកយកមកប្រើប្រាស់ក្នុងខ្លឹមសារអត្ថបទនេះ សំដៅទៅលើប្តីនិងប្រពន្ធដែលបានចុះសំបុត្រអាពាហ៍ពិពាហ៍ស្របតាមផ្លូវច្បាប់។ ចំណែកឯពាក្យថា "កូន" សំដៅដល់ អនីតិជនដែលមានអាយុក្រោម ១៨ឆ្នាំ។

## ៥. វិធីសាស្ត្រស្រាវជ្រាវ

ចំពោះវិធីសាស្ត្រក្នុងការស្រាវជ្រាវប្រធានបទខាងលើគឺផ្តោតលើប្រភពដូចខាងក្រោម៖

- វិភាគឯកសារច្បាប់កម្ពុជាមានជាធរមាន និងច្បាប់ដែលនិរាករណ៍ដើម្បីសិក្សាពីការវិវត្ត និងគតិច្បាប់ពីមុន
- យោងឯកសារច្បាប់ពីប្រទេសដទៃដើម្បីបកស្រាយបន្ថែមលើអត្ថន័យ ក៏ដូចជាការអនុវត្តជាក់ស្តែង
- បន្ថែមគំនិតតាមប្រភពព័ត៌មាន និងឯកសារវិភាគតាមប្រព័ន្ធអនឡាញ។

## ៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ចំពោះការស្រាវជ្រាវនេះត្រូវបានបែងចែកជា ២ (ពីរ) ជំពូកធំៗ ស្របតាមប្រធានបទខាងលើ៖

- ជំពូកទី១៖ សិទ្ធិនិងកាតព្វកិច្ចរបស់សហព័ទ្ធក្នុងករណីលែងលះ នឹងលើកឡើងពីទំនាក់ទំនងសហព័ទ្ធមានដូចជាអានុភាពនៃការលែងលះចំពោះទ្រព្យសម្បត្តិ រួមទាំងអានុភាពនៃការលែងលះចំពោះសិទ្ធិសហព័ទ្ធ ហើយផ្នែកមួយទៀតនឹងលើកឡើងពីទំនាក់ទំនងឪពុកម្តាយចំពោះកូនដែលផ្តោតទៅលើអំណាចមេបា សិទ្ធិក្នុងការចិញ្ចឹមកូននិងអាស្រ័យទំនាក់ទំនងកូន ការទទួលខុសត្រូវចំពោះកូនក្នុងកិច្ចសន្យា និងអំពើអនីត្យានុកូល។
- ជំពូកទី២៖ សិទ្ធិ និងកាតព្វកិច្ចរបស់សហព័ទ្ធក្នុងករណីសហព័ទ្ធម្ខាងទទួលមរណភាព នឹងលើកឡើងពីលក្ខណៈសម្បត្តិរបស់សហព័ទ្ធនៅរស់ រួមទាំងការវិវត្តនៃសិទ្ធិរបស់សហព័ទ្ធ ភាគបម្រុងការទទួលនិងបដិសេធចំពោះសន្តតិកម្ម។ បន្ថែមពីនេះនឹងលើកឡើងពីសិទ្ធិក្រៅបេតិកភណ្ឌដែលនិយាយពីកម្មសិទ្ធិបញ្ញា និងទំនាក់ទំនងញាតិពន្ធ។

# ជំពូកទី១
# សិទ្ធិ និងភាតព្វកិច្ច
# របស់សហព័ទ្ធ
# ក្នុងករណីលែងលះ

# ជំពូកទី១

# សិទ្ធិ និងកាតព្វកិច្ចរបស់សហព័ទ្ធក្នុងករណីលែងលះ

សុភាសិតខ្មែរបុរាណតែងរណ្ដំនូវឃ្លាមួយ “ចាននៅក្នុងរាវលែងអីនឹងរណ្ដំគ្នា”[1] មានន័យថា ក្នុងចំណងអាពាហ៍ពិពាហ៍មួយ គ្រួសារតែងតែមានការប៉ះពារនូវពាក្យសម្ដីរវាងគ្នានិងគ្នា។ ហើយការទាស់ទែង គួបផ្សំនឹងកត្តាផ្សេងៗទៀតបានធ្វើឱ្យចំណងអាពាហ៍ពិពាហ៍មួយប្រេះស្រាំ រហូតឈានទៅដល់ការលែងលះ។ ហេតុដូចនេះហើយ ក្នុងករណីដែលសហព័ទ្ធលែងលះគ្នា តើត្រូវជាប់មាននូវសិទ្ធិ និងកាតព្វកិច្ចអ្វីខ្លះ?

## ផ្នែកទី១៖ ទំនាក់ទំនងសហព័ទ្ធ

អ្វីៗនឹងត្រូវបានបញ្ចប់នៅពេលដែលចំណងអាពាហ៍ពិពាហ៍ដើរដល់ចំណុចលែងលះ។ចាប់តាំងពីថ្ងៃដែលការលែងលះត្រូវបានចូលជាស្ថាពរ អានុភាពនៃចំណងអាពាហ៍ពិពាហ៍របស់សហព័ទ្ធនឹងត្រូវបានរំលាយ។ វាក៏មានអានុភាពចំពោះទ្រព្យសម្បត្តិសហព័ទ្ធ និងសិទ្ធិសហព័ទ្ធផងដែរ។ តើការបែងចែកទ្រព្យសម្បត្តិនឹងប្រព្រឹត្តទៅដូចម្ដេច ហើយសិទ្ធិសហព័ទ្ធនឹងមានការប្រែប្រួលអ្វីខ្លះ?

### កថាខណ្ឌទី១៖ អានុភាពនៃការលែងលះចំពោះទ្រព្យសម្បត្តិសហព័ទ្ធ

នៅពេលដែលចំណងអាពាហ៍ពិពាហ៍ត្រូវបានបញ្ចប់ សិទ្ធិមួយចំនួននឹងមិនត្រូវបានយកមកអនុវត្តទៀតឡើយ។ ជាក់ស្ដែង ចំណែកបន្ទុកនៃសោហ៊ុយអាពាហ៍ពិពាហ៍ដូចជាប្រាក់ចំណូលនិងស្ថានភាពផ្សេងទៀត ទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធ ទ្រព្យសម្បត្តិដែលទទួលបានតាមរយៈប្រទានកម្ម សន្តតិកម្ម អច្ច័យ-ទានក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ និងទ្រព្យសម្បត្តិជាតម្លៃតបដែលបានមកពីការចាត់ចែងទ្រព្យសម្បត្តិសុទ្ធតែជាសិទ្ធិដែលនឹងត្រូវបានរំលត់ នៅពេលចំណងអាពាហ៍ពិពាហ៍ត្រូវបានផ្ដាច់តាមរយៈការលែងលះ។ ត្រង់ចំណុចនេះមានន័យថាទ្រព្យដោយឡែកដែលមានមុនចំណងអាពាហ៍ពិពាហ៍ ឬត្រូវបានបង្កើតក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ត្រូវប្រគល់ឱ្យសាមីសហព័ទ្ធជាអ្នកគ្រប់គ្រងវិញ។[2] មិនតែប៉ុណ្ណោះ ទ្រព្យសម្បត្តិរួម ការគ្រប់គ្រងនិងការប្រើប្រាស់ទ្រព្យសម្បត្តិ ព្រមទាំងទំនួលខុសត្រូវផ្សេងៗដូចជាការទទួលខុសត្រូវដោយសាមគ្គីភាពចំពោះកាតព្វកិច្ច ការចាត់ចែងទ្រព្យសម្បត្តិរួមរបស់ប្ដីប្រពន្ធ និងការអាស្រ័យនៅទ្រព្យសម្បត្តិដោយឡែកនឹងត្រូវបាត់បង់អានុភាពផងដែរ។

នៅពេលទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានកាត់ផ្ដាច់ទ្រព្យសម្បត្តិរវាងសហព័ទ្ធនឹងត្រូវបានបែងចែក។ តាមប្រព័ន្ធច្បាប់ការបែងចែកទ្រព្យសម្បត្តិអាចធ្វើបានតាមវិធី៣យ៉ាងគឺ ការបែងចែកទ្រព្យទៅតាមការព្រមព្រៀង ការបែងចែកទ្រព្យទៅតាមកិច្ចសន្យាទ្រព្យសម្បត្តិ និងការបែងចែកទ្រព្យតាមតុលាការ។

[1] ប៊ុត នាង, *ប្រមូលភាសិតខ្មែរ* (សមាគមសម្ដេច ជួន ណាត, ២០២០), ១៥។

[2] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៧២។

## ១. ការបែងចែកទ្រព្យតាមការព្រមព្រៀង

ការបែងចែកទ្រព្យសម្បត្តិគឺជារឿងមួយដ៏សំខាន់ និងអាចចាត់ទុកថាមានលក្ខណៈស្មុគស្មាញនិងស៊ាំញ៉ាំផងដែរ។ ទ្រព្យសម្បត្តិប្តីប្រពន្ធអាចបែងចែកជា ៣ ប្រភេទ គឺទ្រព្យសម្បត្តិរួម ទ្រព្យសម្បត្តិដោយឡែករបស់ប្តី និង ទ្រព្យសម្បត្តិដោយឡែករបស់ប្រពន្ធ។ ក្រមរដ្ឋប្បវេណីបានបង្ហាញថា ការបែងចែកទ្រព្យសម្បត្តិគឺត្រូវធ្វើឡើងដោយយុត្តិធម៌ ដោយផ្អែកទៅតាមពិភាក្សារបស់ភាគីទាំងសងខាង។[3] ដូច្នេះវាអាចនឹងមានភាពងាយស្រួលបើសិនជានៅពេលរំលាយចំណងអាពាហ៍ពិពាហ៍ សហព័ទ្ធស្រុះស្រួលនិងឯកភាពគ្នាទៅតាមការព្រមព្រៀងបែងចែកទ្រព្យសម្បត្តិទៅតាមការពិភាក្សា ដោយបង្ហាញឱ្យច្បាស់អំពីទ្រព្យសម្បត្តិរួម ចំណែកនៃទ្រព្យសម្បត្តិដោយឡែក និងទំហំនៃលទ្ធកម្មផ្សេងៗត្រូវគោរពទៅតាមការព្រមព្រៀងរបស់គូភាគី។

## ២. ការបែងចែកតាមកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

ប្រសិនបើសហព័ទ្ធមានកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ នោះការបែងចែកទ្រព្យសម្បត្តិនឹងត្រូវគោរពទៅតាមកិច្ចសន្យាដែលបានធ្វើឡើងនោះ។ កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ គឺជាកិច្ចសន្យាដែលបង្កើតឡើងដោយសហព័ទ្ធស្តីពីទំនាក់ទំនងទ្រព្យសម្បត្តិនៅមុនឬក្រោយអាពាហ៍ពិពាហ៍។ ហើយកិច្ចសន្យានេះក៏ត្រូវបានទទួលស្គាល់នៅក្នុងក្រមរដ្ឋប្បវេណីផងដែរ។ ទម្រង់នៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ចាំបាច់ត្រូវធ្វើជាលាយលក្ខណ៍អក្សរ[4] និងមិនត្រូវផ្ទុយពីបញ្ញត្តិស្តីពីសិទ្ធិទាមទារអាហារកាតព្វកិច្ច និងភាគបម្រុងឡើយ។[5]

កិច្ចសន្យាប្តីប្រពន្ធនេះមានភាពចាំបាច់ណាស់ ក្នុងការសម្របសម្រួលដល់ការពិភាក្សានាពេលអនាគតរបស់ប្តីប្រពន្ធ ដោយសារគោលបំណងចម្បងនៃការបង្កើតកិច្ចសន្យាប្តីប្រពន្ធ គឺដើម្បីទប់ស្កាត់វិវាទលើទំនាក់ទំនងទ្រព្យសម្បត្តិ និងដើម្បីបញ្ជាក់អំពីទំនាក់ទំនងសិទ្ធិ និងករណីយកិច្ចរបស់ប្តីប្រពន្ធ។ មានបញ្ហាចោទជាច្រើនបានលើកឡើងថា តើកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធនេះត្រូវបានគេទទួលស្គាល់កម្រិតណា ជាពិសេសនៅក្នុងទំនាក់ទំនងនៃការជួញដូរ និងទំនាក់ទំនងជាមួយតតិយជន។ ប្រសិនបើប្តីប្រពន្ធបានធ្វើកិច្ចសន្យាផ្សេងក្រៅពីប្រព័ន្ធទ្រព្យសម្បត្តិដែលបានកំណត់ដោយច្បាប់ហើយមិនបានចុះបញ្ជីទេ នោះកិច្ចសន្យានោះមិនអាចយកមកតតាំងជាមួយតតិយជនបានឡើយ។[6]

កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ នៅប្រទេសជប៉ុនមានលក្ខណៈខុសគ្នាពីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធនៅប្រទេសកម្ពុជា។ ដោយហេតុថា កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធនៅប្រទេសកម្ពុជា ត្រូវបានបង្កើតឡើងនៅមុន ឬក្រោយពេលរៀបអាពាហ៍ពិពាហ៍ ចំណែកឯនៅប្រទេសជប៉ុនវិញ កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធត្រូវចុះ

---

[3] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៨០។

[4] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៧០។

[5] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៦៩។

[6] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៧០។

បញ្ជីមុនពេលអាពាហ៍ពិពាហ៍ និងមិនអាចប្តូរក្រោយអាពាហ៍ពិពាហ៍ជាដាច់ខាត[7] ហេតុនេះហើយទើបបានជាប្រជាជនជប៉ុនមិនសូវពេញនិយមប្រើរបបនេះទេ។

ជាក់ស្តែង មុនពេលអាពាហ៍ពិពាហ៍លោក ក និងអ្នកស្រី ខ បានធ្វើកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ និងបានរៀបអាពាហ៍ពិពាហ៍ស្របច្បាប់។ ក្រោយមកអ្នកទាំងពីរបានលែងលះគ្នា។ ដូចនេះករណីការលែងលះគ្នានេះ ការបែងចែងទ្រព្យសម្បត្តិត្រូវអនុលោមតាមប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា។ ផ្ទុយទៅវិញ បើមុននិងក្រោយអាពាហ៍ពិពាហ៍ លោក ក និងអ្នកស្រី ខ ពុំបានធ្វើកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធទេ ហើយក្រោយមកអ្នកទាំងពីរបានលែងលះគ្នាដោយការព្រមព្រៀងធ្វើការបែងចែកទ្រព្យសម្បត្តិ។ ដូចនេះការបែងចែកទ្រព្យសម្បត្តិត្រូវអនុលោមតាមការព្រមព្រៀងរបស់គូភាគី។

### ៣. ការបែងចែកទ្រព្យតាមតុលាការ

ផ្ទុយទៅវិញ ប្រសិនបើប្តីប្រពន្ធមិនមានកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ និងរកចំណុចរួមគ្នាមិនបានក្នុងការព្រមព្រៀងបែងចែកទ្រព្យសម្បត្តិទេ នោះសហព័ទ្ធត្រូវអនុវត្តតាមការសម្រេចរបស់តុលាការ។[8] សហព័ទ្ធម្នាក់ៗត្រូវទទួលបាននូវទ្រព្យសម្បត្តិដោយឡែករួមមានដូចជា ទ្រព្យសម្បត្តិដែលសហព័ទ្ធមាននៅមុនពេលអាពាហ៍ពិពាហ៍ ទ្រព្យសម្បត្តិដែលសហព័ទ្ធទទួលបានដោយប្រទានកម្ម សន្តតិកម្ម អច្ច័យទាន នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ និងទ្រព្យសម្បត្តិជាតម្លៃតបដែលទទួលបានពីការចាត់ចែងទ្រព្យសម្បត្តិ។[9] របបទ្រព្យសម្បត្តិដោយឡែករបស់ប្តីប្រពន្ធរួមបញ្ចូលទាំង ទ្រព្យសម្បត្តិដែលប្តីឬប្រពន្ធមានពីមុនពេលរៀបអាពាហ៍-ពិពាហ៍ និងទ្រព្យសម្បត្តិដែលបានដោយឈ្មោះសាមីខ្លួនក្នុងអំឡុងពេលអាពាហ៍ពិពាហ៍។ ទ្រព្យសម្បត្តិដោយឡែក មានតែទ្រព្យសម្បត្តិដែលបានទទួលលទ្ធកម្មតាមរយៈប្រទានកម្ម សន្តតិកម្ម ឬអច្ច័យទាន ព្រមទាំងប្រាក់ដែលបានមកពីការចាត់ចែងទ្រព្យសម្បត្តិទាំងនេះ។[10] ដូច្នេះក្រៅពីនេះ ត្រូវចាត់ទុកថាជាទ្រព្យសម្បត្តិរួម។[11]

សហព័ទ្ធនីមួយៗត្រូវទទួលបានចំណែកមួយភាគពីរនៃទ្រព្យសម្បត្តិរួមផងដែរ។[12] ប៉ុន្តែវាមិនរួមបញ្ចូលនូវករណីពិសេស និងការទាមទាររបស់ភាគីម្ខាងទៀតដែលជាប្តីឬប្រពន្ធឡើយ ដោយហេតុថាតុលាការនឹងធ្វើការបែងចែកទ្រព្យសម្បត្តិរួមដោយពិចារណាទៅលើស្ថានភាពដទៃទៀតដូចជា៖

- ចំណែកនៃវិភាគទានក្នុងការបង្កើតទ្រព្យសម្បត្តិ រួមមានទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗ
- ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗចំពោះលទ្ធកម្មនៃទ្រព្យសម្បត្តិ

[7] ក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា៧៥៥ - ៧៥៨។

[8] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណី ដែលមិនមែនជាបណ្តឹង, លេខ នស/រកម/០៧១០/០១៣, ០៩ មិថុនា ២០១០, ឧបសម្ព័ន្ធ ផ្នែកទី៤ ចំណុច៦។

[9] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៧២។

[10] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៧២។

[11] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៧៣។

[12] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៨០។

- ការថែរក្សាឬការបង្កើនទ្រព្យអំឡុងពេលអាពាហ៍ពិពាហ៍ កម្រិតជីវភាពរស់នៅក្នុងរយៈពេលនៃចំណងអាពាហ៍ពិពាហ៍ អាយុស្ថានភាពផ្លូវចិត្តនិងផ្លូវកាយ វិជ្ជាជីវៈ ប្រាក់ចំណូល លទ្ធភាពធ្វើការងាររបស់ភាគីនីមួយៗ និង
- ផលប្រយោជន៍របស់កូនជាដើម ។

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានចែងយ៉ាងច្បាស់ថា ការងារមេផ្ទះមានតម្លៃស្មើគ្នានឹងកម្រៃដែលបានមកពីការងារធ្វើនៅក្រៅផ្ទះ។[13] ដោយព្រោះថាការងារគេហកិច្ច ទោះបីជាការបរិច្ចាគមិនមានរូបភាពជាតម្លៃសេដ្ឋកិច្ចក៏ដោយ ក៏ត្រូវបានវាយតម្លៃថាជាការបរិច្ចាគសម្រាប់ធ្វើលទ្ធកម្ម ក្នុងការថែរក្សានិងបង្កើនទ្រព្យសម្បត្តិដែរ ហើយការងារនេះទៀតសោតក៏មានតម្លៃស្មើនឹងការបរិច្ចាគជាទំហំទឹកប្រាក់ក្នុងតម្លៃសេដ្ឋកិច្ចដែរ។ ហេតុនេះហើយ ទើបនៅប្រទេសកម្ពុជា ទោះជាស្ត្រីមេផ្ទះក៏ដោយភាគច្រើនអាចធ្វើលទ្ធកម្មមួយភាគពីរនៃទ្រព្យសម្បត្តិដែលបានបង្កើតក្រោយអាពាហ៍ពិពាហ៍ដែរ ដោយហេតុថាច្បាប់កម្ពុជាបានឱ្យតម្លៃការងារមេផ្ទះស្មើគ្នានឹងតម្លៃនៃការងារខាងក្រៅ។[14]

ជាក់ស្តែង បន្ថែមពីលើឧទាហរណ៍ខាងដើម ក្នុងករណីគ្មានកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ហើយគូភាគីមិនមានការព្រមព្រៀងគ្នាទេ នោះត្រូវដាក់ពាក្យសុំធ្វើការបែងចែកទ្រព្យសម្បត្តិ ដើម្បីផ្តល់លទ្ធភាពឱ្យតុលាការពិចារណាទៅលើ៖

- ទ្រព្យសម្បត្តិដោយឡែក ដែលសហព័ទ្ធនីមួយៗត្រូវទទួលបាន
- បន្ថែមពីលើទ្រព្យសម្បត្តិដោយឡែក សហព័ទ្ធនីមួយៗមានសិទ្ធិទទួលយកមួយភាគពីរនៃទ្រព្យសម្បត្តិរួម (ប្រសិនបើមិនមានករណីពិសេស និងមានការទាមទាររបស់ភាគីណាមួយនោះទេ)។

### កថាខណ្ឌទី២៖ អានុភាពនៃការលែងលះចំពោះសិទ្ធិសហព័ទ្ធ

ការលែងលះគ្នាបានរំសាយអានុភាពអាពាហ៍ពិពាហ៍ គិតចាប់តាំងពីថ្ងៃប្រកាសសាលក្រមស្ថាពរនៃការលែងលះ។[15] នៅពេលដែលសហព័ទ្ធផ្តាច់ចំណងអាពាហ៍ពិពាហ៍ នោះសិទ្ធិមួយចំនួនរបស់សហព័ទ្ធក៏ត្រូវបានប្រែប្រួលទៅតាមនោះដែរ ដែលរួមមានឈ្មោះសហព័ទ្ធ សិទ្ធិរៀបអាពាហ៍ពិពាហ៍ថ្មី អាហារកាតព្វកិច្ចចំពោះសហព័ទ្ធ សញ្ជាតិនិងអត្តាធីនភាព។

---

[13] រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា, មាត្រា ៣៦។ *មើលបន្ថែម* ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៨០។

[14] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៨០។

[15] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, ក្រឹត្យច្បាប់លេខ ៥៦ ក្រ, ២៦ កក្កដា ១៩៨៩, មាត្រា៦៩។

### ១. ឈ្មោះសហព័ទ្ធ

ប្ដីឬប្រពន្ធដែលបានប្ដូរនាមត្រកូលថ្មីដោយអាពាហ៍ពិពាហ៍អាចប្រើនាមត្រកូល ដែលមាននៅមុនរៀបអាពាហ៍ពិពាហ៍វិញបាន ឬអាចប្រើនាមត្រកូលដែលបានប្រើនៅពេលលែងលះគ្នាក៏បាន។[16] ក្រឡេកមកមើលការអនុវត្តជាក់ស្ដែងនៅក្នុងប្រទេសកម្ពុជាវិញ ដោយសារប្រជាជនខ្មែរភាគច្រើនមិនបានផ្លាស់ប្ដូរនូវនាមត្រកូលរបស់ខ្លួននៅពេលរៀបអាពាហ៍ពិពាហ៍ទេ ដូច្នេះវាមិនបង្កជាលក្ខណៈស្មុគស្មាញដែលតម្រូវឱ្យមានការកែប្រែនូវនាមត្រកូលចុះឡើងនោះឡើយ មានន័យថាសហព័ទ្ធមិនចាំបាច់ធ្វើការផ្លាស់ប្ដូរនាមត្រកូល ក្រោយពេលពេលលែងលះទេ។ ដោយឡែក ប្រសិនជាមានការប្ដូរឈ្មោះនៅពេលរៀបអាពាហ៍ពិពាហ៍ ភាគីណាមួយបានផ្លាស់ប្ដូរនាមត្រកូលខ្លួន ភាគីនោះនៅតែអាចបន្តការប្រើប្រាស់នាមត្រកូលដែលបានផ្លាស់ប្ដូរ ឬអាចត្រឡប់មកប្រើនាមត្រកូលមុនពេលរៀបអាពាហ៍ពិពាហ៍របស់ខ្លួនវិញក៏បាន។

### ២. អាពាហ៍ពិពាហ៍ថ្មី

ក្រោយពីអាពាហ៍ពិពាហ៍រំលាយដោយមូលហេតុមរណភាពឬលែងលះគ្នា នារីអាចរៀបអាពាហ៍ពិពាហ៍ថ្មីមួយទៀតបាន ប៉ុន្តែត្រូវស្ថិតនៅក្នុងភាពមេម៉ាយចំនួន ១២០ថ្ងៃ គិតចាប់ពីថ្ងៃដែលប្ដីស្លាប់ ឬពីថ្ងៃប្រកាសសាលក្រមស្ថាពរនៃការលែងលះ។[17] ការធ្វើបែបនេះគឺដើម្បីងាយស្រួលក្នុងការកំណត់រកនូវបិតុភាព ថាតើកូនដែលនៅក្នុងផ្ទៃនោះជារបស់ប្ដីដែលនៅក្នុងចំណងអាពាហ៍ពិពាហ៍មុនឬក្រោយ។ ប៉ុន្តែបញ្ញត្តិនេះនឹងមិនត្រូវយកមកអនុវត្តឡើយ លុំកណាមិនមានបញ្ហាទាក់ទងទៅនឹងការប្រកួតប្រជែងអំពីការកំណត់រកបិតុភាព ខណៈបើស្ត្រីនោះមានលិខិតបញ្ជាក់ពីពេទ្យអំពីការមិនមានផ្ទៃពោះ។[18]

### ៣. អាហារកាតព្វកិច្ចចំពោះសហព័ទ្ធ

អាហារកាតព្វកិច្ចរវាងសហព័ទ្ធ គឺជាទម្រង់មួយក្នុងចំណោមអាហារកាតព្វកិច្ចបី[19]ផ្សេងទៀតដែលមានចែងក្នុងក្រមរដ្ឋប្បវេណី។ គោលបំណងនៃអាហារកាតព្វកិច្ច គឺដើម្បីឱ្យភាគីដែលជាសហព័ទ្ធម្ខាងដែលមានជីវភាពប្រសើរជាងសហព័ទ្ធម្ខាងទៀតក្រោយពេលលែងលះ ឱ្យទទួលបាននូវជំនួយផ្នែកហិរញ្ញវត្ថុ ក្នុងន័យសម្រួលដល់បន្ទុកជីវភាពរបស់សហព័ទ្ធដែលខ្វះខាត។

ប៉ុន្តែចំពោះករណីលែងលះ ភាគីដែលគ្មានកំហុសហើយខ្វះខាត អាចស្នើសុំអាហារកិច្ចពីភាគីម្ខាងទៀតបាន ហើយភាគីនោះត្រូវជួយឧបត្ថម្ភទៅតាមលទ្ធភាពដែលខ្លួនមាន ឬទៅតាមការព្រមព្រៀងរបស់ភាគីអំពីកម្រិតអាហារកិច្ចដែលត្រូវផ្គត់ផ្គង់ទៅឱ្យភាគីម្ខាងទៀត។[20] អាហារកាតព្វកិច្ចត្រូវធ្វើឡើងទៅតាមការយល់ព្រម

---

[16] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៨១។

[17] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៦២។

[18] សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគ៥: គម្ពីរទី៧ (ភ្នំពេញ, ២០១០) ១១ និង ១២។

[19] អាហារកាតព្វកិច្ចទាំងបីរួមមាន៖ អាហារកាតព្វកិច្ចរវាងសហព័ទ្ធ អាហារកាតព្វកិច្ចរវាងឪពុកម្ដាយចំពោះកូនជាអនីតិជន និងអាហារកាតព្វកិច្ចរវាងញាតិ ។

[20] ច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, ក្រឹត្យច្បាប់លេខ ៥៦ ក្រ, ២៦ កក្កដា ១៩៨៩, មាត្រា៧៦ (មិនទាន់និរាករណ៍)។

របស់ភាគីទាំងសងខាង[21] ក្នុងទម្រង់ជាសាច់ប្រាក់ ឬជារបស់ និងអាចប្រែប្រួលដោយការកើនឬថយទៅតាមការសំណូមពររបស់ភាគី និងទៅតាមលទ្ធភាពជាក់ស្តែងរបស់ភាគីដែលផ្តល់អាហារកិច្ច[22]។ ប៉ុន្តែបើភាគីទាំងសងខាងមិនឯកភាពគ្នាទេ នោះតុលាការជាអ្នកសម្រេច។[23] ប៉ុន្តែបើជនដែលទទួលអាហារកិច្ចនោះរៀបអាពាហ៍-ពិពាហ៍ថ្មីទៀត ជននោះលែងមានសិទ្ធិទទួលអាហារកិច្ចបន្តទៀតទេ។ [24] នៅប្រទេសជប៉ុនមានដ្យាក្រាមរូមមន្តសម្រាប់គណនាពីចំនួនទឹកប្រាក់នៃអាហារកាតព្វកិច្ច ដូចបង្ហាញនៅខាងក្រោម៖ [25]

- កម្មវត្ថុនៃអាហារកាតព្វកិច្ច = ចំណូលសរុបរបស់អ្នកមានកាតព្វកិច្ច – (ពន្ធជាអាទិ៍ + ចំណាយលើអាជីវកម្ម + ចំណាយពិសេស)
- សោហ៊ុយសម្រាប់ជីវភាពអប្បបរមានៃបុគ្គលមានសិទ្ធិ = (ថ្លៃស្នាក់នៅ + អាហារបីពេល + សម្លៀកបំពាក់ + ថ្លៃពេទ្យធម្មតា) – ចំណូលរបស់អ្នកមានសិទ្ធិ
- ទឹកប្រាក់នៃអាហារកាតព្វកិច្ច = សោហ៊ុយសម្រាប់ជីវភាពអប្បបរមា ឬ កម្មវត្ថុនៃអាហារកាតព្វកិច្ចដែលទាបជាង។

**កំណត់ចំណាំ៖**

- ពន្ធជាអាទិ៍៖ ពន្ធលើប្រាក់បៀវត្សន៍, ពន្ធធានារ៉ាប់រង
- ចំណាយលើអាជីវកម្ម៖ ចំណាយចាំបាច់សម្រាប់អាជីវកម្ម
- ចំណាយពិសេស៖ ចំណាយថេរក្នុងជីវភាពរស់នៅដូចជា ការចំណាយជាប្រចាំថ្ងៃសម្រាប់អាហារ ចំណាយការសិក្សាកូន និងការចំណាយជាប្រចាំផ្ទាល់ខ្លួន
- កម្មវត្ថុនៃអាហារកាតព្វកិច្ច៖ ទឹកប្រាក់ដែលនៅសល់បន្ទាប់ពីចាត់ចែងសម្រាប់ជីវភាពប្រចាំថ្ងៃរបស់អ្នកមានកាតព្វកិច្ច និងគ្រួសារអ្នកមានកាតព្វកិច្ច
- សោហ៊ុយជីវភាពអប្បបរមា៖ ថ្លៃចំណាយទាបបំផុតដែលអាចទ្រទ្រង់ជីវភាព
- ទឹកប្រាក់នៃអាហារកាតព្វកិច្ច៖ គឺជាទឹកប្រាក់ដែលត្រូវបង់ជាក់ស្តែងរបស់អ្នកមានករណីយកិច្ចទទួលបន្ទុកអាហារកាតព្វកិច្ច ចំពោះអ្នកមានសិទ្ធិទទួលអាហារកាតព្វកិច្ច។

ដោយឡែក នៅប្រទេសកម្ពុជាមិនទាន់មានការកំណត់ចេញជារូបមន្តច្បាស់លាស់ដូចនៅប្រទេសជប៉ុនឡើយ។ ហេតុដូចនេះហើយ ទើបនៅប្រទេសកម្ពុជាទុកលទ្ធភាពឱ្យតុលាការជាអ្នកសម្រេច កំណត់ និងវាយតម្លៃអាហារកាតព្វកិច្ចទៅតាមការវិនិច្ឆ័យជាក់ស្តែង។

---

[21] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, ក្រឹត្យច្បាប់លេខ ៥៦ ក្រ, ២៦ កក្កដា ១៩៨៩, មាត្រា៧៦ (មិនទាន់និរាករណ៍)។

[22] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, ក្រឹត្យច្បាប់លេខ ៥៦ ក្រ, ២៦ កក្កដា ១៩៨៩, មាត្រា៧៧ (មិនទាន់និរាករណ៍)។

[23] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, ក្រឹត្យច្បាប់លេខ ៥៦ ក្រ, ២៦ កក្កដា ១៩៨៩, មាត្រា៧៦ (មិនទាន់និរាករណ៍)។

[24] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, ក្រឹត្យច្បាប់លេខ ៥៦ ក្រ, ២៦ កក្កដា ១៩៨៩, មាត្រា៧៦ (មិនទាន់និរាករណ៍)។

[25] អ៊ុំ ប៉ូលី, *អាហារកាតព្វកិច្ច* (ភ្នំពេញ, ២០១៧), ៦៨ និង ៦៩។

## ៤. សញ្ជាតិ និងអត្តាធីនភាព

មានចម្ងល់ជាច្រើនបានចោទឡើងថា តើក្នុងករណីដែលអនីតិជនដែលបានទទួលអត្តាធីនភាពដោយការរៀបអាពាហ៍ពិពាហ៍ ហើយបានលែងលះគ្នា តើអនីតិជននោះគួរដាក់ឱ្យនៅក្រោមអំណាចមេបារបស់ឪពុកម្ដាយវិញ ឬក៏អត្តាធីនភាពដែលទទួលបាននោះនៅមានអានុភាពដដែលឬយ៉ាងណា? តាមការកំណត់របស់ច្បាប់ អនីតិជនត្រូវបានចាត់ទុកជានីតិជនតាមរយៈការរៀបអាពាហ៍ពិពាហ៍ មានន័យអនីតិជនដែលទទួលបានអត្តាធីនភាពត្រូវបានចាត់ទុកថាបានដល់នីតិភាព[26] ពោលគឺនីតិភាពដោយអាពាហ៍ពិពាហ៍។ [27] ម្យ៉ាងទៀត បើទោះជាភាគីលែងលះគ្នាក៏ដោយ ក៏អានុភាពនៃអត្តាធីនភាពនោះមិនត្រូវបានរលត់ឡើយ ។

ដោយឡែក ចំពោះបុរសឬស្ត្រីបរទេសដែលរៀបអាពាហ៍ពិពាហ៍ជាមួយបុរសឬស្ត្រីខ្មែរវិញអាចរក្សាសញ្ជាតិខ្មែរដដែលបានឬទេ ក្រោយពេលលែងលះ?

នៅក្នុងច្បាប់ស្ដីពីសញ្ជាតិបានចែងថា បុរសឬស្ត្រីបរទេសដែលរៀបអាពាហ៍ពិពាហ៍ជាមួយស្ត្រីឬបុរសដែលជាពលរដ្ឋខ្មែរ អាចទាមទារសញ្ជាតិខ្មែរបាន លុះណាតែស្ត្រីឬបុរសនោះបានរស់នៅជាមួយគ្នារយៈពេល ៣ (បី)ឆ្នាំ ក្រោយចុះបញ្ជីអាពាហ៍ពិពាហ៍ និងបានស្នាក់នៅយ៉ាងហោចរយៈពេល ១២ (ដប់ពីរ)ខែ ពេញលេញក្នុងព្រះរាជាណាចក្រកម្ពុជា។[28]ហើយការអនុញ្ញាតិឱ្យចូលសញ្ជាតិតាមរយៈអាពាហ៍ពិពាហ៍នេះទៀតសោត ត្រូវមានការធ្វើសម្បថនៅចំពោះមុខតុលាការកំពូល។[29] យ៉ាងណាមិញ ទោះបីជាចំណងអាពាហ៍ពិពាហ៍ត្រូវរលត់ដោយសារការលែងលះ ឬដោយសារមរណភាពរបស់សហព័ទ្ធក្ដី សញ្ជាតិនេះនឹងមិនត្រូវបានដកហូតវិញបានឡើយ ដោយហេតុថា ពេលដែលទទួលបានសញ្ជាតិហើយ បុគ្គលនោះត្រូវបានរាប់ជាប្រជាពលរដ្ឋខ្មែរ[30] ហើយប្រជាពលរដ្ឋខ្មែរមិនអាចត្រូវបានដកសញ្ជាតិឡើយ[31] លើកលែងតែក្រោមគោលការណ៍ស្ម័គ្រចិត្ត។ យោងទៅតាមគោលការណ៍ស្ម័គ្រចិត្ត ការលះបង់សញ្ជាតិខ្មែរ អាចប្រព្រឹត្តិទៅបាន លុះត្រាតែបុរស ឬស្ត្រីដែលមានបំណងលះបង់នូវសញ្ជាតិនោះ ធ្វើការដាក់ពាក្យសុំលះបង់សញ្ជាតិខ្មែរ ព្រមទាំងបំពេញនូវទម្រង់បែបបទនៅក្រសួងមហាផ្ទៃ[32] និងដោយគ្មានការបង្ខិតបង្ខំ[33] ដែលមានបែបបទដូចតទៅ៖[34]

- ពាក្យសុំលះបង់សញ្ជាតិខ្មែរចំនួន ០២ (ពីរ) ច្បាប់

---

[26] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា២២។

[27] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៦៨។

[28] ច្បាប់ស្ដីពីសញ្ជាតិ, លេខ នស/រកម/០៦១៨/០០៨, ២១ មិថុនា ២០១៨, មាត្រា១១។

[29] ច្បាប់ស្ដីពីសញ្ជាតិ, លេខ នស/រកម/០៦១៨/០០៨, ២១ មិថុនា ២០១៨, មាត្រា១៦។

[30] ច្បាប់ស្ដីពីសញ្ជាតិ, លេខ នស/រកម/០៦១៨/០០៨, ២១ មិថុនា ២០១៨, មាត្រា៦។

[31] ច្បាប់ស្ដីពីសញ្ជាតិ, លេខ នស/រកម/០៦១៨/០០៨, ២១ មិថុនា ២០១៨, មាត្រា៧។

[32] អនុក្រឹត្យស្ដីពីនីតិវិធី និងលក្ខខណ្ឌនៃការសុំលះបង់សញ្ជាតិខ្មែរ, លេខ ២៨៨ អនក្រ.បក, ៣១ ឧសភា ២០១៣, មាត្រា ៤។

[33] អនុក្រឹត្យស្ដីពីនីតិវិធី និងលក្ខខណ្ឌនៃការសុំលះបង់សញ្ជាតិខ្មែរ, លេខ ២៨៨ អនក្រ.បក, ៣១ ឧសភា ២០១៣, មាត្រា ៧។

[34] អនុក្រឹត្យស្ដីពីនីតិវិធី និងលក្ខខណ្ឌនៃការសុំលះបង់សញ្ជាតិខ្មែរ, លេខ ២៨៨ អនក្រ.បក, ៣១ ឧសភា ២០១៣, មាត្រា ៣១។

- ជីវប្រវត្តិសង្ខេបរបស់សាមីខ្លួន មានស្នាមម្រាមដៃ ឈ្មោះមានបិទរូបថតទំហំ៤ ស.ម គុណ ៦ ស.ម ចំនួន ០២ (ពីរ) ច្បាប់ និងមានភ្ជាប់រូបថតចំនួន ១០ (ដប់) សន្លឹក។ រូបថតទាំងអស់ត្រូវថតថ្មី ចំពីមុខ គ្មានពាក់មួក និងគ្មានពាក់វ៉ែនតា
- សៀវភៅគ្រួសារថតចម្លង ឬសៀវភៅស្នាក់នៅថតចម្លង ០១ (មួយ) ច្បាប់
- សេចក្ដីចម្លងសំបុត្រកំណើត ឬអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរថត ឬលិខិតឆ្លងដែនថតចម្លង ០១ (មួយ) ច្បាប់
- លិខិតបញ្ជាក់សញ្ជាតិមួយផ្សេងទៀតឬលិខិតបញ្ជាក់របស់អាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសដែលសាមីខ្លួនបានដាក់ពាក្យសុំចូលសញ្ជាតិ ០១ (មួយ) ច្បាប់
- ចំពោះពលរដ្ឋខ្មែរជាបុរសឬជាស្ត្រីរស់នៅបរទេសស្របច្បាប់ ត្រូវមានលិខិតបញ្ជាក់ទីលំនៅរបស់សាមីខ្លួននៃប្រទេសនោះ ០១ (មួយ) ច្បាប់។

## ផ្នែកទី២៖ ទំនាក់ទំនងឪពុកម្ដាយជាមួយកូន

ក្នុងផ្នែកនេះនឹងផ្ដោតទៅលើអំណាចមេបា សិទ្ធិក្នុងការចិញ្ចឹមនិងអាស្រ័យទាក់ទងកូន ការទទួលខុសត្រូវចំពោះកូន។ តើការកំណត់អំណាចមេបានឹងត្រូវពិចារណាលើអ្វីខ្លះ ហើយសិទ្ធិក្នុងការចិញ្ចឹមកូននឹងមានការបែងចែក ដូចម្ដេចចំពោះភាគីដែលមិនទទួលបានអំណាចមេបា? ម្យ៉ាងទៀត តើការទទួលខុសត្រូវចំពោះកូនលើកិច្ចសន្យា និងអំពើអនីត្យានុកូលត្រូវធ្លាក់លើសហព័ទ្ធណាក្រោយពេលលែងលះ?

### កថាខណ្ឌទី១៖ អំណាចមេបា

កូនជាចំណែកនៃចំណងប្រាំប្រការក្នុងប្រពៃណីខ្មែរ ហើយក្នុងច្បាប់ក៏បានចែងពីទំនួលខុសត្រូវរបស់ឪពុកម្ដាយចំពោះកូន ទោះបីជាសហព័ទ្ធបានចែកផ្លូវគ្នាក៏ដោយ។ ប្រជាជនខ្មែរតែងតែនិយាយថា “កាត់សាច់មិនដាច់ កាត់ទឹកមិនបាន” ប្រៀបប្រដូចនឹងទំនាក់ទំនងឪពុកម្ដាយនេះឯង គឺមិនអាចកាត់ផ្ដាច់ពីឪពុកឬម្ដាយបានឡើយ។ ក្នុងជំនឿពុទ្ធសាសនាដែលមានឥទ្ធិពលលើដួងព្រលឹងខ្មែរក៏បាននិយាយពីចំណងសីលធម៌ដែលម្ដាយឪពុកមានចំពោះកូន ដោយមាតាបិតាជាជនជាទីគោរពរបស់កូន ហើយមាតាបិតាក៏ទទួលខុសត្រូវចំពោះបុត្រធីតា។[35] តែក្នុងករណីមានការលែងលះធ្វើឱ្យមានការកំណត់អំណាចមេបា និងកម្រិតសិទ្ធិមួយចំនួនចំពោះសហព័ទ្ធដែលមិនមានអំណាចមេបា។

#### ១. ការកំណត់អំណាចមេបា

អានុភាពនៃការលែងលះបណ្ដាលឱ្យមានការកំណត់អំណាចមេបាពីព្រោះអំណាចមេបាភ្ជាប់នូវកាតព្វកិច្ច និងសិទ្ធិបីបាច់ថែរក្សា និងគ្រប់គ្រងទ្រព្យសម្បត្តិកូនរហូតដល់កូនពេញនីតិភាព។ ក្រោយពេលលែងលះមានតែ

[35] ឥន្ទ ឱមសារម៉េង, *ប្រវត្តិទស្សនៈសាសនា សីលធម៌ នយោបាយ* (ភ្នំពេញ, ២០១៤), ២៧៦ និង ២៧៧។

សហព័ទ្ធម្ខាងតែប៉ុណ្ណោះមានអំណាចមេបាទៅលើកូន។ ការកំណត់អំណាចមេបាអាចធ្វើឡើងតាមការព្រមព្រៀងរវាងគូភាគីនៃការលែងលះ ឬតាមសេចក្តីសម្រេចរបស់តុលាការ។

### ១.១.ដោយការព្រមព្រៀង

ក្នុងករណីព្រមព្រៀងក្នុងការកំណត់អំណាចមេបាចំពោះកូន គូភាគីនៃការលែងលះអាចពិភាក្សាគ្នាកំណត់អ្នកណាមានអំណាចមេបា ថាតើឪពុកឬម្តាយជាអ្នកមានអំណាចមេបា។[36] បន្ទាប់ពីសម្រេចតាមការព្រមព្រៀងពីការកំណត់អំណាចមេបា គូភាគីនៃការលែងលះត្រូវដាក់ពាក្យស្នើឱ្យតុលាការដើម្បីទទួលស្គាល់ពាក្យស្នើសុំនេះ។[37] ប្រសិនបើការលែងលះនេះកើតមានក្នុងអំឡុងពេលដែលកូននៅក្នុងផ្ទៃ ឬមុនកំណើតកូន គឺអំណាចមេបាត្រូវបានទៅលើម្តាយដោយស្វ័យប្រវត្តិនៅពេលដែលកូននោះកើតមក តែទោះយ៉ាងណាក៏ដោយឪពុកឬម្តាយអាចធ្វើការព្រមព្រៀងផ្សេងពីនេះ។[38] លើសពីនេះបើភាគីដែលមានអំណាចមេបាទទួលមរណភាព នោះអំណាចមេបានឹងធ្លាក់ទៅលើសហព័ទ្ធម្ខាងទៀត។[39]

### ១.២.ដោយសេចក្តីសម្រេចរបស់តុលាការ

ក្នុងករណីដែលគូភាគីនៃការលែងលះមិនអាចកំណត់អំណាចមេបាបាន នោះតុលាការជាអ្នកកំណត់អំណាចមេបា។ អំណាចមេបានេះមិនប្រាកដថាបានទៅឪពុកឬម្តាយគ្រប់ករណីនោះទេ ព្រោះថាបើម្នាក់ថ្លោះសិទ្ធិ ហើយម្ខាងបានបោះបង់អំណាចមេបា ដូច្នេះតុលាការនឹងតែងតាំងអាណាព្យាបាលផ្សេងទៀត។

ក្នុងការគោលការណ៍សម្រេចអំណាចមេបារបស់តុលាការ គឺពិនិត្យលើឧត្តមប្រយោជន៍របស់កូន [40] ពោលគឺថាតើផលប្រយោជន៍កូនបានច្រើននៅពេលដែលកូននោះស្ថិតនៅក្រោមការគ្រប់គ្រងរបស់ឪពុកឬម្តាយ? ម្យ៉ាងទៀតនោះជាឆន្ទានុសិទ្ធិរបស់តុលាការក្នុងការសម្រេចលើការកំណត់អំណាចមេបា[41] ដោយផ្អែកលើមូលហេតុ ឬកត្តាដទៃទៀត ដូចជាយោបល់របស់កូនជាដើម[42]។

ក្នុងករណីស្មុគស្មាញក្នុងការកំណត់អំណាចមេបា នៅពេលដែលសហព័ទ្ធបានឱ្យអ្នកដទៃពពោះជំនួសបន្ទាប់មកលែងលះគ្នា ហើយកូននោះក៏បានកើត។ តើអ្នកណាជាអ្នកមានអំណាចមេបាលើកូននោះ បើមិនមានការព្រមព្រៀង? តាមមាត្រា៦៨៧ នៃក្រមរដ្ឋប្បវេណីគឺ *ស្ត្រីដែលបានសម្រាលកូន គឺជាម្តាយរបស់កូន*។ ហើយ

---

[36] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១០៣៧ កថាខណ្ឌទី១។

[37] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខ នស/រកម/០៧១០/០១៣, ០៩ មិថុនា ២០១០, ឧបសម្ព័ន្ធ ផ្នែកទី៤,៥។

[38] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១០៣៧ កថាខណ្ឌទី២។

[39] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១០៥១ កថាខណ្ឌទី៣។

[40] ច្បាប់ស្តីពីសុំកូនអន្តរប្រទេស, លេខ នស/រកម/១២០៩/០២៤, ២៣ តុលា ២០០៩, មាត្រា២ និងមាត្រា ៥ កថាខណ្ឌទី៤។ *អាចពិនិត្យបន្ថែម* ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១០៣៧ កថាខណ្ឌទី៣។ ក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ ប្រើពាក្យ *ផលប្រយោជន៍កូនជាធំ* ឯ តាមច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ ២០០៩ ប្រើពាក្យ *ឧត្តមប្រយោជន៍របស់កូន*។

[41] ច្បាប់ស្តីនីតិវិធីទាក់ទងនឹងឋានៈបុគ្គល,លេខ នស/រកម/០៦១០/០០៨, ២៦ មេសា ២០១០, មាត្រា ២២ កថាខណ្ឌទី១។

[42] ច្បាប់ស្តីនីតិវិធីទាក់ទងនឹងឋានៈបុគ្គល,លេខ នស/រកម/០៦១០/០០៨, ២៦ មេសា ២០១០, មាត្រា ២២ កថាខណ្ឌទី៤។

តាមមាត្រា១០៣៧ នៃក្រមរដ្ឋប្បវេណី បើករណីដែលឪពុកម្តាយលែងលះគ្នាមុនកំណើតកូន គឺម្តាយជាអ្នកមានអំណាចមេបា។ បើអនុវត្តតាមច្បាប់នោះស្ត្រីដែលពពោះជំនួសនឹងមានអំណាចមេបា ហើយឪពុកឬម្តាយនោះនឹងមិនមានអំណាចមេបាឡើយ។ វាមានលក្ខណៈស្មុគស្មាញក្នុងការកំណត់អំណាចមេបាឱ្យបានច្បាស់។ តើមានការសម្រេចដូចម្តេច បើឪពុកម្តាយ និងស្ត្រីពពោះ ទាមទារអំណាចមេបា? ក្នុងសេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគ ៥ គឺទុកឱ្យតុលាការនាពេលអនាគតក្នុងការសម្រេច។ បើក្រឡេកមកមើលការអនុវត្តរបស់ប្រទេសជឿនលឿនវិញនៅប្រទេសអង់គ្លេសគឺ បើមានវិវាទដូចបានរៀបរាប់ខាងលើនោះគេនឹងពិនិត្យមើល *ផលប្រយោជន៍របស់កូន* ជាធំ។ [43] ហេតុនេះទោះបីស្ត្រីនោះគ្រាន់តែពពោះជំនួសក៏ដោយ បើពិនិត្យឃើញថាកូននោះនឹងមានអនាគតល្អនៅជាមួយស្ត្រីពពោះនោះ នាំឱ្យអំណាចមេបានឹងអាចបានទៅជាលើស្ត្រីដែលពពោះជំនួសវិញ។

បើក្រឡេកមើលតាមការកំណត់ផលប្រយោជន៍ តើត្រូវពិនិត្យមើលលើកត្តាអ្វីខ្លះនោះ គឺក្នុងច្បាប់ខ្មែរពុំទាន់មានការបកស្រាយឱ្យច្បាស់ពីទំហំនៃឧត្តមប្រយោជន៍របស់កូននៅឡើយ។ តែអាចពិនិត្យមើលលើច្បាប់គ្រួសារឆ្នាំ១៩៧៥នៃប្រទេសអូស្ត្រាលីដោយមានចំណុច ដែលទាក់ទងថាតើតុលាកាសម្រេចដូចម្តេចទៅលើឧត្តមប្រយោជន៍របស់កូន។ នៅក្នុងច្បាប់នេះដែរ គឺផ្តោតទៅលើចំណុចចម្បង ២ (ពីរ)៖[44]

១. អត្ថប្រយោជន៍ដល់កូនចំពោះទំនាក់ទំនងប្រសើរ ឬភាពជិតស្និទ្ធ៖ បើកូនមានទំនាក់ទំនងល្អជាមួយម្តាយជាងឪពុក ហើយកូនទទួលបានផលប្រយោជន៍នាពេលខាងមុខ នោះតុលាការអាចសម្រេចផ្តល់អំណាចមេបាទៅឱ្យខាងម្តាយ។ បន្ថែមពីលើចំណុចនេះ តុលាការនៅសហរដ្ឋអាមេរិក ដែលក្នុងនោះមាន១៥ រដ្ឋ និង ១ សង្កាត់[45] បានពិចារណាលើកត្តានេះ ព្រោះវាជាកត្តាចម្បងមួយផងដែរ ដែលនិយាយអំពីទំនាក់ទំនងផ្លូវចិត្ត និងទំនាក់ទំនងរវាងកូននិងឪពុកម្តាយ បងប្អូន ក្រុមគ្រួសារ និងសមាជិកគ្រួសារ ឬអ្នកថែទាំផ្សេងទៀត។

២. តម្រូវការដើម្បីការពារកុមារពីការធ្វើបាបផ្លូវកាយ ឬផ្លូវចិត្ត៖ កូនដែលទទួលរងឬប៉ះពាល់ ការរំលោភបំពាន ការមិនយកចិត្តទុកដាក់ ឬអំពើហិង្សាក្នុងគ្រួសារ គឺត្រូវបានធានាការពារពីការធ្វើបាបដោយតុលាការ។

---

[43] *Surrogacy: legal rights of parents and surrogates*. GOV.UK. n.d., *អាចចូលមើលតាម៖* https://www.gov.uk/legal-rights-when-using-surrogates-and-donors។

[44] ច្បាប់គ្រួសារឆ្នាំ១៩៧៥ នៃប្រទេសអូស្ត្រាលី, លេខ ៥៣ នៃឆ្នាំ១៩៧៥, ១២ មិថុនា ១៩៧៥, ផ្នែក ៦០ cc ។ *អាចចូលមើលតាម៖* https://www.legislation.gov.au/Details/C2022C00126 ។

[45] Connecticut, Delaware, Florida, Hawaii, Illinois, Kansas, Maryland, Massachusetts, Michigan, North Dakota, Ohio, Oregon, Tennessee, Vermont, Virginia and District of Columbia ( Washington D.C) *អាចមើលបន្ថែមតាម៖* https://www.childwelfare.gov/pubpdfs/best_interest.pdf ។

តុលាការនៅសហរដ្ឋអាមេរិក[46]ធ្វើការពិនិត្យនិងពិចារណាទៅលើសុខភាពផ្លូវចិត្ត និងផ្លូវកាយរបស់ឪពុកម្តាយថែមទៀត មុនពេលសម្រេចប្រគល់អំណាចមេបាទៅឱ្យភាគីណាមួយ។

បន្ថែមពីនេះ ច្បាប់នៃប្រទេសអូស្ត្រាលី ក៏បន្ថែមកត្តាពិចារណាផ្សេងទៀតដូចជា៖

- ទំនាក់ទំនងរបស់កុមារជាមួយឪពុកម្តាយម្នាក់ៗ និងមនុស្សផ្សេងទៀត រួមទាំងជីដូនជីតា ឬសាច់ញាតិផ្សេងទៀតរបស់កុមារ
- ទស្សនៈណាមួយដែលបង្ហាញដោយកុមារ និងកត្តាពាក់ព័ន្ធ ដូចជាភាពចាស់ទុំ ឬកម្រិតនៃការយល់ដឹងរបស់ពួកគេ
- ឪពុកម្តាយម្នាក់ៗមានឆន្ទៈ ក្នុងការចូលរួមសម្រេចចិត្តអំពីបញ្ហាសំខាន់ៗនាថ្ងៃខាងមុខ រួមទាំងពេលវេលា ដែលឪពុកម្តាយម្នាក់ៗចំណាយជាមួយកូន ឬទាក់ទងជាមួយកូន
- សមត្ថភាពរបស់ឪពុកម្តាយជាមួយកូនម្នាក់ៗ ឬសាច់ញាតិរបស់ឪពុកម្តាយម្នាក់ៗក្នុងការផ្តល់តម្រូវការរបស់កូន រួមទាំងតម្រូវការផ្នែកសតិអារម្មណ៍ និងចំណេះដឹង
- ភាពចាស់ទុំ ភេទ របៀបរស់នៅ និងប្រវត្តិរូប (រួមទាំងវប្បធម៌ និងប្រពៃណី) របស់កុមារ និងឪពុកម្តាយរបស់កុមារ និងលក្ខណៈផ្សេងទៀតរបស់កុមារដែលតុលាការគិតថាពាក់ព័ន្ធ
- អាកប្បកិរិយាចំពោះកូន និងទំនួលខុសត្រូវនៃភាពជាឪពុកម្តាយដែលបង្ហាញដោយឪពុក ឬម្តាយរបស់កូន
- វិសាលភាពដែលឪពុកម្តាយរបស់កុមារម្នាក់ៗបាន ឬមិនបានក្នុងការបំពេញកាតព្វកិច្ចក្នុងការថែរក្សាកូន។
- វត្តមានអំពើហិង្សាក្នុងគ្រួសារ
- តុលាការអាចពិនិត្យមើលលើកត្តាដទៃទៀត ឬស្ថានភាពដែលពាក់ព័ន្ធក្នុងការសម្រេចពីផលប្រយោជន៍របស់កូន។

សរុបមកវិញ ការសម្រេចរបស់តុលាការគឺត្រូវឈរលើគោលការណ៍ឧត្តមប្រយោជន៍របស់កូនមានន័យថាតុលាការត្រូវពិនិត្យលើប្រយោជន៍កូនជាធំ មិនត្រឹមតែបច្ចុប្បន្នភាពនោះទេ តែតុលាការក៏ត្រូវពិចារណាដល់ប្រយោជន៍នាពេលខាងមុខផងដែរ។ ប្រយោជន៍នេះមិនត្រឹមគិតពីការចិញ្ចឹមបីបាច់ផ្គត់ផ្គង់កូនទេ តែជាប្រយោជន៍ផ្នែកសតិអារម្មណ៍ និងចំណេះដឹងរបស់កូន ដើម្បីក្លាយជាកូនល្អ សិស្សល្អ និងពលរដ្ឋល្អរបស់ប្រទេសស្របតាមរដ្ឋធម្មនុញ្ញរបស់ប្រទេសកម្ពុជា។

[46] Delaware, Georgia, Kentucky, Michigan, North Dakota, South Dakota, Tennessee, Texas, Virginia, and District of Columbia ( Washington D.C) *អាចមើលបន្ថែមតាម* ៖ https://www.childwelfare.gov/pubpdfs/best_interest.pdf ។

## ២. សិទ្ធិក្នុងការចិញ្ចឹម និងអាស្រ័យទំនាក់ទំនងកូន

ចំពោះជីវិតជាចំណងអាពាហ៍ពិពាហ៍ត្រូវបានកាត់ផ្តាច់ និងមានការកំណត់ពីអំណាចមេបាក៏ដោយ ក៏ទំនាក់ទំនងរវាងឪពុកម្តាយនិងកូនមិនអាចកាត់ផ្តាច់ពីគ្នាបានទេ។ សហព័ទ្ធដែលមានសិទ្ធិចិញ្ចឹមកូនមិនត្រូវរារាំងដល់សហព័ទ្ធដែលមិនបានរស់នៅជាមួយកូនឡើយ។ ម៉្យាងទៀត ឪពុកឬម្តាយដែលមិនមានអំណាចមេបាក៏នៅតែមានកាតព្វកិច្ចផ្តល់អាហារកិច្ចចំពោះកូន ក្នុងការថែរក្សាកូន និងចិញ្ចឹមកូន។

### ២.១. ករណីយកិច្ចឪពុក ឬម្តាយទទួលបានអំណាចមេបា

អ្នកមានអំណាចមេបាមានសិទ្ធិ និងករណីយកិច្ចអប់រំកូន[47] និងត្រូវមានកាតព្វកិច្ចថែរក្សា និងអប់រំកូនឱ្យទៅជាពលរដ្ឋល្អ [48]។ ក្នុងច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារ មាត្រា១ ក៏មិនខុសពីការចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាដែរ គឺបានបង្ហាញពីគោលគំនិតដែលដាក់នូវបទបញ្ញា និងការពារគ្រួសារ ជីវិតគ្រួសារក្នុងនោះមានការជំរុញការបណ្តុះបណ្តាលសីលធម៌ ការអប់រំកូន ឱ្យទៅជាពលរដ្ឋល្អក្នុងសង្គម និងមានមនសិការស្នេហាជាតិ។

ទីស្នាក់របស់កូនក៏ជាផ្នែកក្នុងការចិញ្ចឹមបីបាច់កូន ហើយវាត្រូវបានកំណត់នៅទីកន្លែងដែលអ្នកមានអំណាចមេបាបានកំណត់។[49] អ្នកមានអំណាចមេបាអាចធ្វើការទាមទារឱ្យតតិយជនដែលមិនព្រមប្រគល់កូនឱ្យប្រគល់កូនបាន[50] និងអាចទាមទារឱ្យឪពុក ឬម្តាយដែលពុំមានអំណាចមេបាប្រគល់កូនបាន[51]។

ការប្រៀនប្រដៅកូន ឬនិយាយដោយសាមញ្ញ គឺការដាក់ទណ្ឌកម្ម។ បើតាមច្បាប់ ឪពុកម្តាយមិនត្រូវធ្វើបាបកូនឡើយ។[52] មានតែអ្នកមានអំណាចមេបាប៉ុណ្ណោះទើបអាចដាក់ទណ្ឌកម្មកូនដោយខ្លួនឯង នៅក្នុងទំហំដែលចាំបាច់បាន។[53] តាមស្មារតីក្រមរដ្ឋប្បវេណីចាស់ដែលបានផ្តល់នូវគតិទៅលើការដាក់ទណ្ឌកម្មលើកូនដោយបានបន្ថែមត្រង់ថាឪពុកម្តាយមានសិទ្ធិដាក់ទណ្ឌកម្មលើរូបរាងកាយកូនបាន ក៏ប៉ុន្តែដោយព្រហ្មវិហារធម៌ តែក្នុងករណីដែលការដាក់ទណ្ឌកម្មនោះធ្វើឱ្យមានរបួស ស្លាកស្នាម ឬធ្វើឱ្យខូចសុខភាព នោះវាក្លាយជាទណ្ឌកម្មហួសប្រមាណដែលអាចឈានទៅជាទោស។ [54]

---

[47] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១០៤៣។

[48] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ២១ កញ្ញា ១៩៩៣, មាត្រា ៤៧។

[49] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១០៤៤។

[50] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១០៤៧ កថាខណ្ឌទី១។

[51] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១០៤៧ កថាខណ្ឌទី២។

[52] ច្បាប់ស្តីអាពាហ៍ពិពាហ៍និងគ្រួសារ, ក្រឹត្យច្បាប់លេខ ៥៦ ក្រ, ២៦ កក្កដា ១៩៨៩, មាត្រា ១១៦

[53] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១០៤៥។

[54] ក្រមរដ្ឋប្បវេណីចាស់ ឆ្នាំ១៩៦៧, មាត្រា ៣៤៩ និង ៣៥០។

## ២.២. ករណីយកិច្ចឪពុក ឬម្ដាយមិនទទួលបានអំណាចមេបា

ឪពុក ឬម្ដាយដែលពុំមានអំណាចមេបា ក្រោយពេលលែងលះគ្នា មានសិទ្ធិចូលជួបនិងប្រាស្រ័យទាក់ទងជាមួយកូន និងទទួលបន្ទុកករណីយកិច្ចលើសោហ៊ុយដែលចាំបាច់ ដើម្បីគ្រប់គ្រងថែរក្សាកូន។ ជាគោលការណ៍ សិទ្ធិ និងករណីយកិច្ចនេះធ្វើឡើងដោយផ្អែកតាមការពិភាក្សារបស់ឪពុកឬម្ដាយ តែបើមិនអាចពិភាក្សាបានទេ តុលាការជាអ្នកកំណត់តាមការទាមទាររបស់ឪពុកឬម្ដាយ។

### ក.សិទ្ធិចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូន

ភាគីដែលមិនបានរក្សាកូន មានសិទ្ធិទៅសួរសុខទុក្ខកូន ហើយភាគីបានអំណាចមេបាត្រូវបង្កលក្ខណៈងាយស្រួលគ្រប់បែបយ៉ាងដល់ភាគីម្ខាងទៀត។[55] សិទ្ធិជួបប្រាស្រ័យទាក់ទងកូន គឺជាសិទ្ធិដែលត្រូវផ្ដល់ឱ្យឪពុក ឬម្ដាយដែលពុំមានអំណាចមេបា អាចធ្វើទំនាក់ទំនង តាមដានស្ថានភាពរស់នៅរបស់កូន។ តុលាការត្រូវកំណត់អំពីវិធីជួបប្រាស្រ័យទាក់ទងកូន ដែលមានលក្ខណៈបត់បែន និងងាយស្រួលក្នុងការអនុវត្ត បើមិនមានការព្រមព្រៀងរវាងសហព័ទ្ធដែលបានលែងលះ។ ហើយខ្លឹមសារនៃសេចក្ដីសម្រេចពីតុលាការនេះគឺ មានលក្ខណៈចាប់បង្ខំ។ វិធីក្នុងការជួបប្រាស្រ័យកូនអាចកំណត់ពី៖[56]

- ចំនួនដង
- រយៈពេល
- ម៉ោងនៃការជួប
- ទីកន្លែងជួប
- វិធីប្រគល់កូន ជាដើម។

ពាក់ព័ន្ធនឹងការសម្រេចសេចក្ដីពីការចូលជួបនិងប្រាស្រ័យទាក់ទង ក្រមរដ្ឋប្បវេណីតម្រូវឱ្យតុលាការធ្វើការពិចារណាលើផលប្រយោជន៍របស់កូនជាអាទិភាព។

### ខ. ករណីយកិច្ចអាហារកិច្ចចំពោះកូន

ទោះបីឪពុក ឬម្ដាយណាមួយមិនទទួលបានអំណាចមេបា ក៏សហព័ទ្ធម្ខាងទៀតត្រូវមានអាហារកាតព្វកិច្ច (សោហ៊ុយចាំបាច់ដើម្បីចិញ្ចឹមកូន) ដែលជាកិច្ចក្នុងការចិញ្ចឹមកូនដែរ ព្រោះវាជា*កិច្ចការពារប្រយោជន៍កូន*[57]។ បើឪពុក ឬម្ដាយបានស្រុះស្រួលគ្នាយល់ព្រមជួយផ្ដល់សោហ៊ុយអប់រំ ថែរក្សាកូនទៅតាមកម្រិតលទ្ធភាពខ្លួន នោះមិនមានភាពស្មុគស្មាញឡើយ ពោលគឺអនុវត្តតាមការសម្រេចរបស់គូភាគីនៃការលែងលះ។[58] ភាគីដែលមានកាតព្វកិច្ចផ្ដល់អាហារកិច្ចត្រូវផ្ដល់ឱ្យកូនរហូតដល់កូននោះមាននីតិភាព។ ក្នុងករណីដែលមិនអាចព្រមព្រៀង

---

[55] ច្បាប់ស្ដីអាពាហ៍ពិពាហ៍និងគ្រួសារ, ក្រឹត្យច្បាប់លេខ ៥៦ ក្រ, ២៦ កក្កដា ១៩៨៩, មាត្រា ៧៥។

[56] ក្រុមមេធាវីកម្ពុជាសហប្រតិបត្តិការអន្តរជាតិ, *យល់ដឹងផ្នែកច្បាប់៖ ការកំណត់អំពីសិទ្ធិជួបប្រាស្រ័យទាក់ទងកូនដោយតុលាការ,* ១១ កុម្ភៈ ២០២១, http://ciclg.com/cn/article/250 (ចូលមើល ១៤ មិថុនា ២០២២)

[57] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១០៣៧ ។

[58] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៤១ កថាខណ្ឌទី១។

លើការកម្រិត ឬរបៀបនៃការផ្គត់ផ្គង់អាហារកាតព្វកិច្ច តុលាការនឹងជាអ្នកកំណត់ពីកម្រិត ឬរបៀបនៃការផ្គត់ផ្គង់កូនទៅតាម *សេចក្តីត្រូវការចាំបាច់ក្នុងជីវភាពរស់នៅរបស់ជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច លទ្ធភាពទ្រព្យធនរបស់ជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច និងស្ថានភាពផ្សេងទៀតទាំងអស់* ។[59]

ការសម្រេចរបស់តុលាការគឺ មិនអាចធ្វើការសម្រេចដោយប៉ះពាល់ដល់ជីវភាពជនដែលមានករណីយកិច្ចផ្តល់អាហារកាតព្វកិច្ចឡើយ។ ក្នុងច្បាប់ក៏មិនបានដាក់កំហិតខ្លាំងលើការកំណត់អាហារកិច្ចឡើយ។ បើក្រោយពីការសម្រេចរបស់តុលាការហើយ នោះភាគីទាំងពីរក៏អាចលុបចោលកម្រិតអាហារកិច្ចដោយការពិភាក្សាគ្នាទាំងសងខាង ក្នុងករណីមានការប្រែប្រួលទៅតាមស្ថានភាពជាក់ស្តែង ដែលប៉ះពាល់ដល់ការផ្តល់អាហារកិច្ច។[60] ប៉ុន្តែបើជនដែលមានករណីយកិច្ចក្នុងការផ្តល់អាហារកិច្ចបែរជាមិនអនុវត្តក្នុងរយៈពេល ០២ (ពីរ)ខែ នោះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ០១ (មួយ) ខែ ទៅ ០១ (មួយ) ឆ្នាំ និងពិន័យប្រាក់ពី ១០០,០០០ (មួយសែន) រៀល ទៅ ២,០០០,០០០ (ពីរលាន) រៀល។[61] ឪពុក ឬម្តាយដែលពុំមានអំណាចមេបា ក្រោយពេលលែងលះមានសិទ្ធិក្នុងការជួបនិងប្រាស្រ័យទាក់ទងកូន តែត្រូវស្ថិតក្រោមការពិភាក្សានិងការកំណត់ពីការជួបកូន។ តែទោះជាយ៉ាងណា បើមិនមានការឯកភាពក្នុងការប្រាស្រ័យទាក់ទងកូនទេ នោះតុលាការត្រូវកំណត់ពីរបៀបទាក់ទងកូន។[62]

### គ. សិទ្ធិទាមទារអំណាចមេបាមកវិញ

អ្នកមានអំណាចមេបា អាចទាមទារឱ្យឪពុកឬម្តាយដែលពុំមានអំណាចមេបាប្រគល់កូនបាន។[63] តែក្នុងករណីដែលឪពុក ឬម្តាយអនុវត្តអំណាចមេបាមិនបានល្អ ឬធ្វេសប្រហែសក្នុងការបំពេញករណីយកិច្ចក្នុងនាមជាអ្នកមានអំណាចមេបា នោះអ្នកពុំមានអំណាចមេបាអាចប្តឹងដកហូតអំណាចមេបាមកវិញបាន។ ក្នុងក្រមរដ្ឋប្បវេណីបច្ចុប្បន្ន ផ្នែកទី៤ ការព្យួរ និងដកហូតអំណាចមេបា មិនបានចែង ឬរៀបរាប់មូលហេតុណាដែលអាចឱ្យភាគីម្ខាងទាមទារអំណាចមេបាមកវិញបាន តែបើពិនិត្យតាមច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារមាត្រា ១១៩ គឺអាចមានករណីដូចខាងក្រោមដែលអាចជាមូលហេតុនៃការដកហូតអំណាចមេបា និងជាហេតុផលឱ្យភាគីម្ខាងទៀតអាចទាមទារមកវិញ៖

- ឪពុក ឬម្តាយមានការខ្វះខាតក្នុងការអប់រំ
- ឪពុក ឬម្តាយ ប្រើអំណាចដោយរំលោភទៅលើកូន ដោយប្រើឧបាយកលផ្សេងៗដើម្បីបង្ខំកូនឱ្យប្រព្រឹត្តបទល្មើស ឬអំពើណាមួយប៉ះពាល់ដល់សង្គម
- ឪពុក ឬម្តាយវាយធ្វើបាបកូនឥតត្រាប្រណី

[59] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៥២។

[60] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៥៣។

[61] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ១២ តុលា ២០០៩, មាត្រា ៣២៥។

[62] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១០៥០ កថាខណ្ឌទី៥។

[63] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១០៥៧ កថាខណ្ឌទី២។

- ឪពុក ឬម្ដាយ ប្រព្រឹត្តផ្ទុយពីសីលធម៌បណ្ដាលឱ្យមានឥទ្ធិពលអាក្រក់ដល់កូន។

## កថាខណ្ឌទី២៖ ការទទួលខុសត្រូវចំពោះទង្វើកូន

ទំនួលខុសត្រូវក្នុងច្បាប់ទាក់ទងឪពុកម្ដាយចំពោះកូន ក៏មិនខុសពីទំនួលខុសត្រូវតាមន័យពុទ្ធសាសនា និងសីលធម៌ឡើយ មានដូចជាការចិញ្ចឹមបីបាច់ដែលមានការផ្ដល់ជម្រក អាហារូបត្ថម្ភ ការមើលថែពេលកូនមានជំងឺ ការបញ្ជូនកូនទៅសាលារៀនជាដើម។ ទោះបីចំណងអាពាហ៍ពិពាហ៍ត្រូវបាននត្ថិភាពក៏ដោយ ក៏មិនមានន័យថាកាតព្វកិច្ចរបស់ឪពុកឬម្ដាយដែលមានអំណាចមេបាចំពោះកូនត្រូវបានបាត់បង់ឡើយ។ តែយ៉ាងណាការគ្រប់គ្រងចម្បងត្រូវបានធ្លាក់លើសហព័ទ្ធដែលមានអំណាចមេបាក្នុងករណីដែលចំណងអាពាហ៍ពិពាហ៍ត្រូវបានផ្ដាច់។

### ១. ការទទួលខុសត្រូវក្នុងកិច្ចសន្យា

កិច្ចសន្យាគឺជា *ការព្រមព្រៀងគ្នារវាងបុគ្គលពីរ ឬច្រើននាក់ដើម្បីបង្កើត កែប្រែ ឬរំលត់នូវកាតព្វកិច្ច*។[64] ហើយកាតព្វកិច្ចក្នុងកិច្ចសន្យាជា *ទំនាក់ទំនងគតិយុត្តដែលចងភ្ជាប់បុគ្គលពីរនាក់ដោយឱ្យបុគ្គលម្នាក់ដែលបានកំណត់ (កូនបំណុល) មានករណីយកិច្ចចំពោះបុគ្គលដែលបានកំណត់ម្នាក់ទៀត (ម្ចាស់បំណុល)* ។ ក្នុងបញ្ញត្តិច្បាប់បានការពារចំពោះជនដែលមានកម្រិតសមត្ថភាពខាងឆន្ទៈ ដោយធ្វើការលុបចោលនូវសកម្មភាពរបស់បុគ្គលដែលខ្វះសមត្ថភាពខាងឆន្ទៈ។*សកម្មភាពដែលភាគីបានធ្វើឡើងនៅក្នុងស្ថានភាពដែលខ្លួនមិនអាចយល់ដឹង និងវិនិច្ឆ័យបានអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនអាចលុបចោលបាន*។ [65] ជនដែលមានអាយុក្រោម ១៨ឆ្នាំ ត្រូវបានកំណត់ថាជាអនីតិជនក្នុងបរិបទនៃប្រទេសកម្ពុជា។[66] អនីតិជនជាជនដែលមានកម្រិតសមត្ថភាពខាងឆន្ទៈ ហេតុនេះឪពុកម្ដាយដែលមានអំណាចមេបាក្រោយពេលលែងលះ មានសិទ្ធិសម្រេចលើការចុះកិច្ចសន្យានានារបស់កូន និងធ្វើការលុបចោលបាន។[67]

#### ក. ករណីអនីតិជនចុះកិច្ចសន្យាអេឡិចត្រូនិច

ក្នុងបញ្ញត្តិច្បាប់ចែងច្បាស់ពីសមត្ថភាពខាងឆន្ទៈរបស់អនីតិជន ហើយអនីតិជនមិនអាចបង្កើតកិច្ចសន្យាបានឡើយ បើគ្មានការយល់ព្រមពីឪពុកម្ដាយដែលមានអំណាចមេបា។ តែក្នុងសម័យជឿនលឿនផ្នែកបច្ចេក-វិទ្យា ការបង្កើតកិច្ចសន្យាមិនបានធ្វើឡើងដោយផ្ទាល់នោះទេ ហើយកាន់តែស្មុគស្មាញនោះគឺ មិនបានដឹងថាជនដែលបង្កើតកិច្ចសន្យានោះជាជនមានសមត្ថភាពខាងឆន្ទៈដែរឬទេ? ក្នុងប្រព័ន្ធពាណិជ្ជកម្មអេឡិចត្រូនិចអ្នកគ្រាន់តែប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិតដើម្បីទិញឥវ៉ាន់។ ក្នុងករណីដែលកូនបានក្លែងព័ត៌មានខ្លួន ហើយប្រើប្រាស់កាតធនាគារឪពុកម្ដាយដើម្បីប្រតិបត្តិការទិញតាមប្រព័ន្ធអនឡាញ ឬកូនបានយកទូរស័ព្ទឪពុកម្ដាយដើម្បីទិញ

[64] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៣០៧។

[65] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១៤។

[66] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១៧។

[67] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១៨។

ទំនិញតាមអនឡាញ តើឪពុកឬម្តាយមានសិទ្ធិក្នុងការលុបចោលកិច្ចសន្យាទិញតាមប្រព័ន្ធអេឡិចត្រូនិចដែរឬទេ?

មានករណីសិក្សាជាច្រើននៅក្នុងសហរដ្ឋអាមេរិក ដែលឪពុកម្តាយបានដាក់ពាក្យបណ្តឹងទៅកាន់ក្រុមហ៊ុនអនឡាញដូចជា Google, Apple, Amazon ជាដើម ទាក់ទិននឹងកូនប្រើប្រាស់កាតធនាគារឪពុកម្តាយដើម្បីទិញកម្មវិធីហ្គេមដោយចំណាយលុយរាប់ពាន់ដុល្លា។ ជាឧទាហរណ៍ ក្នុងសំណុំរឿងក្រុមហ៊ុន Apple បានទទួលបណ្តឹងរាប់ម៉ឺនពីឪពុកម្តាយ អំពីការទិញក្នុងកម្មវិធីដោយគ្មានការអនុញ្ញាតរបស់កូនពួកគេ។ គួរកត់សម្គាល់ថា ក្មេងម្នាក់បានចំណាយប្រាក់ ២,៦០០ (ពីរពាន់ប្រាំមួយរយ) ដុល្លាសហរដ្ឋអាមេរិកលើការទិញកម្មវិធីហ្គេម “Tap Pet Hotel”។ [68] ក្រោមការដោះស្រាយរបស់គណៈកម្មការពាណិជ្ជកម្មសហព័ន្ធ (Federal Trade Commission) ក៏បានសម្រេចឱ្យមានការកែតម្រូវ ដោយតម្រូវឱ្យមានការអនុញ្ញាតច្បាស់លាស់ពីឪពុកម្តាយជាមុនសិន មុនធ្វើការបញ្ជាទិញតាមប្រព័ន្ធអេឡិចត្រូនិក ហើយក៏បង្គាប់ឱ្យសងទៅឪពុកម្តាយវិញ។ ប្រធានគណៈកម្មការពាណិជ្ជកម្មសហព័ន្ធ លោកស្រី Edith Ramirez បាននិយាយថា “អ្នកមិនអាចគិតថ្លៃពីអតិថិជនសម្រាប់ការទិញដែលពួកគេមិនបានអនុញ្ញាតនោះទេ”។ នៅក្នុងសហរដ្ឋអាមេរិក បើមានករណីដូចខាងលើគឺឪពុកម្តាយមិនមានការទទួលខុសត្រូវឡើយ តែត្រូវធ្វើនីតិវិធីក្នុងការទាមទារប្រាក់មកវិញគឺ៖

(១) ទាក់ទងទៅពាណិជ្ជករ ឬអ្នកដែលលក់ទំនិញ ឬសេវានោះ

(២) ទាក់ទងទៅខាងធនាគារដើម្បីបញ្ជាក់ពីការទិញដោយគ្មានការអនុញ្ញាត

(៣) ទាក់ទងទៅគណៈកម្មការពាណិជ្ជកម្មសហព័ន្ធ (Federal Trade Commission)

ក្នុងច្បាប់កម្ពុជា ទោះមិនបានលំអិតពីកិច្ចសន្យាតាមប្រព័ន្ធអេឡិចត្រូនិក តែអាចពិនិត្យមើលគោលការណ៍ទូទៅក្នុងការបង្កើតកិច្ចសន្យា ដែលក្នុងនោះសមត្ថភាពខាងឆន្ទៈជាផ្នែកមួយសំខាន់ ដើម្បីបង្កើតកិច្ចសន្យាដែលមានសុពលភាព។ បើមិនដូច្នេះនឹងមានការរំលាយកិច្ចសន្យាដោយមូលហេតុទាក់ទងនឹងសមត្ថភាពខាងឆន្ទៈ។ របប គតិយុត្តិដែលបានកំណត់ពីមូលហេតុនេះ គឺជារបបការពារកុំឱ្យមានការទទួលរងការខូចខាតលើភាគីដែលមានកម្រិតសមត្ថភាពខាងឆន្ទៈ ដោយការកេងចំណេញព្រោះអនីតិជនមិនមានសមត្ថភាពក្នុងការវិនិច្ឆ័យបានត្រឹមត្រូវ។ អនីតិជនត្រូវចាត់ទុកជាជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព ប៉ុន្តែប្រសិនបើជនដែលត្រូវបានកម្រិតសមត្ថភាពបានប្រើប្រាស់មធ្យោបាយឆបោក ដើម្បីឱ្យគេជឿជាក់ថាខ្លួនជាជនមានសមត្ថភាព នោះកិច្ចសន្យាមិនអាចលុបចោលវិញបានទេ។[69] ហេតុនេះគេអាចនិយាយបានថា ទោះបីអនីតិជនបានចុះកិច្ចសន្យាតាមប្រព័ន្ធអេឡិចត្រូនិកក៏ដោយ ក៏ឪពុកឬម្តាយដែលមានអំណាចមេបាអាចធ្វើការលុបចោលបានដែរ ព្រោះតាមចរិតលក្ខណៈនៃច្បាប់ គឺការពារប្រយោជន៍ជនដែលមានកម្រិតសមត្ថភាព។

---

[68] Alexandria White. "Who's responsible for your kids' unauthorized charges?." CNBC. 26 January 2021, https://www.cnbc.com/select/whos-responsible-for-kids-unauthorized-credit-card-charges/.

[69] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៣៣។

### ខ. ករណីអនីតិជនចុះកិច្ចសន្យាទិញបរិភោគហួសប្រមាណ

ក្នុងច្បាប់មិនបានការពារអនីតិជនក្នុងការបង្កើតកិច្ចសន្យាគ្រប់ប្រភេទឡើយ បើការបង្កើតកិច្ចសន្យានោះធ្វើឡើងដើម្បីជីវភាពប្រចាំថ្ងៃដូចជា ការទិញរបស់របរប្រើប្រាស់ប្រចាំថ្ងៃ គ្រឿងបរិភោគជាដើម។ ប៉ុន្តែបញ្ហានៅតែកើតមាន ឧទាហរណ៍ថាអនីតិជនកម្ម៉ង់បាយសាច់ជ្រូកតាមអនឡាញចំនួន ២០ប្រអប់ដែលវាជាចំនួនលើសពីតម្រូវការប្រចាំថ្ងៃ តើឪពុកឬម្ដាយមានសិទ្ធិលុបចោលដែរឬទេ?

បើយោងតាមស្មារតីច្បាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកគឺ មិនបានកំណត់ពីអាយុអតិថិជនឡើយ ហេតុនេះអនីតិជនក៏អាចក្លាយជាអតិថិជនស្របតាមច្បាប់នេះដែរ។ តែក្នុងមាត្រា ៤៨ នៃច្បាប់នេះបានបង្ហាញពីការទទួលខុសត្រូវរបស់អតិថិជន។ ទោះបីច្បាប់នេះមិនបាននិយាយពីកម្រិតសមត្ថភាពរបស់អតិថិជនឱ្យបានលម្អិតក៏ដោយ តែប្រហែលគេអាចត្រឡប់ទៅពិនិត្យមើលក្រមរដ្ឋប្បវេណីចំពោះការបង្កើតកិច្ចសន្យាបរិភោគប្រចាំថ្ងៃ។ ក្នុងច្បាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនេះបាននិយាយ ពីទំនួលខុសត្រូវរបស់អតិថិជនដោយអតិថិជនត្រូវជូនដំណឹងដល់បុគ្គលដែលផ្ដល់សេវាទូទាត់អំពីប្រតិបត្តិការដែលកើតឡើងដោយគ្មានការអនុញ្ញាតកំហុសឆ្គង ឬភាពមិនត្រឹមត្រូវផ្សេងទៀត នៅក្នុងគណនីខ្លួន[70]។ ក្នុងប្រយោគដែលនិយាយអំពី “[...] *អតិថិជនត្រូវជូនដំណឹងដល់បុគ្គលដែល ផ្ដល់សេវាទូទាត់អំពីប្រតិបត្តិការដែលកើតឡើងដោយគ្មានការអនុញ្ញាត ...*” អាចបង្ហាញថាឪពុកម្ដាយដែលជំនួសឱ្យកូនមានសិទ្ធិជូនដំណឹងអំពីការលុបចោលការទិញទំនិញ ឬការបរិភោគដែលមានតម្លៃហួសហេតុ ឬខុសប្រក្រតី ចំពោះប្រតិបត្តិការដោយគ្មានការអនុញ្ញាតពីឪពុកម្ដាយ។ ក្នុងច្បាប់ដដែលនេះក៏មិនបានដាក់បន្ទុកតែអតិថិជនឡើយ គឺច្បាប់នេះបានចែងពីទំនួលខុសត្រូវរបស់បុគ្គលដែលផ្ដល់សេវាទូទាត់។[71] មុនពេលធ្វើប្រតិបត្តិការផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក បុគ្គលផ្ដល់សេវាត្រូវបញ្ជាក់ឱ្យបានច្បាស់ពីអត្តសញ្ញាណរបស់អតិថិជន និងផ្ទៀងផ្ទាត់ឡើងវិញនូវភាពត្រឹមត្រូវនៃការផ្ទេរប្រាក់តាមប្រព័ន្ធអេឡិច-ត្រូនិក។ ក្នុងឧទាហរណ៍ជាក់ស្ដែង ទាក់ទងទៅនឹងការកម្ម៉ង់អាហារតាមក្រុមហ៊ុនដឹកជញ្ជូនអាហារ បន្ទាប់ពីធ្វើការដាក់កម្ម៉ង់តាមប្រព័ន្ធអេឡិចត្រូនិកហើយ ក្រុមហ៊ុននឹងធ្វើការបញ្ជាក់អំពីចំនួននិងមុខទំនិញ ឬម្ហូប ដើម្បីធានាថាការកម្ម៉ង់នោះមិនបានធ្វើឡើងដោយកំហុស ឬគ្មានការអនុញ្ញាតឡើយ។ ហេតុនេះគឺមានទំនួលខុសត្រូវទាំងសងខាង ហើយឪពុកម្ដាយអាចធ្វើការលុបចោលការទិញទំនិញឬអាហារដែលមានបរិមាណហួសហេតុ ឬតម្លៃច្រើនហួសតាមប្រព័ន្ធអេឡិចត្រូនិក ដែលកូនជាអនីតិជនបានបង្កើត។

### ២. ការទទួលខុសត្រូវអំពើអនីត្យានុកូលចំពោះទង្វើអនីតិជន

អំពើអនីត្យានុកូលជាទូទៅ ជាអំពើដែលបំពានច្បាប់នូវសិទ្ធិ ឬផលប្រយោជន៍អ្នកដទៃដោយចំណុះនូវលក្ខខណ្ឌដូចជា ទំនាក់ទំនងនៃហេតុផលរវាងអំពើរបស់អ្នកប្រព្រឹត្តអំពើបំពាន និងការកើតឡើងនៃការខូចខាត

[70] ច្បាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, លេខ នស/រកម/១១១៩/០១៧, ៨ តុលា ២០១៩, មាត្រា ៤៨ កថាខណ្ឌ ១។
[71] ច្បាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, លេខ នស/រកម/១១១៩/០១៧, ៨ តុលា ២០១៩, មាត្រា ៤៧។

និងការខូចខាតដែលកើតមានឡើងលើជនរងគ្រោះ។[72] អំពើអនីត្យានុកូលបែងចែកជា ២ (ពីរ)គឺ អំពើដែលកើតពីកំហុសចេតនា និងអំពើដែលកើតពីកំហុសអចេតនា។[73] ក្នុងករណីដែលកូនជាអនីតិជនបានប្រព្រឹត្តកំហុស តើកូន ឬឪពុកម្តាយជាអ្នកទទួលខុសត្រូវ? ទាក់ទិននឹងសមត្ថភាពទទួលខុសត្រូវ គឺអាចនិយាយបានថាអនីតិជនមិនត្រូវបានទទួលខុសត្រូវទេ។ ដើម្បីកំណត់ពីការទទួលខុសត្រូវ សមត្ថភាពទទួលខុសត្រូវជាលក្ខខណ្ឌចាំបាច់ក្នុងការពិនិត្យ។ ក្រមរដ្ឋប្បវេណីកំណត់ថា ជនដែលមានអាយុក្រោម ១៤ ឆ្នាំ *មិនត្រូវទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលទេ។* [74] ជាការពិតណាស់ កូនដែលជាអនីតិជនត្រូវបានការពារដោយច្បាប់មិនត្រូវទទួលខុសត្រូវឡើយ តែបុគ្គលដែលកំណត់ដោយច្បាប់ក្នុងការគ្រប់គ្រងអនីតិជន ពោលគឺអ្នកដែលមានអំណាចមេបាជាអ្នកដែលទទួលខុសត្រូវចំពោះទង្វើកូន។ ទោះបីជាមានការលែងលះក៏ដោយ ឪពុកឬម្តាយដែលមានអំណាចមេបាក្នុងការត្រួតពិនិត្យកូនដែលជាអនីតិជន មានករណីយកិច្ចសងការខូចខាតដល់អ្នកដទៃដែលកើតឡើងដោយ *អំពើបំពានរបស់បុគ្គលនៅក្រោមការត្រួតពិនិត្យរបស់ខ្លួន។* [75]

### ក. ការបែងចែកអាយុអនីតិជន

ក្នុងចំណុចអនីត្យានុកូល ការប្រើប្រាស់ពាក្យ "អនីតិជន" មានការប្រយ័ត្នប្រយែងណាស់ ព្រោះតាមអត្ថន័យមាត្រា ១៧ នៃក្រមរដ្ឋប្បវេណីបានបញ្ជាក់យ៉ាងច្បាស់ថា អនីតិជនជាជនដែលមានអាយុក្រោម ១៨ ឆ្នាំ។ តែនៅក្នុងជំពូកទី ១៦ នៃអំពើអនីត្យានុកូល គឺអនីតិជន ត្រូវបានបែងចែកជា ២ (ពីរ)៖ អនីតិជនមានអាយុក្រោម ១៤ឆ្នាំ និង អនីតិជនមានអាយុចាប់ពី ១៤ ឆ្នាំ [76] ដោយសារការទទួលត្រូវខុសមានលក្ខណៈខុសគ្នាបន្តិច៖

- ក្នុងករណីអនីតិជនអាយុក្រោម ១៤ ឆ្នាំ គឺបុគ្គលដែលមានករណីយកិច្ចដែលបានកំណត់ដោយច្បាប់មានករណីយកិច្ចត្រូវសងការខូតខាតដល់អ្នកដទៃ ដែលកើតឡើងដោយអំពើបំពានរបស់បុគ្គលនៅក្រោមការត្រួតពិនិត្យរបស់ខ្លួននេះ។
- ក្នុងករណីអនីតិជនអាយុចាប់ពី ១៤ ឆ្នាំ គឺបុគ្គលដែលមានករណីយកិច្ចដែលបានកំណត់ដោយច្បាប់ និង អនីតិជនអាយុចាប់ពី១៤ ឆ្នាំ គឺ ត្រូវទទួលខុសត្រូវដោយសាមគ្គីភាព។

ក្នុងទំនាក់ទំនងឪពុកម្តាយ និងកូន ក្នុងសង្គមជាក់ស្តែង ទោះយ៉ាងណាឪពុកម្តាយតែងតែទទួលរ៉ាប់រងលើកូនទាំងអស់មិនថាកូនមានអាយុលើសពី ១៤ ឆ្នាំក៏ដោយ។ ហេតុនេះ ការបែងចែកអាយុអនីតិជននេះគ្រាន់តែការពារមួយផ្នែក ចំពោះបុគ្គលដែលកំណត់ដោយច្បាប់ (ក្រៅពីឪពុក ឬម្តាយ) ក្នុងការគ្រប់គ្រងអនីតិជនដែលមានអាយុលើសពី ១៤ ឆ្នាំ។

---

[72] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៧៤៣។

[73] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៧៤២។

[74] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៧៤៥។

[75] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៧៤៦ កថាខណ្ឌទី១ និង ២។

[76] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៧៤៦ កថាខណ្ឌទី១ និង ២។

## ខ. សំណងនៃការទទួលខុសត្រូវ

ក្នុងច្បាប់ខ្មែរពុំបានកំណត់ពីទំហំនៃការទទួលខុសត្រូវឡើយ ហេតុនេះការទទួលខុសត្រូវគឺគ្មានព្រំដែន អាស្រ័យទៅតាមព្យាសនកម្មនៃអំពើនោះ ហើយមានចំណុចពិសេសមួយទៀតត្រង់ថា មាត្រា ៧៤៤ នៃក្រមរដ្ឋប្បវេណីបានរាប់បញ្ចូលសំណងនៃការខូតខាត ដែលមិនមែនជាទ្រព្យសម្បត្តិដូចជា ការសងការខូចខាតចំពោះអ្វីដែលមិនមែនជាទ្រព្យសម្បត្តិផងដែរ។

បើក្រឡេកមើលតថភាពច្បាប់នៃរដ្ឋកាលីហ្វ័រញ៉ានៃសហរដ្ឋអាមេរិក បានកំណត់ពីព្រំដែននៃការទទួលខុសត្រូវ ពោលគឺគណនាពីទំហំទឹកប្រាក់ដែលឪពុកម្ដាយត្រូវទទួលខុសត្រូវ។ ក្នុងច្បាប់រដ្ឋកាលីហ្វ័រញ៉ាបានចែងថា ឪពុកម្តាយ ឬអាណាព្យាបាលរបស់កុមារដែលជាអនីតិជនត្រូវទទួលខុសត្រូវ ចំពោះអំពើចេតនាណាមួយរបស់កូនដែល *បណ្ដាលឱ្យមានរបួស ឬស្លាប់ដល់មនុស្សម្នាក់ទៀត ឬបង្កគ្រោះថ្នាក់ដល់ទ្រព្យសម្បត្តិរបស់អ្នកដទៃ*។[77] ឪពុកម្តាយ (ដែលមានអំណាចមេបា)ត្រូវទទួលខុសត្រូវ ចំពោះការខូចខាតរដ្ឋប្បវេណីទាំងអស់ ដែលបណ្ដាលមកពីអំពើអនីត្យានុកូលរបស់កូន។

ចំណុចដែលពិសេសប្លែកពីច្បាប់ខ្មែរ គឺច្បាប់រដ្ឋកាលីហ្វ័រញ៉ាបានកំណត់អំពីអតិបរមានៃចំនួនប្រាក់ដែលត្រូវសង ឬត្រូវទទួលខុសត្រូវ។ ឪពុក ឬម្តាយដែលមានអំណាចមេបា អាចធ្វើការចេញសងដោយមិនលើសពី ២៥,០០០ (ពីរម៉ឺនប្រាំពាន់)ដុល្លាសហរដ្ឋអាមេរិក ដោយមិនគិតពីការទទួលខុសត្រូវផ្សេងទៀតដែលតម្រូវដោយច្បាប់។[78] ហើយបើយោងទៅតាមស្មារតីនៃច្បាប់នេះ គឺគេមិនអាចទាមទារការខូចខាតដែលមិនមែនជាទ្រព្យសម្បត្តិទេ ដូចជាការប៉ះពាល់អារម្មណ៍ការឈឺចាប់ជាដើម។ [79]

[77] ក្រមរដ្ឋប្បវេណីរដ្ឋកាលីហ្វ័រញ៉ា, មាត្រា ១៧១៤.១ (a).
https://leginfo.legislature.ca.gov/faces/codes_displaySection.xhtml?lawCode=CIV&sectionNum=1714.1។

[78] ក្រមរដ្ឋប្បវេណីរដ្ឋកាលីហ្វ័រញ៉ា, មាត្រា ១៧១៤.១ (b).
https://leginfo.legislature.ca.gov/faces/codes_displaySection.xhtml?lawCode=CIV&sectionNum=1714.1។

[79] *Parental Liability for the Actions of Children* | San Jose Personal Injury Lawyers.CMA Law. n.d.,
https://www.cmalaw.net/parental-liability-for-the-actions-of-children.html. (*ថ្ងៃចូលមើល ២៥ មិថុនា ២០២២*)។

# ជំពូកទី២
# សិទ្ធិ និងភាតព្វកិច្ច
# របស់សហព័ទ្ធ
# ក្នុងករណីសហព័ទ្ធ
# ទទួលមរណភាព

# ជំពូកទី២

# សិទ្ធិ និងភាពព្វកិច្ចសហព័ទ្ធ ក្នុងករណីសហព័ទ្ធម្ខាងទទួលមរណភាព

មរណភាព គឺជាសេចក្តីស្លាប់ហើយការបាត់ខ្លួននេះត្រូវបានសន្មតថាមរណភាព។[80] មរណភាពជាពេលដែលបញ្ចប់សមត្ថភាពទទួលសិទ្ធិ ហើយការបាត់ខ្លួនជាអវត្តមាននៃដំណឹងរបស់បុគ្គលដោយមិនដឹងច្បាស់ថាបុគ្គលនោះនៅរស់ ឬមរណភាព។ ជាទូទៅ ការបាត់ខ្លួនដោយមិនមានដំណឹងរយៈពេល ០៥ (ប្រាំ) ឆ្នាំ[81] សហព័ទ្ធអាចដាក់ពាក្យទៅតុលាការដើម្បីប្រកាសថាសហព័ទ្ធខ្លួនបានបាត់ខ្លួនតាមផ្លូវច្បាប់។

ក្នុងករណីដែលការបាត់ខ្លួននោះមានមូលហេតុ ដែលអាចដឹងបានដូចជា បុគ្គលនោះបានទៅធ្វើសង្គ្រាម ធ្វើដំណើរតាមកប៉ាល់ យន្តហោះ ឬជួបគ្រោះថ្នាក់ផ្សេងៗ ដោយគ្មានទទួលដំណឹងអ្វីសោះរយៈពេល ០១ (មួយ) ឆ្នាំ[82] នោះអាចសន្មតថាបាត់ខ្លួន។ ដោយការបាត់ខ្លួនស្មើនឹងមរណភាព ហើយមរណភាពនេះក៏បានធ្វើឱ្យដាច់ចំណងអាពាហ៍ពិពាហ៍។ ក្នុងចំណុចខាងក្រោមនេះ នឹងធ្វើការបកស្រាយជុំវិញមរណភាពនៃសហព័ទ្ធដោយក្តោបទាំងអត្ថន័យនៃការបាត់ខ្លួន។

## ផ្នែកទី១៖ លក្ខណៈសម្បត្តិរបស់សហព័ទ្ធនៅរស់

ក្នុងផ្នែកនេះនឹងបកស្រាយពីការវិវត្តសិទ្ធិរបស់សហព័ទ្ធនៅរស់ ដែលវាជាភាពចាំបាច់ក្នុងដើម្បីបង្ហាញពីសហព័ទ្ធដែលមានសិទ្ធិ ក្នុងការប្រកួតប្រជែងសន្តតិកម្មក្រោយសហព័ទ្ធម្ខាងបានទទួលមរណភាព។ ម្យ៉ាងទៀតវាក៏មានភាពប្រទាក់ក្រឡានឹងភាគបម្រុង ដែលជាគោលគំនិតក្នុងការការពារការបែងចែកមត៌កដោយត្រឹមត្រូវដោយមិនប៉ះពាល់ដល់ចំណែកដែលសន្តតិជនត្រូវទទួលបាន ហើយសហព័ទ្ធជាតួអង្គសំខាន់ក្នុងការបកស្រាយនេះ។

### កថាខណ្ឌទី១៖ ការវិវត្តសិទ្ធិរបស់សហព័ទ្ធនៅរស់

នៅក្នុងក្រមរដ្ឋប្បវេណីចាស់ឆ្នាំ១៩៦៧ នៅពេលចាប់ផ្តើមបើកសន្តតិកម្ម កូនរបស់មតកជនត្រូវទទួលបានមុនគេ តែក្នុងករណីមិនមានបច្ឆាញាតិ នោះសន្តតិកម្មត្រូវបានទៅឪពុកម្តាយរបស់មតកជន។[83] បើឪពុកម្តាយរបស់មតកជនមិនមាន នោះត្រូវបានទៅលើបុព្វញាតិខាងឪពុកនិងបុព្វញាតិខាងម្តាយ ដោយទទួលចំណែកម្នាក់ពាក់កណ្តាល។[84] បើនៅតែមិនមានអ្នកទទួលសន្តតិកម្មទៀត គេពិនិត្យមើលបងប្អូនបង្កើតរបស់មតកជន(ឪពុកម្តាយរួម) ហើយសន្តតិកម្មនោះនឹងបានលើពួកគេ។

---

[80] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៤៣។

[81] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៤១ កថាខណ្ឌទី១។

[82] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៤១ កថាខណ្ឌទី២។

[83] ក្រមរដ្ឋប្បវេណីចាស់ ឆ្នាំ១៩៦៧, មាត្រា ៤៩៣ និង៤៩៤។

[84] ក្រមរដ្ឋប្បវេណីចាស់ ឆ្នាំ១៩៦៧, មាត្រា ៤៩៥។

ក្នុងករណីចុងក្រោយនៃការបែងចែកសន្តតិកម្មនេះគឺ បើមិនមានបុព្វញាតិ បងប្អូន កូន បច្ឆាញាតិ នោះទេ ទើបសន្តតិកម្មធ្លាក់លើសហព័ទ្ធ។[85]

ក្រមរដ្ឋប្បវេណីចាស់កំណត់ថា សន្តតិកម្មនោះបានលើសហព័ទ្ធលុះត្រាតែះ

(១) សហព័ទ្ធនោះមានខាន់ស្លា (ស្របច្បាប់)

(២) រស់នៅជាមួយគ្នា

(៣) មិនបានលែងលះគ្នា។

សង្ខេបដោយខ្លី គឺសហព័ទ្ធក្នុងក្រមរដ្ឋប្បវេណីចាស់ គឺស្ថិតនៅលំដាប់សន្តតិជនស្ទើរតែក្រោយគេទៅហើយ។ អ្វីដែលសំខាន់នោះមិនមានភ័ព្វក្នុងការប្រកួតប្រជែងសន្តតិកម្មឡើយ។ តាមការសិក្សាក្រមរដ្ឋប្បវេណីចាស់ ទោះសហព័ទ្ធនៅរស់មិនអាចប្រកួតប្រជែងជាមួយលំដាប់ញាតិដទៃទៀតបាន តែក្នុងករណីសហព័ទ្ធមានខាន់ស្លានិងមានកូន នោះផ្ទះដែលនៅនិងបេតិកភណ្ឌទាំងប៉ុន្មានត្រូវដាក់ឱ្យសហព័ទ្ធដែលរស់នោះ គ្រប់គ្រងថែរក្សាប្រើប្រាស់ជាប្រយោជន៍នៃគ្រួសារ។[86]

ប៉ុន្តែក្នុងមាត្រា ៥០៤ នៃក្រមរដ្ឋប្បវេណីចាស់នេះ មិនបាននិយាយពីសិទ្ធិចាត់ចែងឡើយ ឬអាចនិយាយបានថា សហព័ទ្ធនៅតែមិនអាចលក់បេតិកភណ្ឌនោះ។ តែក្នុងករណីមានសេចក្តីត្រូវការ អាចលក់បានតែត្រូវមានការសុំអនុញ្ញាតពីក្រុមប្រឹក្សាញាតិ (ក្នុងមាត្រានេះដែរ គឺកំណត់តែក្នុងករណីដែលប្តីស្លាប់ហើយប្រពន្ធនៅរស់ តែមិនបាននិយាយពីករណីដែលប្រពន្ធស្លាប់ ប្តីនៅរស់ឡើយ តែអាចសន្និដ្ឋានថាវាមិនខុសគ្នាទេរវាងប្រពន្ធឬប្តី ក្នុងករណីមរណភាព)។ តាមការកំណត់ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ សហព័ទ្ធនៅរស់ជាសន្តតិជនជានិច្ច ក្នុងការប្រកួតប្រជែងក្នុងចំណែកមត៌ក ហើយមានលំដាប់ស្មើគ្នានឹងបុគ្គលដែលកំណត់ដោយច្បាប់។ ទោះបីជាសហព័ទ្ធម្ខាងបានទទួលមរណភាពក៏ដោយ ក៏សិទ្ធិរបស់សហព័ទ្ធនៅរស់ជាសន្តតិជននៅតែមានជានិច្ច។[87]

[85] ក្រមរដ្ឋប្បវេណីចាស់ ឆ្នាំ១៩៦៧, មាត្រា ៤៩៧។

[86] ក្រមរដ្ឋប្បវេណីចាស់ ឆ្នាំ១៩៦៧, មាត្រា ៥០៤។

[87] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៦១។

| មាត្រា ១១៦២ នៃក្រមរដ្ឋប្បវេណីថ្មី | | | |
|---|---|---|---|
| ដៃគូប្រកួតប្រជែង | | | ចំណែកសន្តតិកម្ម |
| | | បច្ឆាញាតិផ្ទាល់របស់មតកជន | សហព័ទ្ធ និងកូននីមួយៗ របស់មតកជន នោះនឹងត្រូវទទួលចំណែកមត៌កស្មើគ្នា។ |
| សហព័ទ្ធ | និង | ឪពុក ម្ដាយរបស់មតកជន | ចំណែកមត៌ករបស់សហព័ទ្ធត្រូវជា ១ ភាគ ៣ ឯចំណែកមត៌ករបស់ឪពុកម្ដាយត្រូវជា ២ ភាគ ៣ ។ *ប៉ុន្តែបើឪពុក ឬម្ដាយរបស់មតកជនតែម្នាក់នៅរស់ ឪពុកម្ដាយនោះ និងសហព័ទ្ធត្រូវបានចំណែកមត៌កស្មើគ្នា។* |
| | | បុព្វញាតិផ្ទាល់ ក្រៅពីឪពុកម្ដាយរបស់មតកជន ឬបងប្អូនបង្កើតរបស់របស់មតកជន ឬអ្នកទទួលសន្តតិកម្មជំនួសបុគ្គលទាំងនោះ | ចំណែកមត៌ករបស់សហព័ទ្ធត្រូវជា ១ ភាគ ២ ឯចំណែកមត៌ករបស់បុព្វញាតិផ្ទាល់ ក្រៅពីឪពុកម្ដាយរបស់មតកជន ឬបងប្អូនបង្កើតរបស់មតកជន ឬអ្នកទទួលសន្តតិកម្មជំនួសនោះត្រូវជា ១ ភាគ ២។ |

បន្ទាប់ពីប្រៀបធៀបលំដាប់សន្តតិជននៅក្នុងក្រមរដ្ឋប្បវេណីថ្មីនិងចាស់ អាចទាញសេចក្ដីសន្និដ្ឋានបានថា សហព័ទ្ធនៅក្រមរដ្ឋប្បវេណីចាស់មិនបានចែងពីសិទ្ធិក្នុងការប្រកួតប្រជែងជាមួយលំដាប់ញាតិដទៃទៀតទេ តែនៅក្នុងក្រមថ្មីនេះបានផ្ដល់នូវសិទ្ធិមួយ ដែលជាភ័ព្វក្នុងការប្រកួតប្រជែងជាមួយសន្តតិជនដទៃទៀត។

## កថាខណ្ឌទី២៖ សិទ្ធិលើភាគបម្រុង

ច្បាប់បានទទួលស្គាល់ឱ្យមានសន្តតិកម្មតាមបណ្ដាំ ដែលមតកជនអាចបង្ហាញឆន្ទៈរបស់ខ្លួនក្នុងការបែងចែកចំណែកមត៌ក បន្ទាប់ពីខ្លួនបានទទួលមរណភាពទៅ។ ប៉ុន្តែការទទួលស្គាល់របបសន្តតិកម្មបែបនេះ ក៏អាចធ្វើឱ្យប៉ះពាល់ដល់ចំណែកដែលសន្តតិជនត្រូវទទួលបានផងដែរ ប្រសិនបើមតកជនបានបង្ហាញឆន្ទៈចាត់ចែងទ្រព្យសម្បត្តិរបស់ខ្លួនទៅឱ្យជនដទៃ ក្រៅពីសន្តតិជនឬចាត់ចែងទ្រព្យមួយភាគធំឱ្យទៅសន្តតិជនមួយចំនួនដែលធ្វើឱ្យចំណែកមត៌កមិនសមហេតុសមផល។ ហេតុនេះហើយទើបក្រមរដ្ឋប្បវេណីបានបង្កើតនូវរបបភាគបម្រុងឡើង។

### ១. សញ្ញាណនៃភាគបម្រុង

ក្រមរដ្ឋប្បវេណីថ្មី មិនបានចែងអំពីនិយមន័យភាគបម្រុងឡើយ តែបើក្រឡេកមើលក្រមរដ្ឋប្បវេណីចាស់ឆ្នាំ១៩៦៧ ភាគបម្រុងគឺជា *របបមួយនៃបេតិកភណ្ឌដែលម្ចាស់បណ្ដាំខ្លួនឯងផ្ទាល់ ក៏មិនអាចនឹងចាត់ចែង*

*យ៉ាងណាៗដោយសេរីបានឡើយ។*[88] តែតាមរយៈអត្ថន័យក្នុងមាត្រា១២៣០ ភាគបម្រុងសំដៅលើ *សិទ្ធិដែលទទួលបានមត៌កជាអប្បបរមាដែលត្រូវធានាដោយច្បាប់ ចំពោះអ្នកមានសិទ្ធិលើភាគបម្រុង។* គោលបំណងនៃភាគបម្រុងគឺ បង្កើតឡើងដើម្បីធានានូវចំណែកមត៌កអប្បបរមា ចំពោះសន្តតិជនដែលមានញាតិជិតស្និទ្ធិនឹងមតកជន។[89] ម៉្យាងទៀតដើម្បីរក្សាចំណែកមត៌កជាក់លាក់លើទ្រព្យសម្បត្តិរបស់មតកជន សម្រាប់ជនដែលបានរស់នៅក្នុងបន្ទុកនិងដោះស្រាយនូវចំណែកមត៌កជាសក្តានុពលសម្រាប់ញាតិជិតស្និទ្ធិ ដែលបានចូលរួមក្នុងការបង្កើតទ្រព្យសម្បត្តិរបស់មតកជន។[90]

### ២. ភាគបម្រុងចំពោះសហព័ទ្ធ

ក្រមរដ្ឋប្បវេណីកម្ពុជា បានកំណត់ឱ្យជនមួយចំនួនដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយមតកជន ក្លាយជាអ្នកមានសិទ្ធិលើភាគបម្រុង ដែលរួមមានបច្ឆាញាតិផ្ទាល់ ឬសន្តតិជនជំនួសរបស់ខ្លួន ឱពុកម្ដាយ ជីដូនជីតា និងសហព័ទ្ធ។ ប៉ុន្តែទោះបីជាយ៉ាងណាក្ដី មិនមែនមានន័យថា ជនទាំងអស់ដូចមានបញ្ជាក់ខាងលើសុទ្ធតែមានសិទ្ធិលើភាគបម្រុងគ្រប់ៗគ្នានោះទេ ព្រោះថាបើមានសន្តតិជនលំដាប់ទី១ ជាអ្នកមានសិទ្ធិលើភាគបម្រុង[91] នោះសន្តតិ-ជនលំដាប់ទី២ ពុំមានសិទ្ធិទទួលឋានៈជាអ្នកមានសិទ្ធិលើភាគបម្រុងទៀតនោះឡើយ។ ទោះក្នុងករណីណាក៏ដោយសហព័ទ្ធជាជនដែលមានភ័ព្វ គឺមានសិទ្ធិលើភាគបម្រុងជានិច្ចទោះក្នុងកាលៈទេសៈយ៉ាងណាក៏ដោយ។

គោលគំនិតនៃភាគបម្រុងបានការពារដល់ជនដែលមានសិទ្ធិលើភាគបម្រុង បើទោះបីជាមត៌កជនមានគំនិតមិនប្រាថ្នាផ្ញើមត៌កដល់បុគ្គលមួយចំនួន ឬផ្ញើមត៌កឱ្យតែជនតែម្នាក់ ឬច្រើនតែមិនសមាមាត្រនៃការបែងចែកមត៌ក។ បើការគណនាភាគបម្រុងនោះគិតចាប់ពីពេលបើកមត៌កនោះ មតកជនអាចធ្វើប្រទានកម្មទ្រព្យសម្បត្តិមុនពេលស្លាប់ទៅឱ្យតែបុគ្គលខ្លួនចង់ប្រគល់។ ហេតុនេះបានជាច្បាប់បានបញ្ញត្តិក្នុងការគណនាភាគបម្រុងទាំងមុនមរណភាព និងក្រោយមរណភាព ដោយរួមបញ្ចូលទាំងតម្លៃនៃផលប្រយោជន៍ពិសេស[92] និងប្រទានកម្ម។

---

[88] ក្រមរដ្ឋប្បវេណីចាស់ ឆ្នាំ១៩៦៧, មាត្រា ៥២៨។

[89] ញាតិដែលជិតនឹងមរតកជនគឺ *បច្ឆាញាតិផ្ទាល់ ឬសន្តតិជនជំនួស, ឪពុកម្តាយ និងជីដូនជីតា, សហព័ទ្ធ*។

[90] គម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ, ក្រសួងយុត្តិធម៌ និងដទៃទៀត, *មេរៀនស្ដីពីក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី ភាគ ១* (ភ្នំពេញ, ២០១៥), ៨៥។

[91] ច្បាប់បានបញ្ញត្តិនូវលំដាប់នៃការទទួលទ្រព្យសម្បត្តិដែលមត៌កនៃមតកជនដោយកំណត់យក*បច្ឆាញាតិផ្ទាល់* របស់មត៌កជនជាអ្នកមានសិទ្ធិទទួលមត៌កមុនគេ។ *ពិនិត្យបន្ថែម* ក្រមរដ្ឋប្បវេណីលេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៥៦ និង ១១៥៧។

[92] តម្លៃនៃផលប្រយោជន៍ពិសេស គឺទ្រព្យដែលបុគ្គល(សន្តតិជន) បានទទួលជាប្រទានកម្មនៅក្នុងឱកាសអាពាហ៍ពិពាហ៍ ឬហេតុការណ៍ផ្សេងទៀត ឬដើម្បីមូលធននៃជីវភាពរស់នៅ ឬដែលបានទទួលជាអច្ច័យទានពីមតកជន។ (មាត្រា ១១៦៣ នៃក្រមរដ្ឋប្បវេណី)

## ផ្នែកទី២៖ ការទទួល និងបដិសេធសន្តតិកម្ម

នៅពេលដែលសហព័ទ្ធណាម្នាក់ទទួលមរណភាព ការបែងចែកសន្តតិកម្មនឹងកើតមានឡើង។ សន្តតិកម្មកើតមានទៅតាមការបែងចែកដែលមានចែងនៅក្នុងច្បាប់ ឬទៅតាមមតកសាសន៍របស់មតកជន។ យ៉ាងណាមិញ មិនមែនសន្តតិជនសុទ្ធតែយល់ព្រមក្នុងការទទួលនូវសន្តតិកម្មទាំងនោះទេ ដោយហេតុថាមានលក្ខខណ្ឌមួយចំនួនដែលធ្វើឱ្យសន្តតិជនបដិសេធមិនទទួលសន្តតិកម្មនោះបាន។ ថ្វីបើផ្អែកតាមបញ្ញត្តិច្បាប់ ការចាប់ផ្តើមសន្តតិកម្មត្រូវចាប់ផ្តើមនៅពេលមរណភាពរបស់មតកជន[93] ក៏ប៉ុន្តែការទទួលយក ឬមិនទទួលយកសន្តតិកម្មគឺអាស្រ័យទៅនឹង ឆន្ទៈ ការយល់ឃើញ និងការសម្រេចចិត្តរបស់សន្តតិជននោះទេ។

ក្របខណ្ឌនៃសន្តតិកម្ម ដែលលើកយកមកបរិយាយត្រង់ចំណុចនេះមាន ២ (ពីរ) គឺសិទ្ធិបេតិកភណ្ឌនិងសិទ្ធិក្រៅបេតិកភណ្ឌ។ សិទ្ធិបេតិកភណ្ឌ សំដៅដល់ទ្រព្យសម្បត្តិ រួមមានទ្រព្យសកម្ម និងទ្រព្យអកម្ម។ ចំណែកឯសិទ្ធិក្រៅបេតិកភណ្ឌ សំដៅដល់កម្មសិទ្ធិបញ្ញា។

### កថាខណ្ឌទី១៖ សិទ្ធិបេតិកភណ្ឌ

ក្នុងលក្ខខណ្ឌនៃការបែងចែកសន្តតិកម្ម មាន ០២ (ពីរ) គឺ៖ (១) សហព័ទ្ធយល់ព្រមទទួលនូវចំណែកមត៌កទៅតាមផ្លូវច្បាប់ ឬទៅតាមមតកសាសន៍ និង (២) សហព័ទ្ធបដិសេធមិនទទួលយកនូវចំណែកមត៌កដោយយោងលើមូលហេតុផ្សេង។

#### ១.លក្ខខណ្ឌក្នុងការទទួលសន្តតិកម្ម

ក្រមរដ្ឋប្បវេណីបានចែងយ៉ាងច្បាស់ថា សហព័ទ្ធគឺជាសន្តតិជនជានិច្ច[94] មានន័យថាពេលដែលសហព័ទ្ធម្ខាងទៀតទទួលអនិច្ចកម្មទៅ សហព័ទ្ធដែលនៅរស់មិនចាំបាច់ត្រូវប្រកួតប្រជែងជាមួយសន្តតិជនដទៃទៀតឡើយ ដោយហេតុថាលំដាប់នៃសន្តតិជននឹងមិនត្រូវបានយកមកគិត ព្រោះជាស្វ័យប្រវត្តិសហព័ទ្ធនៃមតកជនមានសិទ្ធិក្នុងការទទួលបាននូវចំណែកមួយភាគពីរ ទៅតាមការកំណត់របស់ច្បាប់។

នៅពេលដែលសហព័ទ្ធដែលជាសន្តតិជនយល់ព្រមទទួលបន្តនូវមត៌ក មានន័យថាសន្តតិជនត្រូវទទួលយកនូវសិទ្ធិ និងករណីយកិច្ចទាំងអស់ដែលស្ថិតនៅក្រោមទ្រព្យសម្បត្តិរបស់មតកជន ចាប់ពីពេលដែលសន្តតិ-កម្មបានចាប់ផ្តើម។[95] លទ្ធភាពនៃការយល់ព្រមទទួលសន្តតិកម្មរបស់សន្តតិជនមាន ៣ (បី) ទម្រង់៖ ការយល់ព្រមទាំងស្រុង ការយល់ព្រមទាំងស្រុងតាមច្បាប់ និងការយល់ព្រមដោយមានកម្រិត។

##### ក. ការយល់ព្រមទាំងស្រុង

ការយល់ព្រមទាំងស្រុង មានន័យថាសន្តតិជនបានយល់ព្រមក្នុងការទទួលបន្តទាំងស្រុងនូវសិទ្ធិ និងករណីយកិច្ចទាំងអស់ដែលស្ថិតនៅក្រោមទ្រព្យសម្បត្តិរបស់មតកជនទាំងទ្រព្យសកម្ម និងទ្រព្យអកម្ម ដោយ

[93] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៤៥។

[94] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៦១។

[95] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៤៧។

គ្មានកម្រិតសិទ្ធិនិងកាតព្វកិច្ចរបស់មតកជននោះទេ។[96] ត្រង់ចំណុចមានន័យថា បុគ្គលដែលទទួលស្នងនូវមត៌កត្រូវទទួលយកទាំងទ្រព្យបំណុលរបស់មតកជនដែលមានពេលនៅរស់ និងត្រូវបានដាក់បញ្ចូលនៅក្នុងមត៌កផងដែរ។ ម្យ៉ាងវិញទៀត ករណីដែលសន្តតិជនធ្វើការចាត់ចែងទៅលើទ្រព្យសម្បត្តិទាំងស្រុង ឬទៅលើចំណែកណាមួយនៃមត៌ក នោះក៏ត្រូវចាត់ទុកថាសន្តតិជនបានយល់ព្រមទាំងស្រុងទៅលើការទទួលយកមត៌កដែរ។[97]

### ខ. ការយល់ព្រមទាំងស្រុងតាមច្បាប់

ជាគោលការណ៍ ការយល់ព្រមទាំងស្រុងតាមផ្លូវច្បាប់ត្រូវបានកំណត់ក្នុងលក្ខខណ្ឌ ៣ (បី) យ៉ាងដូចមានចែងនៅក្នុងមាត្រា ១២៥៥ នៃក្រមរដ្ឋប្បវេណី ហើយល្គឹកណាសកម្មភាពរបស់សហព័ទ្ធនៅរស់ចូលក្នុងលក្ខខណ្ឌណាមួយ ក្នុងចំណោមលក្ខខណ្ឌទាំងបីខាងក្រោម គឺត្រូវសន្មតថាសហព័ទ្ធនោះបានយល់ព្រមទាំងស្រុងតាមច្បាប់ ក្នុងការទទួលបន្តនូវសន្តតិកម្មៈ

ក. បើសន្តតិជនបានចាត់ចែងមត៌កនោះទាំងអស់ ឬមួយភាគ

ខ. បើសន្តតិជនមិនបានយល់ព្រមដោយកម្រិត ឬបោះបង់ នៅក្នុងអំឡុងពេលកំណត់ ០៣ (បី) ខែ

គ. សន្តតិជនបានលាក់មត៌កទាំងអស់ ឬមួយភាគ ឬបានប្រើប្រាស់មត៌កនោះដើម្បីខ្លួន។

តាមការកំណត់នៅក្នុងក្រមរដ្ឋប្បវេណីចាស់ បើសន្តតិជនជាសហព័ទ្ធនៅរស់បដិសេធមិនទទួលយកនូវសន្តតិកម្ម ត្រូវប្តឹងមកតុលាការក្នុងអំឡុងពេល ០៣ (បី) ខែ គិតចាប់ពីថ្ងៃដែលមតកជនទទួលមរណភាព។[98] បន្ថែមពីនេះទៀត ក្រមរដ្ឋប្បវេណីចាស់ក៏បានសន្មតថា ការនៅស្ងៀមគឺស្មើនឹងការយល់ព្រមទទួលនូវមត៌ក។[99] ជាក់ស្តែង សហព័ទ្ធនៅរស់មានអំឡុងពេលពិចារណារយៈពេល ០៣ (បី)ខែដើម្បីបដិសេធ ឬទទួលសន្តតិកម្ម ប៉ុន្តែប្រសិនជារយៈពេលកំណត់នេះកន្លងផុត ក្នុងករណីនេះសន្មតថាសន្តតិជនយល់ព្រមទទួលនូវសន្តតិកម្ម។ ប៉ុន្តែក្នុងករណីសន្តតិជនគ្រប់គ្រងមត៌កជាបណ្តោះអាសន្ន សកម្មភាពនេះមិនចាត់ទុកថាជាយល់ព្រមទាំងស្រុងតាមច្បាប់នោះទេ ដោយហេតុថាក្នុងនាមជាសន្តតិជនគឺមានករណីយកិច្ចត្រូវរក្សាគ្រប់គ្រងមត៌ក។

### គ. ការយល់ព្រមដោយមានកម្រិត

នៅពេលដែលសហព័ទ្ធនៅរស់ពិចារណាឃើញថា ទ្រព្យសម្បត្តិដែលបន្សល់ទុកពីមតកជនមានជាប់នូវសំណងកាតព្វកិច្ច និង អច្ច័យទាន នោះសន្តតិជនអាចធ្វើការបម្រុងទុកនូវចំណែកទាំងនោះ ហើយទទួលយក

[96] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២៥៤។

[97] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩២១។

[98] បើមិនទទួលមត៌កទេ អ្នកប្រកែកត្រូវប្តឹងក្នុងរវាង ០៣ (បី) ខែ គិតពីត្រឹមពីក្រោយថ្ងៃដែលខ្មោចស្លាប់មក។ (មាត្រា ៥៨៦ ក្រមរដ្ឋប្បវេណីចាស់)

[99] ការទទួល ឬមិនទទួលត្រូវឱ្យឆ្លើយក្នុងកំណត់ ១៥ថ្ងៃ គិតតាំងពីថ្ងៃដែលធ្វើបញ្ញើហើយជាស្រេច, បើនៅស្ងៀមទុកស្មើព្រមទទួលយក។ (មាត្រា ៥៩២ នៃក្រមរដ្ឋប្បវេណីចាស់)

ត្រឹមតែកម្រិតនៃទ្រព្យសម្បត្តិដែលខ្លួនទទួលបានតាមរយៈសន្តតិកម្ម។[100] ត្រង់ចំណុចនេះមានន័យថា សហព័ទ្ធនៅរស់ដែលក្លាយទៅជាកូនបំណុលទទួលសងត្រឹមតែកម្រិតនៃទ្រព្យសម្បត្តិដែលទទួលបានពីសន្តតិកម្ម ចំពោះការជាប់នូវកាតព្វកិច្ចទាំងអស់របស់មតកជន។ និយាយឱ្យខ្លីគឺសហព័ទ្ធនៅរស់អាចកម្រិតនូវការទទួលខុសត្រូវសងបំណុលរបស់មតកជន ដោយសងត្រឹមតែកម្រិតនៃមត៌កដែលខ្លួនទទួលបាន។ នៅពេលដែលសហព័ទ្ធនៅរស់បានយល់ព្រមដោយកម្រិត ចំពោះបំណុលដែលមតកជនមានចំពោះម្ចាស់បំណុល គឺម្ចាស់បំណុលរបស់មតកជនពុំអាចទាមទារឱ្យសហព័ទ្ធដែលជាសន្តតិជនប្រើប្រាស់នូវទ្រព្យសម្បត្តិផ្ទាល់ខ្លួន ដើម្បីទទួលខុសត្រូវលើបំណុលរបស់ខ្លួនបានទេ។[101]

ក្នុងការយល់ព្រមដោយកម្រិត ទាមទារឱ្យសហព័ទ្ធដែលជាសន្តតិជនយល់ព្រមដោយកម្រិត ធ្វើបញ្ជីទ្រព្យសម្បត្តិដើម្បីដាក់ជូនទៅតុលាការ ព្រមទាំងថ្លែងការណ៍អំពីការយល់ព្រមដោយកម្រិតក្នុងអំឡុងពេល ០៣ (បី) ខែគិតចាប់ពីពេលដែលដឹងថាសន្តតិកម្មបានចាប់ផ្តើម។[102]

ម្យ៉ាងទៀត ការយល់ព្រមដោយកម្រិតនេះអាចធ្វើទៅបាន លុះត្រាតែមានការយល់ព្រមពីសន្តតិជនទាំងអស់តែប៉ុណ្ណោះ ប្រសិនបើមានសន្តតិជនច្រើននាក់។ ក្នុងចំណោមសហសន្តតិជន កាលណាបើមានសន្តតិជនណាម្នាក់យល់ព្រមទាំងស្រុង ឬបោះបង់ នោះមិនមានសន្តតិជនណាម្នាក់អាចធ្វើការយល់ព្រមដោយកម្រិតបានឡើយ។[103] ដោយហេតុថា ចំពោះការយល់ព្រមដោយកម្រិតចាំបាច់ត្រូវមាននីតិវិធីជម្រះបញ្ជី ដើម្បីឱ្យមានភាពស្មើគ្នាក្នុងការទូទាត់សងម្ចាស់បំណុលរបស់មតកជន ជាហេតុតម្រូវឱ្យសហសន្តតិជនឯកភាពគ្នាក្នុងការសង។ ប៉ុន្តែប្រសិនបើក្នុងចំណោមសហសន្តតិជន មានសន្តតិជនមួយចំនួនដែលបានយល់ព្រមទាំងស្រុង ហើយអះអាងនូវចំណែកមត៌ក នោះនឹងធ្វើឱ្យប៉ះពាល់ទៅដល់ដំណើរការនៃការជម្រះបញ្ជី។ ដោយឡែក បើសិនជាសន្តតិជនបោះបង់សន្តតិកម្ម នោះមិនមែនជាបញ្ហាចោទទេ ព្រោះថាអ្នកទាំងនោះមិនត្រូវបានរាប់ជាសន្តតិជនតាំងពីដំបូង និងមិនប៉ះពាល់ទៅដល់ការជម្រះបញ្ជីផងដែរ។[104]

### ២. លក្ខខណ្ឌក្នុងការបដិសេធសន្តតិកម្ម

ផ្ទុយមកវិញ ក្នុងករណីដែលទ្រព្យបំណុលមានច្រើនជាងទ្រព្យសម្បត្តិដែលសហព័ទ្ធនៅរស់ត្រូវទទួលបាន តើសហព័ទ្ធដែលនៅរស់នោះអាចបដិសេធមិនទទួលយកនូវមត៌កនោះបានដែរឬទេ?

ក្នុងការបែងចែកនូវចំណែកមត៌ក មិនថាតាមរយៈមតកសាសន៍ ឬតាមរយៈច្បាប់ក្តី មិនប្រាកដថាបុគ្គលដែលជាសន្តតិជនត្រូវតែទទួលយកនូវចំណែកទ្រព្យសម្បត្តិទាំងនោះទេ។ ជាក់ស្តែង សហព័ទ្ធដែលជាសន្តតិជនមានសិទ្ធិបដិសេធទៅលើសន្តតិកម្មបានដែរ។ មានមូលហេតុផ្សេងៗជាច្រើន ដែលសន្តតិជនសម្រេចចិត្តធ្វើការ

[100] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២៥៦។
[101] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២៥៨។
[102] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២៥៧។
[103] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២៥៦។
[104] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគ៦: គម្ពីរទី៨-ទី៩ (ភ្នំពេញ, ២០១០), ១១៧ និង ១១៨។

បោះបង់ចោលនូវសន្តតិកម្ម ដែលក្នុងនោះរួមមាន មូលហេតុនៃទ្រព្យអកម្មឬទ្រព្យបំណុល ដែលបន្សល់មកមានភាពលើសលុបពីទ្រព្យសកម្មដែលត្រូវទទួលបាន។

ពេលដែលសន្តតិជនមានបំណងចង់បោះបង់នូវទ្រព្យសម្បត្តិនោះ សន្តតិជនត្រូវធ្វើការបោះបង់សន្តតិកម្មទាំងស្រុងឬដោយកម្រិត ដោយសន្តតិជនមានរយៈពេល ៣ (បី) ខែ គិតចាប់ពីពេលដែលបានដឹងថាសន្តតិកម្មរបស់ខ្លួនចាប់ផ្តើម។[105] ប៉ុន្តែសន្តតិជននៅតែអាចពន្យារទៅលើពេលវេលានេះទៀតបាន តាមរយៈការដាក់ពាក្យស្នើសុំទៅតុលាការ ក្រោមហេតុផលដើម្បីធ្វើការស្រាវជ្រាវទៅលើមត៌កនោះ មុននឹងសម្រេចចិត្តបោះបង់ ឬយល់ព្រមទទួលយកនូវសន្តតិកម្ម។[106] នៅពេលដែលសន្តតិជនបោះបង់ចោលនូវចំណែកមត៌ក នោះត្រូវចាត់ទុកថាមិនមែនជាសន្តតិជនតាំងពីដំបូង។[107]

## កថាខណ្ឌទី២៖ សិទ្ធិក្រៅបេតិកភណ្ឌ

ការបែងចែកទ្រព្យ មិនមែនជារឿងមួយថ្មីប្លែកដែលទើបកើតមាននៅក្នុងសង្គមរស់នៅរបស់មនុស្សនោះឡើយ ព្រោះជាទូទៅនៅពេលដែលបុគ្គលណាម្នាក់ទទួលអនិច្ចកម្ម សន្តតិកម្មជារឿយៗគឺតែងផុសឡើងនៅក្នុងគ្រួសារ និងរង្វង់ញាតិ។ មតកជនជាម្ចាស់នៃសិទ្ធិ ឬម្ចាស់កម្មសិទ្ធិផ្ទេរនូវចំណែកទ្រព្យសម្បត្តិរបស់ខ្លួនទៅឱ្យទាយាទ ក្នុងទំហំជាទឹកប្រាក់ ឬជាវត្ថុដែលអាចគណនាចេញជាតម្លៃនៃទឹកប្រាក់បាន។ ចុះចំពោះរបស់ទ្រព្យមួយចំនួនមានទម្រង់ជាស្នាដៃសំខាន់ៗដូចជា ផលិតផលខាងវិស័យអក្សរសាស្ត្រ វិទ្យាសាស្ត្រ សិល្បៈ តូរ្យតន្ត្រី ឬស្នាដៃផ្សេងទៀតដែលបង្កើតឡើងពីគំនិតច្នៃប្រឌិត និងការបង្កើតថ្មី តើមត៌កនៃការបង្កើតឡើងទាំងនោះនឹងត្រូវធ្វើការបែងចែកយ៉ាងដូចម្តេច ហើយស្នាដៃទាំងនោះនឹងធ្លាក់ទៅលើនរណាដែលជាអ្នកស្នង ឬបន្តវេន?

### ១. កម្មសិទ្ធិបញ្ញា

ប្រទេសលោកខាងលិចជាប្រទេស ដែលមានការវិវត្តជឿនលឿនជាងប្រទេសមួយចំនួនក្នុងសកលលោក តែងលើកស្ទួយនិងឱ្យតម្លៃខ្ពស់ទៅលើកម្មសិទ្ធិបញ្ញានេះណាស់ ព្រោះអ្នកទាំងនោះបានបណ្តុះ និងបំផុសឱ្យមានការអភិវឌ្ឍគំនិតនៅក្នុងសង្គមដែលនេះជាចំណែកមួយបម្រើប្រយោជន៍ដល់សកលជនទាំងមូល។

កម្មសិទ្ធិបញ្ញា សំដៅទៅលើប្រភេទនៃទ្រព្យសម្បត្តិដែលផ្តើមចេញពីការបង្កើតនូវគំនិតច្នៃប្រឌិតរបស់មនុស្ស។[108] កម្មសិទ្ធិបញ្ញា ជាបណ្តុំនៃសិទ្ធិដែលត្រូវបានទទួលស្គាល់ដោយច្បាប់ ព្រមទាំងទទួលបានការការពារដោយផ្ទាល់ ឬដោយប្រយោលពីច្បាប់ទៅលើស្នាដៃដែលបានបង្កើតឡើងនោះ។[109] ប៉ុន្តែនៅក្នុងចំណុចនេះនឹងផ្តោតទៅលើតែកម្មសិទ្ធិបញ្ញានៃសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលតែប៉ុណ្ណោះ ថាតើច្បាប់បានចែង

---

[105] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២៤៨។

[106] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២៤៨។

[107] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៣៩។

[108] លឹម យុសួ, *អ្វីជាកម្មសិទ្ធិបញ្ញា* (ភ្នំពេញ, ២០២១), ១៦។

[109] ទេព សុខ, *នីតិកម្មបញ្ញា* (ភ្នំពេញ, ២០២១), ២។

យ៉ាងដូចម្តេចខ្លះអំពីការទទួលបន្តនូវស្នាដៃ ដែលជាផលិតផលវប្បធម៌កើតចេញពីស្នាដៃអ្នកនិពន្ធ អ្នកសម្តែង និងផលិតករ?

មាត្រា២ នៃច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល បានឱ្យនិយមន័យអ្នកនិពន្ធថា ជាបុគ្គលដែលបង្កើតបានស្នាដៃ។ ចំណែកឯសិទ្ធិប្រហាក់ប្រហែល សំដៅដល់សិទ្ធិអ្នកសម្តែង សិទ្ធិផលិតករហ្វូណូក្រាម និងសិទ្ធិអង្គភាពទូរផ្សាយ។ ដែលក្នុងនោះផលិតករហ្វូណូក្រាម សំដៅដល់បុគ្គលដែលផលិតបានឬបានថតបញ្ចូល សម្លេងនៃការសម្តែង ឬសំឡេងផ្សេងៗទៀត ឬនិមិត្តសញ្ញានៃសំឡេង ក្រៅពីទម្រង់នៃការថតបញ្ចូលជាខ្សែភាពយន្ត ឬស្នាដៃដែលបង្កើតឡើងដោយមានរូបភាពតគ្នាជាឈុតៗភ្ជាប់គ្នា បង្កើតបានជាចលនាអាចឱ្យមើលឃើញបាន។[110] រីឯអង្គភាពទូរផ្សាយ សំដៅទៅលើស្ថានីយវិទ្យុ ទូរទស្សន៍ ទូរទស្សន៍ខ្សែកាប ឬផ្កាយរណប។[111] បុគ្គលទាំងអស់នេះហើយ ដែលត្រូវទទួលបានការការពារពីច្បាប់ ពាក់ព័ន្ធទៅនឹងសិទ្ធិលើកម្មសិទ្ធិបញ្ញា។

អ្នកនិពន្ធស្នាដៃជាអ្នកទទួលបាននូវសិទ្ធិជាម្ចាស់កម្មសិទ្ធិផ្តាច់មុខទៅលើស្នាដៃនោះ[112] ហើយសិទ្ធិរបស់អ្នកនិពន្ធត្រូវបានការពារចាប់តាំងពីថ្ងៃដែលស្នាដៃនោះបានបង្កើតឡើង ដែលកិច្ចការពារនោះមានរយៈពេលអស់មួយជីវិតរបស់អ្នកនិពន្ធ បន្ថែមពីលើរយៈពេល៥០ (ហាសិប)ឆ្នាំទៀត ក្រោយថ្ងៃទទួលមរណភាពរបស់អ្នកនិពន្ធ[113]។ ដោយឡែក នៅពេលអ្នកនិពន្ធទទួលមរណភាព ស្នាដៃទាំងនោះនឹងត្រូវផ្ទេរទៅឱ្យទាយាទរបស់អ្នកនិពន្ធ[114] ដែលក្នុងនោះរួមបញ្ចូលទាំងសហព័ទ្ធដែលជាសន្តតិជនជានិច្ចរបស់មតកជនផងដែរ។ បើមានមតកសាសន៍នឹងធ្វើការផ្ទេរដូចមានចែងក្នុងមតកសាសន៍នោះ ប៉ុន្តែប្រសិនបើគ្មានមតកសាសន៍ទេនោះរដ្ឋដែលតំណាងដោយក្រសួងវប្បធម៌និងវិចិត្រសិល្បៈជាអ្នកគ្រប់គ្រងសិទ្ធិនោះ។[115]

### ២. ទំនាក់ទំនងញាតិពន្ធ

យោងតាមមាត្រា៣ នៃច្បាប់ស្តីពីឯកពន្ធភាពបានចែងថា ចំណងអាពាហ៍ពិពាហ៍ត្រូវរំលាយក្នុងករណីដែលសហព័ទ្ធណាមួយស្លាប់។ ប៉ុន្តែអាហារកាតព្វកិច្ចរវាងញាតិនៅតែមានរវាងសហព័ទ្ធនៅរស់ជាមួយនឹងញាតិរបស់សហព័ទ្ធដែលបានទទួលមរណភាព លើកលែងតែករណីដែលសហព័ទ្ធនៅរស់នោះមានចំណងអាពាហ៍ពិពាហ៍ថ្មី ឬបានបង្ហាញឆន្ទៈក្នុងការផ្តាច់នូវទំនាក់ទំនងញាតិពន្ធតាមផ្លូវតុលាការតែប៉ុណ្ណោះ។[116]

[110] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល, លេខ នស/រកម/០៣០៣/០០៨, ០៥ មីនា ២០០៣, មាត្រា ២។
[111] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល, លេខ នស/រកម/០៣០៣/០០៨, ០៥ មីនា ២០០៣, មាត្រា ២។
[112] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល, លេខ នស/រកម/០៣០៣/០០៨, ០៥ មីនា ២០០៣, មាត្រា ១៨។
[113] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល, លេខ នស/រកម/០៣០៣/០០៨, ០៥ មីនា ២០០៣, មាត្រា ៣០។
[114] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល, លេខ នស/រកម/០៣០៣/០០៨, ០៥ មីនា ២០០៣, មាត្រា ៣៣។
[115] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល, លេខ នស/រកម/០៣០៣/០០៨, ០៥ មីនា ២០០៣, មាត្រា ៣៣។
[116] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៨១

នេះជាមូលហេតុ ដែលបើកឱកាសឱ្យសហព័ទ្ធនៅរស់មានលក្ខណៈពិសេសប្លែកពីសហព័ទ្ធក្នុងករណីលែងលះ ព្រោះថា បើសិនជាសហព័ទ្ធក្នុងករណីលែងលះ ទំនាក់ទំនងញាតិពន្ធគឺត្រូវបានកាត់ផ្តាច់តែម្តងនៅពេលចំណងអាពាហ៍ពិពាហ៍ត្រូវបានរំលាយ។ ដោយឡែកបើចំពោះសហព័ទ្ធនៅរស់វិញ ឃើញថាទំនាក់ទំនងញាតិពន្ធគឺមិនត្រូវបានកាត់ផ្តាច់នោះទេ ដរាបណាសហព័ទ្ធនៅរស់មិនរៀបការជាថ្មី ឬមិនបានបង្ហាញពីបំណងចង់កាត់ផ្តាច់នូវទំនាក់ទំនងញាតិទេ។

ម្យ៉ាងទៀត ដោយហេតុថាទំនាក់ទំនងញាតិពន្ធរបស់សហព័ទ្ធនៅរស់មិនត្រូវបានកាត់ផ្តាច់ធ្វើឱ្យសហព័ទ្ធនៅរស់នោះមានលក្ខណៈសម្បត្តិជាសន្តតិជន។ ដោយហេតុថា ប្រសិនបើមរណភាពរបស់សហព័ទ្ធម្ខាងធ្វើឱ្យផ្តាច់ទំនាក់ទំនងញាតិពន្ធដូចក្នុងករណីលែងលះ នោះសហព័ទ្ធដែលនៅរស់នោះក៏ពុំមានលក្ខណៈសម្បត្តិជាសន្តតិជនបានដែរ។

សរុបមក ប្រសិនបើគ្មានការសុំផ្តាច់ទំនាក់ទំនងញាតិពន្ធតាមផ្លូវតុលាការទេ នោះទំនាក់ទំនងញាតិពន្ធរបស់សហព័ទ្ធនៅរស់មិនត្រូវបានផ្តាច់ក្រោមមូលហេតុនៃការស្លាប់របស់សហព័ទ្ធឡើយ ជាពិសេសទៀតនោះគឺសហព័ទ្ធនៅតែមានលក្ខណៈសម្បត្តិជាសន្តតិជន។

# សេចក្តីសន្និដ្ឋាន

តាមរយៈការបកស្រាយ និងការសិក្សាស្រាវជ្រាវលើប្រធានបទខាងលើ រួចមកឃើញថាប្រធានបទខាងលើបានបង្ហាញយ៉ាងច្បាស់ពីសិទ្ធិនិងកាតព្វកិច្ចមួយចំនួនរបស់សហព័ទ្ធ។ ថ្វីបើប្រធានបទនេះស្ថិតក្នុងនីតិគ្រួសារមែនតែតាមការវិវត្តរបស់សង្គម សិទ្ធិនិងកាតព្វកិច្ចមួយចំនួនត្រូវបានគ្រប់គ្រងដោយច្បាប់ដទៃទៀតដូចជានីតិកម្មសិទ្ធិបញ្ញា ច្បាប់ពាណិជ្ជកម្ម និងក្រមព្រហ្មទណ្ឌជាដើម។

ការលែងលះបានធ្វើឱ្យចំណងអាពាហ៍ពិពាហ៍ត្រូវបាននត្ថិភាព ជាហេតុធ្វើឱ្យមានការបែងចែកទ្រព្យសម្បត្តិ ការលែងប្រើប្រាស់ឈ្មោះសហព័ទ្ធម្ខាង ការរៀបអាពាហ៍ពិពាហ៍ថ្មី និងជាប់មកនូវអាហារកាតព្វកិច្ចចំពោះសហព័ទ្ធទៀតផង។ ប៉ុន្តែការលែងលះមិនបានធ្វើឱ្យមានការផ្លាស់ប្តូរអត្តាធីនភាពរបស់អនីតិជន និងសញ្ជាតិដែលបានពីការរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ឡើយ។ ក្នុងទំនាក់ទំនងឪពុកម្តាយនិងកូនវិញ ក្រោយពេលលែងលះគឺត្រូវកំណត់អំណាចមេបាជាការចាំបាច់ដើម្បីទទួលសិទ្ធិគ្រប់គ្រងកូន ហើយការកំណត់នេះអាចធ្វើតាមការព្រមព្រៀង ឬតាមតុលាការដែលពិនិត្យមើលប្រយោជន៍របស់កូនជាធំ។ ក្នុងករណីដែលសហព័ទ្ធម្ខាងមិនទទួលបានអំណាចមេបាក៏ឪពុក ឬម្តាយនោះនៅតែមានសិទ្ធិចូលជួបនិងប្រាស្រ័យទាក់ទងនឹងកូន រួមទាំងកាតព្វកិច្ចក្នុងការផ្តល់អាហារកិច្ចដល់កូនជានិច្ច ព្រមទាំងមានសិទ្ធិក្នុងការទាមទារអំណាចមេបាមកវិញ។ ចំពោះឪពុកម្តាយដែលមានអំណាចមេបាត្រូវទទួលខុសត្រូវចំពោះទង្វើកូនទាំងកិច្ចសន្យា និងអំពើអនីត្យានុកូលរួមទាំងសំណងផ្សេងៗដែលកើតចេញពីទង្វើអនីត្យានុកូលរបស់កូន។

ចំពោះករណីដែលសហព័ទ្ធម្ខាងទទួលមរណភាពក៏ធ្វើឱ្យចំណងអាពាហ៍ពិពាហ៍ត្រូវបានរំលាយ តែវាពិសេសត្រង់ថាទំនាក់ទំនងញាតិមិនត្រូវបានកាត់ផ្តាច់ទេ លើកលែងមានការស្នើសុំ។ មរណភាពរបស់សហព័ទ្ធបានធ្វើឱ្យមានការបើកសន្តតិកម្មដោយមានការបែងចែកមត៌ក រួមទាំងសិទ្ធិខាងកម្មសិទ្ធិបញ្ញា។ ក្នុងករណីនេះដែរ បន្ទាប់ពីសិក្សាពីការវិវត្តនៃសិទ្ធិរបស់សហព័ទ្ធ ឃើញថាច្បាប់បច្ចុប្បន្នបានផ្តល់នូវសិទ្ធិពិសេសដល់សហព័ទ្ធនៅរស់ជាសន្តតិជនលំដាប់ទី១ជានិច្ច ក្នុងការប្រកួតប្រជែងក្នុងចំណែកមត៌ក។ ម្យ៉ាងទៀត សហព័ទ្ធនៅរស់មានសិទ្ធិទទួលបានសិទ្ធិលើភាគបម្រុងជានិច្ច ទោះក្នុងកាលៈទេសៈបែបណាក៏ដោយ។ ថ្វីបើសហព័ទ្ធនៅរស់មានសិទ្ធិពិសេសដូចដែលបានចែងក៏ដោយ ក៏សហព័ទ្ធខ្លួនឯងនោះអាចបដិសេធមិនទទួលយកមត៌កបានដែរនៅពេលដែលមានការបែងចែកសន្តតិកម្ម។ នៅក្នុងការអនុវត្តជាក់ស្តែង ភាគច្រើនគឺតែងតែដោះស្រាយតាមការព្រមព្រៀង ទាំងការបែងចែកទ្រព្យសម្បត្តិ អំណាចមេបា អាហារកិច្ច សិទ្ធិបីបាច់កូនជាដើម ក្រោយការលែងលះ និងមរណភាពរបស់នីតិសង្វាសជន។

# អនុសាសន៍

ឆ្លងតាមការបកស្រាយ និងស្រាវជ្រាវរយៈពេលកន្លងមកទៅលើប្រធានបទខាងលើ អាចសង្កេតឃើញថា ច្បាប់ដែលបានដាក់ចេញនិងការអនុវត្តជាក់ស្តែងនៅក្នុងសង្គម គឺនៅមិនទាន់មានភាពបំពេញឱ្យគ្នាទៅវិញទៅមកបានគ្រប់ជ្រុងជ្រោយនៅឡើយទេ ពោលគឺខ្វះនូវស្តង់ដារឬបន្ទាត់ដើម្បីវាស់វែងលើបញ្ហាក្នុងនីតិគ្រួសារ។ ហេតុដូចនេះគប្បីកែប្រែលើចំណុចមួយចំនួនដូចខាងក្រោម៖

- បង្កើនការលើកទឹកចិត្តក្នុងការចុះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធ ដោយយល់ថាការចុះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធជារឿងត្រឹមត្រូវហើយមិនមែនបង្កើតការសង្ស័យរវាងគ្នានិងគ្នាឡើយ ព្រោះថាតាមអនុវត្តរបស់ប្រទេសជឿនលឿនគឺការចុះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធគឺជារឿងមួយដែលសំខាន់និងចាំបាច់។ ដោយហេតុថាវាកំណត់នូវប្រភេទនៃទ្រព្យសម្បត្តិដាច់ដោយឡែករបស់សហព័ទ្ធដែលមានមុនចំណងអាពាហ៍ពិពាហ៍។
- បង្កើតរូបមន្តជាក់លាក់មួយសម្រាប់គណនា និងកំណត់តម្លៃអាហារកិច្ចដោយហេតុថាច្បាប់កម្ពុជាមិនទាន់មានការកំណត់ចេញជាការគណនាមួយបានច្បាស់លាស់នោះទេ។ប្រសិនបើមានការចងនូវរូបមន្តណាមួយទុកច្បាស់លាស់ នោះវានឹងបង្កើតឱ្យមានជាគោលការណ៍ស្របគ្នានិងរួមគ្នាមួយ ដែលបង្កភាពងាយស្រួលសម្រាប់តុលាការក៏ដូចជាផ្តល់នូវតម្លាភាព និងភាពត្រឹមត្រូវទៅលើការចាត់ចែងនិងបែងចែករបបអាហារកិច្ច នៅពេលដែលចំណងអាពាហ៍ពិពាហ៍ត្រូវបានរំលត់ជាស្ថាពរ។
- កំណត់កត្តាដែលសន្មតថាជាឧត្តមប្រយោជន៍ចំពោះកូនមានអ្វីខ្លះនៅពេលកំណត់អំណាចមេបា ព្រោះវាជាបន្ទាត់មួយដើម្បីវាស់វែងឱ្យច្បាស់ពីការកំណត់ផលប្រយោជន៍របស់កូនជាអនីតិជន។
- បង្កើតឱ្យមានសាលក្រមដែលអាចមហាជនចូលអានសេចក្តីសម្រេចដើម្បីពិចារណាមលើការសម្រេចរបស់តុលាការ។
- គប្បីបង្កើតតុលាការពិសេសខាងនីតិគ្រួសារដើម្បីដោះស្រាយបញ្ហានីតិសាស្ត្រឱ្យបានរហ័សមានគុណភាពជាយុត្តិសាស្ត្រសម្រាប់សំណុំរឿងនីតិគ្រួសារ។

# ឯកសារយោង

# ឯកសារយោង

## ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត


- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។
- ច្បាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, លេខ នស/រកម/១១១៩/០១៧, ៨ តុលា ២០១៩។
- ច្បាប់ស្តីពីសញ្ជាតិ, លេខ នស/រកម/០៦១៨/០០៨, ២១ មិថុនា ២០១៨។
- ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណី ដែលមិនមែនជាបណ្តឹង, លេខ នស/រកម/០៧១០/០១៣, ០៩ មិថុនា ២០១០។
- ច្បាប់ស្តីនីតិវិធីទាក់ទងនឹងឋានៈបុគ្គល,លេខ នស/រកម/០៦១០/០០៨, ២៦ មេសា ២០១០។
- ច្បាប់ស្តីពីសុំកូនអន្តរប្រទេស, លេខ នស/រកម/១២០៩/០២៤, ២៣ តុលា ២០០៩។
- ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។
- ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល, លេខ នស/រកម/០៣០៣/០០៨, ០៥ មីនា ២០០៣។
- អនុក្រឹត្យស្តីពីនីតិវិធី និងលក្ខខណ្ឌនៃការសុំលះបង់សញ្ជាតិខ្មែរ, លេខ ២៨៨ អនក្រ.បក, ៣១ ឧសភា ២០១៣។


## ច្បាប់និរាករណ៍


- ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, ក្រឹត្យច្បាប់លេខ ៥៦ ក្រ, ២៦ កក្កដា ១៩៨៩។
- ក្រមរដ្ឋប្បវេណីចាស់ ឆ្នាំ១៩៦៧។


## ច្បាប់បរទេស


- ច្បាប់គ្រួសារប្រទេសអូស្ត្រាលី១៩៧៥, លេខ ៥៣ នៃឆ្នាំ១៩៧៥, ១២ មិថុនា ១៩៧៥។
- ក្រមរដ្ឋប្បវេណីជប៉ុនឆ្នាំ១៨៩៦។
- ក្រមរដ្ឋប្បវេណីរដ្ឋកាលីហ្វ័រញ៉ាឆ្នាំ ១៨៧២។


## សៀវភៅដែលបានបោះពុម្ពផ្សាយ


- ក្រសួងយុត្តិធម៌ និងក្រុមការងារជទៃ.*សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី*, ភាគ៥: គម្ពីទី៧, ភ្នំពេញ.២០១០។
- ក្រសួងយុត្តិធម៌ និងក្រុមការងារជទៃ.*សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី*, ភាគ៦: គម្ពីទី៨-ទី៩, ភ្នំពេញ.២០១០។
- ទេព សុខ.*សៀវភៅនីតិកម្មបញ្ញា*, បោះពុម្ពលើកទី១, ភ្នំពេញ.២០២១។
- ប៊ុត នាង.*ប្រមូលភាសិតខ្មែរ*. បោះពុម្ពលើកទី១, ភ្នំពេញ.២០២០។
- លឹម យូសួ.*អ្វីជាកម្មសិទ្ធិបញ្ញា*, ភ្នំពេញ.២០២១។
- អ៊ីវ ប៉ូលី.*អាហារកាតព្វកិច្ច*, ភ្នំពេញ.២០១៧។

- ឥន្ទ ឱមសាររម៉េង.*ប្រវត្តិទស្សនៈសាសនា សីលធម៌ នយោបាយ*, បោះពុម្ពលើកទី១, ភ្នំពេញ.២០១៤។


**គេហទំព័រ**


- ក្រុមមេធាវីកម្ពុជាសហប្រតិបត្តិការអន្តរជាតិ. ២០២១. យល់ដឹងផ្នែកច្បាប់៖ ការកំណត់អំពីសិទ្ធិជួបប្រាស្រ័យទាក់ទងកូនដោយតុលាការ. *ក្រុមមេធាវីកម្ពុជាសហប្រតិបត្តិការអន្តរជាតិ*, http://ciclg.com/cn/article/250 (ថ្ងៃចូលមើល៖ ០៨ ឧសភា ២០២២)។
- Alexandria White. "Who's responsible for your kids' unauthorized charges?." CNBC. 26 January 2021, https://www.cnbc.com/select/whos-responsible-for-kids-unauthorized-credit-card-charges/ (ថ្ងៃចូលមើល៖ ១៨ មិថុនា ២០២២)
- Parental Liability for the Actions of Children | San Jose Personal Injury Lawyers.CMA Law. n.d., https://www.cmalaw.net/parental-liability-for-the-actions-of-children.html ។ (ថ្ងៃចូលមើល៖ ១៨ មិថុនា ២០២២)

# ឧបសម្ព័ន្ធ

## បញ្ជីរាយនាមឧបសម្ព័ន្ធ

- ឧបសម្ព័ន្ធទី១ ៖ ក្រមរដ្ឋប្បវេណីចាស់ឆ្នាំ១៩៦៧។
- ឧបសម្ព័ន្ធទី២ ៖ ក្រមរដ្ឋប្បវេណីរដ្ឋកាលីហ្វ័រញ៉ាឆ្នាំ ១៨៧២។
- ឧបសម្ព័ន្ធទី៣ ៖ ច្បាប់គ្រួសារប្រទេសអូស្ត្រាលី១៩៧៥, លេខ ៥៣ នៃឆ្នាំ១៩៧៥, ១២ មិថុនា ១៩៧៥។
- ឧបសម្ព័ន្ធទី៤ ៖ ប្រកាសអន្តរក្រសួងស្តីពីការផ្តល់សេវាសាធារណៈនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ លេខ៥៥១ សហវ.ប្រក ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២០។
- ឧបសម្ព័ន្ធទី៥ ៖ កម្រងបញ្ជីស្តីពីការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។
- ឧបសម្ព័ន្ធទី៦ ៖ ដីកាបង្គាប់ឱ្យផ្តល់អាហារកាតព្វកិច្ច លេខ០១ "ក" ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៤។

# ឧបសម្ព័ន្ធទី១

GENERALE ... AIR CAMBODGE

ការសិក្សា ច្បាប់ គ្រប់ មាត្រា ទាំងអស់

ក្នុង

# ក្រមរដ្ឋប្បវេណី

របស់ អេង - សុត
នៅ ក្រសួង យុត្តិធម៌

បោះពុម្ពលើកទីមួយ

ព.ស. ២៥១០ គ.ស. ១៩៦៧

បិតុភាពសុំ នោះ ត្រូវកាត់ ឲ្យប្រគល់ កូនសុំ ដែលនៅ ក្នុងអនីតិភាព នោះ ឲ្យបុគ្គលណា ម្នាក់ រក្សា ឬ ឲ្យនៅ ក្នុងអាណាព្យាបាល នៃបុគ្គលណា ម្នាក់ផង ។

មាត្រា ៣៣៤.- សេចក្តីវិនិច្ឆ័យ នៃសាលាក្រម នេះ ត្រូវយក ទៅ ចុះ ត្រង់រឹមទំព័រ នៃសញ្ញាប័ត្រ កំណើត របស់កូនសុំ ព្រមទាំងចុះ លើរឹមទំព័រ នៃកិច្ចសន្យា សុំកូន ដែលរក្សាទុក ក្នុងបណ្ណសារដ្ឋាន នៃឃុំ នោះ ផង ។

## ជំពូក ៦

## អំពី អំណាច មេបា

មាត្រា ៣៣៥.- ដែលហៅថា អំណាច មេបា នោះ គឺសិទ្ធិ និង អំណាច ទាំងអស់ ដែលច្បាប់ ប្រគល់ ដល់ឪពុក និង ម្ដាយ ឲ្យយក សិទ្ធិ និង អំណាច នេះ ទៅប្រើប្រាស់ លើរូបកាយ និង លើទ្រព្យសម្បត្តិ របស់កូនអនីតិជន ដើម្បីឲ្យឪពុក និង ម្ដាយ នោះ អាច បំពេញ ករណីយកិច្ច របស់ខ្លួន ជាឪពុកម្ដាយ បាន ។

មាត្រា ៣៣៦.- ក្នុងរយៈវេលា ដែលឪពុកម្ដាយ នៅមាន អាពាហពិពាហ នៅឡើយ. មានតែឪពុក ម្នាក់ ប៉ុណ្ណោះ ទេ ដែលមាន អំណាចមេបា ។

មាត្រា ៣៣៧.– កាលណាឪពុក ស្លាប់ទៅ ឬ ក៏ តុលាការ បាន កាត់សេចក្ដី ឲ្យ ឪពុក នោះ ដូស អំណាច ទៅ ឬ ក៏ ឪពុក នោះ ជាប់គំហាត់ របស់ច្បាប់, ក្នុងករណី នេះ, ម្ដាយ ត្រូវទទួល អំណាចមេបា នេះ ឡើង ។

មាត្រា ៣៣៨.– កាលបើ ឪពុក និង ម្ដាយ ត្រូវ លែងលះគ្នា, អំណាចមេបា នេះ ត្រូវ បានទៅ ម្ដាយ ចំពោះ តែ កូន ដែលប្រគល់ ឲ្យម្ដាយ រក្សា ។

មាត្រា ៣៣៩.– ក្នុងរយៈវេលា ដែលឪពុក បាត់ខ្លួន នៃកាយពិការ មិនទាន់រលាយ នៅឡើយ អំណាចមេបា ត្រូវ បានទៅ ប្រពន្ធ ទាន់ស្លាទី១ ត្រួតត្រា លើកូន ទាំងឡាយ ដែលកើត អំពីប្ដី ហើយ ដែល រស់នៅ ក្នុងផ្ទះ ដែលប្រពន្ធ នោះ ត្រួតត្រា ។

មាត្រា ៣៤០.– អំណាចមេបា នោះ គឺសិទ្ធិ ឃុំឃាំង កូន, សិទ្ធិ រៀនប្រដៅ កូន និង សិទ្ធិ គ្រប់គ្រង ទ្រព្យសម្បត្តិ របស់កូន ។

## ផ្នែកទី ១

### អំពី សិទ្ធិ ឃុំឃាំង

មាត្រា ៣៤១.– ដើម្បីឃុំឃាំង កូន, អ្នកមាន អំណាចមេបា ត្រូវធ្វើ ពាក្យ ជាលាយល័ក្ខអក្សរ សុំទៅ ចាងហ្វាងសាលាដំបូង;ចាងហ្វាង

កំបញ្ញា ឲ្យចាប់ កូន នោះ ហើយ ចុះ ហត្ថលេខា លើដីកា ឃុំ ។

មាត្រា ៣៤២.- ចាងហ្វាងសាលាដំបូង, មុន នឹងបញ្ញា ឲ្យ ចាប់, អាច ហៅ អ្នក ដែលប្ដឹងសុំ ឲ្យឃុំឃាំង នោះ មក សួរពី ហេតុ ផល ដែលខ្លួន យល់ឃើញ ថា មានប្រយោជន៍សិន បាន, និង ឲ្យ ដំបូន្មាន ដែលខ្លួន យល់ឃើញ ថា គួរឲ្យ បាន ជាដរាប ។

បើ អ្នកប្ដឹង នៅតែ ទទូចសុំ ឲ្យឃុំ ដដែល ចាងហ្វាងសាលាដំបូង នឹងប្រកែក មិនព្រម ទទួល ពាក្យ នោះ ពុំបាន ទេ; តែ ចាងហ្វាងអាច បន្ថយ កំណត់ ឃុំ នោះ ឲ្យនៅ ត្រឹមតែ មួយខែ មកវិញបាន ។

មាត្រា ៣៤៣.- កូន អនីតិជន អាយុ ១៦ ឆ្នាំ មិន អាច ត្រូវ ជាប់ឃុំ លើស ពីមួយ ខែ ម្ដងៗ តៗ គ្នា បាន ទេ ។

អនីតិជន អាយុ លើស ពី ១៦ ឆ្នាំ មិន អាច ត្រូវជាប់ឃុំ លើស ពី ៦ខែ ម្ដងៗ តៗ គ្នា បាន ដែរ; នីតិកាល របស់វា នាំ ឲ្យ ដោះ វា ចេញ ពីឃុំ មួយរំពេច ។

មាត្រា ៣៤៤.- ប្រសិនបើ ឪពុក ប្ដឹង សុំ ឲ្យដាក់ឃុំ កូន ដែល កើត ពីខ្លួន, ប៉ុន្តែជាកូន នឹងប្រពន្ធ ដើម, ចាងហ្វាងសាលាដំបូង អាច ប្រកែក មិន ឃុំ តាមពាក្យសុំ បាន ។

ចាងហ្វាង អាច ប្រកែក មិនព្រម ឃុំ តាមពាក្យ សុំ បាន វេលាណា បើ អ្នក ដែលប្ដឹង នោះ សុំ ឲ្យ ដាក់ឃុំ កូន ដែលខ្លួន មិនមែន ជា ឪពុក

និង មិនមែន ជា ម្ដាយ ។

មាត្រា ៣៤៥.– ជន ដែលសុំ ឲ្យឃុំ កូនខ្លួន អាច សុំ ឲ្យដោះ វិញ ភ្លាម មួយរំពេច បាន ។

ជន ដែលបានទទួល អំណាចមេបា ជំនួស ជន ដែលប្ដឹង ឲ្យឃុំ កូន នោះ មាន សិទ្ធិ នឹងសុំ ឲ្យដោះ ចេញ ពីឃុំ វិញ បាន តាំង ពីថ្ងៃ ដែលកូន នោះ ជាប់ឃុំ មក ។

មាត្រា ៣៤៦.– ចាងហ្វាងសាលាដំបូង អាច ប្រកែក មិនព្រម ដាក់ឃុំ កូន នោះ បាន, ប្រសិនបើ ឃើញ ថា អ្នកប្ដឹង នោះ មាន សតិបញ្ញា ទន់ខ្សោយ ឬ ក៏ មាន វ័យ ជរា ហើយ ។ ចាងហ្វាង អាច នឹង ប្រកែកយ៉ាងនេះ បាន លុះណាតែ ខ្លួន បានកោះ អ្នកប្ដឹង នោះ ឲ្យចូល ខ្លួន មក ; ក្នុងករណី នេះ ចាងហ្វាង ត្រូវ អធិប្បាយ អំពីហេតុ ដែលខ្លួន ប្រកែកមិនព្រម ឃុំ នេះ ឲ្យសព្វគ្រប់ ដើម្បីជូន សាលាឧទ្ធរណ៍ ពិនិត្យ តទៅ ប្រសិនបើ គេ ឧទ្ធរណ៍ ។

មាត្រា ៣៤៧.– បើពេលណា មាន ឧទ្ធរណ៍ ចាងហ្វាង សាលាឧទ្ធរណ៍ត្រូវ ជំនុំះ ក្នុងរយៈវេលា ១០ ថ្ងៃ ចាប់តាំង ពីថ្ងៃ ដែលបានទទួល បណ្ដឹងឧទ្ធរណ៍ ដែលក្រឡាបញ្ជីសាលាដំបូង ត្រូវបញ្ជូន ជាប្រញាប់ ។ សាលាឧទ្ធរណ៍អាច កាត់សេចក្ដី ឲ្យដោះ អំណាចមេបា ពីជន ដែលប្ដឹង នោះ ដោយចិត្តឯង បាន ។ បណ្ដឹងសាទុក្ខ អំពីសាលក្រម នេះ

មិនអាច នាំ ឲ្យមាន ប្រតិបត្តិ នូវសាលក្រម ទាំងលើ នេះ បាន ទេ ។

មាត្រា ៣៤៨.– និតិវិធី ដែលស្តី ពីដាក់ឃុំ កូន ឬ ពីដោះ កូន ចេញ ពីឃុំ ព្រមទាំងនីតិវិធីស្តី អំពីក្តី ជាន់សាលាឧទ្ធរណ៍ ទាំងអស់នេះ ត្រូវឲ្យផុត ពីបង់ ប្រដាប់ក្តី ទិង មិនបាច់ ឲ្យមាន ទំរង់ការ អ្វី ៗ ទេ ។

## ផ្នែកទី ២

### សិទ្ធិ ដាក់ ទណ្ឌកម្ម

មាត្រា ៣៤៩.– ឪពុកម្តាយ មាន សិទ្ធិ ដាក់ ទណ្ឌកម្ម លើរូបកាយ កូន បាន ក៏ប៉ុន្តែ ដោយព្រហ្មវិហារធម៌ ។

មាត្រា ៣៥០.– ការដែលឪពុកម្តាយ ធ្វើបាប កូន ហួសដល់មាន របួស ស្នាកស្នាម ឬ ក៏ធ្វើឲ្យខូច សុខភាពរបស់វា ទុកជាទណ្ឌកម្ម ហួស ប្រមាណ ។ ទណ្ឌកម្ម ហួសប្រមាណ នេះនាំឲ្យមាន ទោស ជាបទអាជ្ញា ព្រមទាំង ដាពិរុទ្ធ នាំ ឲ្យតុលាការ កាត់សេចក្តី ឲ្យដកហូត អំណាចមេបា ពីឪពុក នោះ ដោយចិត្តឯង ក៏បាន, ដោយមាន ពាក្យ ពីអាជ្ញាធរ ឬ ពីញាតិ សន្តាន ណាមួយ ក៏ បាន ។ ប្រសិនបើ កូននោះ នៅ ជាអនីតិជន នៅឡើយ ហើយ មិនទាន់ អាច មាន អត្តាធិនភាព បាន ទេ តុលាការ ត្រូវរក អាណាព្យាបាល ឲ្យ កូន នោះ ។

មាត្រា ៣៨៨.– ចាងហ្វាង សាលាដំបូង អាច នឹងអនុញ្ញាត ឲ្យក្តី បាន លុះណាតែ ខ្លួន បានកោះ ហៅ ឪពុក និង កូន នោះ ឲ្យចូល មកផ្សះផ្សា ជាមុនសិន ។

ប្រសិនបើ ថ្ងៃ នេះ ចាងហ្វាង ផ្សះផ្សា មិនបាន ផល ទេ ចាងហ្វាង អាច នឹងកោះហៅ ឪពុក និង កូន មក ផ្សះផ្សា ក្នុងថ្ងៃ ក្រោយ ទៀត បាន ។

មាត្រា ៣៨៦.– ឪពុកម្តាយ ត្រូវផ្តល់ អាហារ, ពិភក្តិរក្សា, ចិញ្ចឹម អប់រំ កូន ឲ្យបាន ល្អ, មើល កិរិយាមារយាទវា ឲ្យបានត្រឹមត្រូវ, ឲ្យដំបូន្មាន ល្អ ដល់វា ។ ឪពុកម្តាយ ត្រូវ បង្រៀនកូន ឬ ត្រូវ ឲ្យកូន រៀនសូត្រ តាមសក្តិប្រាជ្ញា របស់វា ។

មាត្រា ៣៨៧.– ឪពុកម្តាយ ដែលថ្វស់ អំណាច មេបា អស់ ហើយ ត្រូវចេញ សោហ៊ុយ ស្បៀងអាហារ ហើយនិងចេញ សោហ៊ុយ ឲ្យកូន រៀនសូត្រ ទៀត ផង ។

ប៉ុន្តែ កូន មានខាន់ស្លា, ដែលកើត អំពីជន អភ័ព្វ នោះ ក្នុងរវាង ៣០០ថ្ងៃ ក្រោយថ្ងៃ ស្លាប់ នៃជន អភ័ព្វ នោះ ហើយ រស់, ត្រូវ ស៊ី មតក ផុតកាល បាន ។

សន្តតិជន ដែលត្រូវ កាត់ កាល់ ហើយ ត្រូវបង្វិល ចំណែកសន្តតិកម្ម ដែលខ្លួន បានទទួល រួចហើយ ព្រមទាំងផល និង ផលទុន ដែលខ្លួនបាន ហូតយក តាំងពីថ្ងៃ ដែលបែក សន្តតិកម្ម នោះ មកវិញ ។

មាត្រា ៤៩២.- ជន អភ័ព្វ អាច នឹងកាន់កាប់ ថែរក្សា នូវសន្តតិកម្ម ដែលបាន ទៅ កូនខ្លួន ដែលនៅ ក្នុងអនីតិភាព បាន ។

## ជំពូក ទី៣

## អំពីសន្តតិកម្ម ឥត បណ្តាំ

## ផ្នែក ទី ១

### អំពីលំដាប់ នៃការផ្ទេរ នូវសន្តតិកម្ម

មាត្រា ៤៩៣.- សន្តតិកម្ម ឥតបណ្តាំ ត្រូវផ្ទេរទៅឲ្យកូននៃខ្មោច; កូនទាំងនោះ ត្រូវ ចូលមក ទទួល ចំណែក នៃមតកនោះ ដោយការស្មើ ទោះកូន នោះ មានខាន់ស្លា ក្តី, កូន ដែលទើបនឹងបាន ធម្មានុរូបភាព ក្តី, កូន សុំ ក្តី, កូន ឥតខាន់ស្លា ដែលតុលាការ កាត់ ឲ្យទទួលស្គាល់ ក្តី, ឬ ដែលទទួល ពីចិត្ត ឯង ក្តី ។

បើកូន នោះ ស្លាប់, កូនទាំងឡាយ នៃខ្មោច នោះ ត្រូវ ចូលមក ទទួល មត៌ក ជាមួយ នឹង មាមីងរបស់ខ្លួន ជួស ឪពុកម្តាយ ខ្លួន ហើយ ចែក ភាគ នោះ ដល់បងប្អូនខ្លួន ស្មើៗគ្នា ទៀត ប្រសិនបើកូនទាំងឡាយ រស់នៅ ក្នុងគ្រា ដែលចែក សន្តតិកម្ម នោះ ។

មាត្រា ៤៩៤. បើ ខ្មោច នោះ គ្មាន កូន ទេ សន្តតិកម្ម ត្រូវ បានទៅ ឪពុកម្តាយ នៃខ្មោច ។ បើ ឪពុកម្តាយ នោះ នៅ ដោយខ្លួន ពីរគ្នា សន្តតិកម្ម ត្រូវចែក ពាក់កណ្ដាល ម្នាក់ ស្មើគ្នា ។

បណ្ដាជន ទាំងពីរ នាក់ នេះ បើម្នាក់ បានធ្វើ កាលកិរិយាហើយ អ្នករស់នៅ ត្រូវទទួល សន្តតិកម្ម ទាំងអស់ នោះ តែម្នាក់ឯង ។

បើឪពុក ជាជន បរទេស ហើយ ត្រូវទទួល មត៌ក ជាអចលនវត្ថុ ដែល ជាប់នៅ លើដី របស់ខ្មែរ, ឪពុកនោះ អាច នឹងទទួល មត៌ក នោះបាន លុះណាតែ ខ្លួន បាន សញ្ជាតូបនីយកម្មហើយៗបើ មិនទាន់ បាន សញ្ជាតូបនីយកម្ម ទេ, ការផ្ទេរ សន្តតិកម្ម នេះ ត្រូវធ្វើ តាមបទបញ្ញត្តិ នៃក្រម នេះ ។

មាត្រា ៤៩៥.- បើខ្មោច នោះ ឥត កូន, ឥត ឪពុក, ឥតម្តាយ ទេ, សន្តតិកម្ម នោះ ត្រូវបែង ជាពីរ ភាគ គឺមួយ ភាគ ត្រូវបានទៅ បុព្វញាតិខាងឪពុក, មួយភាគ ទៀត ត្រូវ បានទៅ បុព្វញាតិ ខាងម្តាយ ។

បុព្វញាតិ ណា ជិត ជាងគេ ត្រូវយក ភាគ ពាក់កណ្ដាល ដែល ត្រូវធ្លាក់ទៅ ជូនខ្លួន, តែបើ ប្ដី ប្រពន្ធ នៅបែកគ្នា ត្រូវចែក តាមសេចក្ដី

DIRECTION GENERALE ... CAMBODGE

បញ្ញតិ នៃមាត្រា មុន ថែមទៀត ។ បើ មាន បុព្វញាតិ ច្រើន រូប ត្រូវ ថ្នាក់ស្មើគ្នា ដែលទៅ ក្នុងជួរ ជាមួយគ្នា, បុព្វញាតិ ម្នាក់ៗ ត្រូវ បាន ភាគ ស្មើៗគ្នា ដែរ ។

មាត្រា ៤៨៦.- បើ ខ្មោច នោះ ឥត កូនចៅ, ឥត បុព្វញាតិ ទេ សន្តតិកម្ម ត្រូវ បានទៅ បងប្អូន ប្រុសស្រី ដោយភាគ ស្មើ, ទោះ ចំពោះតែ បងប្អូន នោះ មាន ឪពុកម្ដាយ ជាមួយគ្នា ។ ប្រសិនបើ ជាបងប្អូន ឪពុក ឬម្ដាយ ទីទៃពីគ្នា ទេ, បងប្អូន រួមឪពុកម្ដាយមួយ ត្រូវបានពីរភាគ, បងប្អូន រួមតែ ឪពុក ឬ រួមតែ ម្ដាយ ត្រូវបាន មួយ ភាគ ម្នាក់ ។ បើ បងប្អូន ដែល ត្រូវទទួល នោះ ស្លាប់ ត្រូវ កូន ចូលមក ទទួល ជាមួយ នឹងមាមីង របស់ ខ្លួន ជួស ឪពុកម្ដាយខ្លួន ហើយ ចែក ភាគ នោះដល់បងប្អូនខ្លួន ស្មើៗគ្នា ទៀត ប្រសិនបើ ខ្លួនរស់នៅ ទាំងអស់ក្នុងគ្រា ដែលចែក សន្តតិកម្មនោះ ។

មាត្រា ៤៨៧.- បើ ខ្មោច នោះ ឥត បុព្វញាតិ, ឥត បងប្អូន, ឥត កូន, ឥត បច្ឆាញាតិ ដែលកើត ពីខ្លួន ទេ, សន្តតិកម្ម ត្រូវ បានទៅ ប្រពន្ធ ដើម មានខាន់ស្លា ដែលរស់នៅ ហើយ ដែលមិន បានលែងគ្នា ។

មាត្រា ៤៨៨.- បើ ប្ដី ដែលស្លាប់ នោះ ឥត បុព្វញាតិ, ឥត បងប្អូន ប្រុសស្រី, ឥត បច្ឆាញាតិ នៃបងប្អូន, ឥត ប្រពន្ធដើម នៅ ជាង ក្រោយ ទេ, សន្តតិកម្ម នៃខ្មោច នោះ ត្រូវ បាន ទៅ ប្រពន្ធចុង ទាំងឡាយ ដែល មាន ខាន់ស្លា ហើយ ដែលមិន បានលែងគ្នា ដោយភាគ ស្មើគ្នា ។

មាត្រា ៤៩៩.- បើ ប្រពន្ធ ចុង ស្លាប់ ឥត កូនចៅ, ឥត បុព្វញាតិ, ឥត បង ប្អូន ប្រុសស្រី, ឥត បច្ឆាញាតិ នៃជន ទាំងនេះ ទេ, សន្តតិកម្ម ត្រូវ បានទៅ ប្ដី ដែលមិន បានលែងគ្នា ។

មាត្រា ៥០០.- បើ សហព័ទ្ធ ណា មុន នឹងស្លាប់ បានប្ដឹង សុំលែង សហព័ទ្ធ ដែលនៅរស់, ពាក្យបណ្ដឹង នេះ ត្រូវ មាន អានុភាព ដូចជាបានលែងគ្នា ដែរ, ប្រសិនបើ អ្នក ដែលមាន ប្រយោជន៍ ក្នុងរឿង នេះ សុំ តក្ដី ហើយ តុលាការ កាលជំនុំជំរះទៅ ក៏បានទុក ពាក្យ ដែល ប្ដឹង សុំលែង នោះ ថា ជាត្រូវដែរ ។

មាត្រា ៥០១.- បើ ខ្មោច នោះ ឥត កូនចៅ, ឥត បុព្វញាតិ, ឥត បង ប្អូន ប្រុសស្រី, ឥត បច្ឆាញាតិ របស់បងប្អូន, ឥត ប្រពន្ធដើម, ប្រពន្ធ ចុង សោះ ទេ, សន្តតិកម្ម ត្រូវ បានទៅ មា មីង គឺ បងប្អូន មាន ខាន់ស្លា, ឥតខាន់ស្លា ឬ សុំ នៃឪពុកម្ដាយ នៃខ្មោច នោះ ។

ក្នុងករណីយ នេះ បេតិកភ័ណ្ឌ ត្រូវ ចែក តាមចំនួន មនុស្ស កុំបី ចែក តាមសាខា ឡើយ ។

មាត្រា ៥០២ - បើ ឪពុកម្ដាយ មាន បងប្អូនបង្កើត ផង, បងប្អូន រួមតែ ឪពុក ឬរួមតែ ម្ដាយផង, បងប្អូន ដែលរួមតែ ម្ដាយ ឬ រួមតែ ឪពុក ត្រូវបាន ក្នុងម្នាក់ៗ តែពាក់កណ្ដាល ចំណែក ដែលត្រូវ បានទៅ បងប្អូន បង្កើត ។

បើបងប្អូន នៃឪពុកម្ដាយ របស់ខ្មោច (គឺមាមីងរបស់ខ្មោច) នោះ ស្លាប់ ទៅទៀត, កូន នៃមា, មីង នោះ ចូលមកទទួល មត៌ក ជួស ឪពុកម្ដាយខ្លួន តាមចំណែក ដែលត្រូវបានទៅ ឪពុកម្ដាយ កាលខ្លួន ប្រសិនបើកូនទាំងនោះ មាន ជីវិតរស់នៅ ដូចគេ ដែរ ។

មាត្រា ៥០៣.- បើខ្មោច នោះ ស្លាប់ ឥតកូនចៅ, ឥតបុព្វញាតិ ឥតបងប្អូន ប្រុសស្រី, ឥតបច្ឆាញាតិ របស់បងប្អូន, ឥតប្រពន្ធដើម, ឥតប្រពន្ធចុង, ឥតមាមីង, ឥតបងប្អូន ជីដូនមួយបង្កើត, សន្តតិកម្ម នោះ ត្រូវធ្លាក់ទៅ លើរដ្ឋ ។

## ផ្នែក ទី ២

### អំពី សិទ្ធិ នៃសហព័ទ្ធ ដែលនៅរស់

មាត្រា ៥០៤.- បើ ខ្មោច នោះ ស្លាប់ទៅ នៅតែ សហព័ទ្ធ មានទាំងស្លា ទីមួយ ដែលឥតបានលែងគ្នា ទេ និង កូន ម្នាក់ឬច្រើននាក់ ដែលកើត អំពី ប្ដី និង ប្រពន្ធ នោះ នៅ នឹងផ្ទះ នោះ ដែរ, បេតិកភណ្ឌ ទាំងប៉ុន្មានត្រូវ ដាក់ ឲ្យសហព័ទ្ធ នោះ គ្រប់គ្រង, ថែរក្សា, ប្រើប្រាស ជាប្រយោជន៍ នៃគ្រួសារ ។

មាត្រា ៥០៥.- កូន ដែលមាន ប្ដីប្រពន្ធ ហើយ មាន សិទ្ធិ ទារចំណែក នៃសន្តតិកម្ម របស់សហព័ទ្ធ ដែលស្លាប់ មុន នោះ ពីឪពុក ឬម្ដាយ ដែលរស់នៅ បាន ។

# កថាខណ្ឌទី ១

## សិទ្ធិនៃប្រពន្ធ មានខាន់ស្លា ដ៏មួយ ដែលជាមេជុះ

មាត្រា៨០៦.–បើប្ដីស្លាប់មុន, ប្រពន្ធដើមមិនអាច ទទួលកំដូរ ឬថែពាយ ដោយប្រាក់កោតប្រត្យ័ក្ស នូវគេបលខត្ត នៃសន្តតិកម្ម ដោយ ពុំសុំ អនុញ្ញាតពីក្រុមប្រឹក្សាញាតិ ឲ្យគេពិនិត្យពីសេចក្ដីត្រូវការ នៃសន្តតិកម្ម នោះបានឡើយ ។ ប្រពន្ធដើម បរិភោគផល និងផល ទុនបាន ។

មាត្រា ៨០៧.–ប្រពន្ធដើម អាច ប្រកែក មិន ទទួល សិទ្ធិ គ្រប់គ្រង និង បរិភោគ នូវបេតិកភណ្ឌ របស់គ្រួសារ បាន ។

មាត្រា៨០៨.–បើ ប្រពន្ធដើម នោះ មាន ប្ដី ទៀត, មាន ប្រុសសហាយ ឬ មាន គំនិត មារយាទ អាក្រក់, នោះ ត្រូវ ដូស់ខ្លួន ចាក សិទ្ធិ នេះ ។

មាត្រា ៨០៩.–អ្នក ដែលអាច ប្ដឹងសុំ ឲ្យដូស់ សិទ្ធិ ខាងលើ នេះ បាន គឺពួកញាតិ ឬ បងប្អូន នៃប្ដី ដែលមាន និតិភាព, កូនប្រុសច្បង ដែលមាន និតិភាព, ប្ដីនៃកូនស្រីច្បង, ក្រុមប្រឹក្សាញាតិ ។

ឯ កូន ដែលនៅ ក្នុងអនិតិភាព នោះ ត្រូវ ឲ្យមាន អាណាព្យាបាល តាមបទបញ្ញត្តិ នៃជំពូក ១ ភាគទី ៨ គន្ថីបុគ្គល ។

មាត្រា ៨១០.–បើ ប្រពន្ធដើម មាន ខាន់ស្លា លះបង់ សិទ្ធិ របស់ខ្លួន ឬ ត្រូវតុលាការ ជម្មោះ សិទ្ធិ គ្រប់គ្រង នោះ, ស្ត្រី នេះ ត្រូវ

យកបាន នៃទ្រព្យ ដើម របស់ខ្លួន គឺទ្រព្យ ដែលខ្លួន មាន កាលរៀបការ ឬ ទ្រព្យ ជាមត៌ក, ជាអំណោយ ឬ អច្ច័យទាន ដែលបានមក ស្ត្រី នោះ ផ្ទាល់ខ្លួន ក្នុងពេល ដែលមាន អាពាហ៍ពិពាហ៍ ។

ក្នុងករណី ដែលទ្រព្យ ដើម របស់ខ្លួន បាត់បង់ អស់ទៅ, ស្ត្រី នោះ ត្រូវ ឃាត់ យក ក្នុងមត៌ក ត្រឹមតែ តម្លៃ ទ្រព្យ ខ្លួន វិញ ។

មាត្រា៤១១ .– បើ ប្រពន្ធ ដើម មាន កាន់ស្លា ផង ទ្រព្យ ដើម សោះ ឬ ក៏ទ្រព្យ នោះ មិនគួរសម ដើម្បីចិញ្ចឹម ជីវិត ដោយសមគួរបាន, ស្ត្រី នោះ ត្រូវ មាន សិទ្ធិ បាន អាហារសោធន ។

មាត្រា៤១២.– ប្រពន្ធ ដើម មាន កាន់ស្លា ដែលប្រកបព្រម ដោយលក្ខខណ្ឌ ដូចដែលមាន បញ្ញត្តិ ក្នុងមាត្រា៤០៧នោះ ទើប គប្បីឲ្យ បាន អាហារសោធន ។ ថាបើ មារយាទស្រីនោះ ចូល ក្នុងលក្ខខណ្ឌ នៃ មាត្រា៤០៨ ទេ, ស្រី នោះ មិន ត្រូវ បាន អាហារសោធន ឡើយ ។

## កឋាខណ្ឌទី២

### អំពីសិទ្ធិ នៃប្រពន្ធ ដើម មាំងខាន់ស្លា ដែលអាះឥតក្បួន

៤១៣ .– ស្រី មេម៉ាយ ជាប្រពន្ធ ដើម មាន កាន់ស្លា ដែលនៅ រស់ នៃ ឈរ ផង កូន នោះមិន មាន សិទ្ធិ គ្រប់គ្រង និង បរិភោគ នូវ បេតិកភណ្ឌ របស់គ្រួសារ ទេ ។

មាត្រា ៨១៤.- ក្នុងករណីនេះ, ប្រពន្ធដើម មាន ខាន់ស្លា ដែលមេម៉ាយ គ្មាន កូន នោះ ត្រូវបានមួយភាគបីនៃទ្រព្យ សំបាច់, ក្រៅ ពីទ្រព្យ ដើម របស់ខ្លួន ។

មាត្រា ៨១៥ .- ទោះ ប្រពន្ធ នោះ មាន គំនិតមារយាទ អាក្រក់ ក្តី, មាន ប្តី ទៀត ក្តី ក៏មិន ត្រូវ ខូច សិទ្ធិ ដែល ត្រូវ បាន ចំណែក ក្នុងមត៌ក ដែល ខ្លួន ត្រូវ តែ បាន នោះ ឡើយ ។

មាត្រា ៨១៦.- បណ្តឹង ដែលប្តី បានប្តឹង សុំ លែង ប្រពន្ធ កាល ខ្លួន នៅរស់ នៅឡើយ នោះនឹងនាំ ឲ្យខូច សិទ្ធិ នៃស្រី នេះ បាន លុះ ណា តែ បណ្តឹងនោះ មានសាងហេតុ ថាប្រពន្ធ នោះ ផិតក្បត់ ។ ក្នុងករណីនេះ, ទើប ស្រី នោះ ត្រូវ បាត់ សិទ្ធិ ដែលត្រូវបាន ទ្រព្យ សំបាច់ នោះ ។

មាត្រា ៨១៧.- បទបញ្ញត្តិ នៃមាត្រា ៨០៧, ៨០៨, ៨១០, ៨១១, ៨១២ ត្រូវអនុវត្តិ លើ ប្រពន្ធ ដើម មាន ខាន់ស្លា ដែលមេម៉ាយ គ្មានកូន ដែរ ។

## កថាខណ្ឌទី៣

### អំសិទ្ធិ នៃប្រពន្ធចុង មានខាន់ស្លា

មាត្រា ៨១៨.- ក្នុងវេលា ដែលប្តី ស្លាប់ទៅ ហើយ ប្រពន្ធ ដើម រស់នៅ, ប្រពន្ធ ចុងទាំង ប៉ុន្មាន ព្រមទាំង កូន របស់ខ្លួន រៀងខ្លួន គាប

នៅ ទីផ្ទះ នៃគ្រួសារ ក្រោមអំណាច នៃប្រពន្ធ ដើម បាន ប្រសិនបើ ប្រពន្ធចុង ក៏សុខចិត្ត ហើយ ប្រពន្ធដើម ក៏ឥត ទទឹងទាស់ ដែរ ។ បើនៅជាមួយគ្នា ដូច្នេះ ប្រពន្ធចុង ទាំងអស់ នោះ ត្រូវ មាន សិទ្ធិ និងករណីយកិច្ច ទាំងឡាយ ដូច កាល ប្ដី រស់នៅ នោះ ដែរ ។

មាត្រា ៨១៩.– បើ ប្រពន្ធដើម មិន ឲ្យ ប្រពន្ធចុង នៅ ជាមួយផង ទេ ឬ បើ ប្រពន្ធចុង មិន ព្រមនៅ ទីផ្ទះក្រោមអំណាច ប្រពន្ធដើមទេ, ប្រពន្ធចុង ត្រូវ បាន តែ គ្រឿងប្រដាប់ សម្រាប់ខ្លួន ហើយនឹងទ្រព្យ ដើម ខ្លួន ព្រមទាំង បាន សោធន កល់ខែ ដើម្បីចិញ្ចឹម ជីវិតខ្លួន និង កូន អនីតិជន ទាំងឡាយ នៃខ្លួន ដែល កើត ក្នុងអាពាហ៍ពិពាហ៍ជាមួយនឹង ប្ដី នោះ ។

មាត្រា៨២០.– ប្រពន្ធចុង ណា មាន ប្ដីទៀត ឬ មានសហាយ, មាន គំនិត ការយោគ អាក្រក់, ប្រពន្ធចុង នោះ ត្រូវ ខានបាន សោធនចំណែកខ្លួន ហើយ សោធន មួយ ភាគ ទៀត ដែលត្រូវ បានទៅ កូនអនីតិជន គប នៅតែ ឲ្យ គេទៅ ទៀត បាន ដើម្បីចិញ្ចឹម កូន នោះ ប្រសិនបើ គេ ទុក អំណាច អាណាព្យាបាល នៃកូន នោះ ឲ្យ ប្រពន្ធចុងនោះ គេទៅ ទៀត

មាត្រា៨២១.– ដែលនឹងប្ដឹង សុំ ឲ្យលប់ សោធន នេះ ប្រពន្ធដើម ឬជន ណា មួយ បណ្ដាជន ដែលមានសំដែង ក្នុងមាត្រា៨០៩.

KH3

នោះ ពុំ បាន ជាដាច់

មាត្រា ៤៦២ .– បើ ប្រពន្ធដើម ត្រូវបណ្តេញ ចាកសិទ្ធិ ត្រួត ត្រាផង និង បរិភោគ បេតិកភណ្ឌ នៃគ្រួសារ ព្រោះតែ ឥត កូន ក្តី, ព្រោះ តុលាការ កាត់សេចក្តី ប្រែប្រួល ចាកសិទ្ធិ នោះ ក្តី ឬ គំមិន ព្រមទទួល សិទ្ធិ នោះ ក្តី, ប្រពន្ធចុង មាន វាចាស្នា ទាំងឡាយ ត្រូវ ដកយក ទ្រព្យ ដើម និង គ្រឿងប្រដាប់ ជារបស់ខ្លួន វិញ ហើយ ត្រូវ ទទួល ត្បាញាល ឱ្យ ទ្រព្យសម្បត្តិ ជាចំណែក នៃមតក ដែលត្រូវ បាន កូន អធិការ របស់ ខ្លួន រៀងខ្លួន ។

## ជំពូក ៤

## អំពីសន្តតិកម្ម មាន បណ្តាំ

### ផ្នែកទី ១

### បទបញ្ញត្តិ ទូទៅ

មាត្រា ៤៦៣.– ដែលហៅថា បណ្តាំ ឬ មតកសាសន៍ គឺសេចក្តី ដែលមនុស្ស ម្នាក់ ហៅថា ម្ចាស់បណ្តាំ សំដែង នូវឆន្ទៈ ណា មួយ របស់ ខ្លួន ដើម្បីឱ្យគេ យកទៅ ប្រតិបត្តិ ក្រោយពេល ដែលខ្លួន ស្លាប់ទៅ ។

មាត្រា ៤៦៤ .– បណ្តាំណាៗ ត្រូវបដិសេធ បាន ជាដាច់ ។

មាត្រា ៤៦៥ .– ម្ចាស់បណ្តាំ អាច តាំង អាណាព្យាបាល ឱ្យ

កូន អនីតិកាល របស់ខ្លួន, អាច បណ្ដាំ ឲ្យធ្វើ បុណ្យ សព នៃខ្លួន, អាច ចាត់ចែង នូវទ្រព្យសម្បត្តិ របស់ខ្លួន ទាំងអស់ ឬខ្លះ បាន មិន អាច, បើ ពោលឲ្យវែងឆ្ងាយ ទៅទៀត, ដាក់បណ្ដាំ, ឲ្យជំពូនាន ឬ យោបល់យ៉ាង ណា ដែលខ្លួន យល់ឃើញថា ជាទុសច សក្ដិសិទ្ធិ អាច ធ្វើ ឲ្យ ក្រាន របស់ខ្លួន បានសុខដុម នោះ មិនបាន រំលោភ ដល់គ្រួសារ ផង បានៗ

មាត្រា ៨២៦.– សេចក្ដីបណ្ដាំ ដែលបានធ្វើ ជាត្រឹមត្រូវ ត្រូវទុក ជាច្បាប់ ដែលត្រូវ តែសមាជិក ទាំងអស់ នៃគ្រួសារ គោរព តាម ។

មាត្រា ៨២៧.– បណ្ដាំ ឯណា ដែលផ្ដាំ ឲ្យចែក ទ្រព្យសម្បត្តិ បណ្ដាំ នោះ ឲ្យហៅថា កច្ច័យទាន, ជន ដែលត្រូវបាន អច្ច័យទាន នោះ ឲ្យហៅថា អច្ច័យលាភី ។

មាត្រា ៨២៨.– ដែល ហៅ ថាភាគ បំរុង នោះ គឺភាគ មួយ នៃ បេតិកភណ្ឌ ដែលម្ចាស់បណ្ដាំ ខ្លួន ឯង ក៏មិន អាច នឹងចាត់ចែង យ៉ាងណាៗ ដោយសេរី បានឡើយ; ឯភាគ ដ៏សេស ពីភាគ បំរុង ហៅថា ភាគ ទំនេរ ភាគទំនេរ នេះ ម្ចាស់បណ្ដាំ នឹងចង់ ឲ្យទៅ នរណា ក៏បាន តាមចិត្ត ។

មាត្រា ៨២៩.– ភាគបំរុង ដែលច្បាប់ បង្កើតឡើង នេះ គឺ ប្រយោជន៍ ឲ្យទាយាទ ខ្លះ ដែលមាន ភ័ព្វ ជាដំណែ បាន បរិភោគ ទាំងអស់ ឬខ្លះ ប្រសិនបើ ម្ចាស់មតក ស្លាប់ទៅ មិនបានផ្ដាំ ទុកយ៉ាងណាៗ ទេ ។

មាត្រា ៨៣០.– ប្រភេទ ដើម ទាន រាងស្វា ដង បព្វជន នៃ

ម្ចាស់មរតក នៃចំណោះឯង ដែលជាទាយាទ ត្រូវស៊ូ ការបំរុង ។

## ផ្នែកទី២

### អំពីសមត្ថភាព នៃអ្នកផ្តាំ

មាត្រា ៨៣១.- បុគ្គល ទាំងពួងណា ដែលជានីតិជន ឬដែលបាន អត្តាធិនភាព ហើយមាន សមត្ថភាព ចេះ ពិចារណា ស្គាល់ខុសត្រូវ, បុគ្គល ទាំងពួង នោះ អាច ធ្វើ បណ្តាំ មានតម្លៃ ពេញទី បាន ។

មាត្រា ៨៣២.- ឯមនុស្ស អសមត្ថភាព ដូចមានសំដែង ក្នុង មាតិកា ទី៨ មិនអាច ធ្វើ នូវបណ្តាំ ដែលត្រូវទុក ជាមានតម្លៃ ពេញទី បានឡើយ ។

មាត្រា ៨៣៣.- ស្ត្រី មានប្តី ក្នុងវេលា ដែលនៅមាន សាពាហ៍ពិពាហ៍ នៅឡើយ អាច នឹងតាក់តែង ដោយបណ្តាំ នូវទ្រព្យ ដើម របស់ខ្លួន នៃចំណោះ បាន ។

មាត្រា ៨៣៤.- ឯព្រះរាជវង្សានុវង្ស និង សាច់ញាតិ អាច នឹង ប្រទាន អំណោយ ដោយបណ្តាំ ដល់ជន ដែលមិនមែន ជាទាយាទ បាន នោះ លុះណា តែព្រះករុណា ព្រះចៅក្រុងកម្ពុជា ទ្រង់ព្រះរាជានុញ្ញាត ផង, បើ ពុំ នោះ ទេ, សេចក្តីបណ្តាំ នោះ ត្រូវ ទុក ជាមោឃៈ គ្មាន ផល ឡើយ ។

# ឧបសម្ព័ន្ធទី២

LEGISLATIVE COUNSEL BUREAU
STATE OF CALIFORNIA
AUTHENTICATED
ELECTRONIC LEGAL MATERIAL

**State of California**

**CIVIL CODE**

**Section 1714.1**

---

1714.1. (a) Any act of willful misconduct of a minor that results in injury or death to another person or in any injury to the property of another shall be imputed to the parent or guardian having custody and control of the minor for all purposes of civil damages, and the parent or guardian having custody and control shall be jointly and severally liable with the minor for any damages resulting from the willful misconduct.

Subject to the provisions of subdivision (c), the joint and several liability of the parent or guardian having custody and control of a minor under this subdivision shall not exceed twenty-five thousand dollars ($25,000) for each tort of the minor, and in the case of injury to a person, imputed liability shall be further limited to medical, dental and hospital expenses incurred by the injured person, not to exceed twenty-five thousand dollars ($25,000). The liability imposed by this section is in addition to any liability now imposed by law.

(b) Any act of willful misconduct of a minor that results in the defacement of property of another with paint or a similar substance shall be imputed to the parent or guardian having custody and control of the minor for all purposes of civil damages, including court costs, and attorney’s fees, to the prevailing party, and the parent or guardian having custody and control shall be jointly and severally liable with the minor for any damages resulting from the willful misconduct, not to exceed twenty-five thousand dollars ($25,000), except as provided in subdivision (c), for each tort of the minor.

(c) The amounts listed in subdivisions (a) and (b) shall be adjusted every two years by the Judicial Council to reflect any increases in the cost of living in California, as indicated by the annual average of the California Consumer Price Index. The Judicial Council shall round this adjusted amount up or down to the nearest hundred dollars. On or before July 1 of each odd-numbered year, the Judicial Council shall compute and publish the amounts listed in subdivisions (a) and (b), as adjusted according to this subdivision.

(d) The maximum liability imposed by this section is the maximum liability authorized under this section at the time that the act of willful misconduct by a minor was committed.

(e) Nothing in this section shall impose liability on an insurer for a loss caused by the willful act of the insured for purposes of Section 533 of the Insurance Code. An insurer shall not be liable for the conduct imputed to a parent or guardian by this section for any amount in excess of ten thousand dollars ($10,000).

